

# ខេប

## អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា

"ការអភិវឌ្ឍមនុស្សដោយភាពថ្លៃថ្នូរ"

## អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា

# របាយការណ៍ប្រចាំឆ្នាំ ២០១៣

(អង្គការ ខេប បានចុះបញ្ជីនៅក្រសួងមហាផ្ទៃក្នុងឆ្នាំ ១៩៩៩)









ខេប គឺជាអង្គការក្រៅ
រដ្ឋាភិបាលក្នុងស្រុក ដែលធ្វើការចម្បង
នៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា ។
ខេប បានប្រតិបត្តិការគម្រោងនៅគ្រប់កម្រិតជាមួយអ្នក
ទទួលផលនៅក្នុងសាលាបឋមសិក្សា អនុវិទ្យាល័យ និង
កម្មវិធីអាហារូបករណ៍សម្រាប់សិស្សនៅសាកល-
វិទ្យាល័យ ។ ចំនួនកុមារទទួលផលផ្ទាល់មានជាង
១៥០.០០០ នាក់ និងគ្រូបង្រៀនពីបីរយនាក់
ដែលបង្រៀននៅជាង ៤០០ សាលា
ក្នុង ១២ ខេត្ត ។

# ចក្ខុវិស័យ

ចក្ខុវិស័យរបស់ ខេប គឺផ្តល់លទ្ធភាពដល់កុមារ និងយុវជននូវជម្រើសដ៏ល្អបំផុតនៅក្នុងជីវិតផ្អែកលើសក្តានុពលរបស់ពួកគេតាមរយៈទទួលបានការអប់រំល្អ ។

# គុណតម្លៃ

- ការផ្តល់សិទ្ធិអំណាច
- ការសាមគ្គី
- សេចក្តីមេត្តា
- ការគោរព
- កិច្ចសហប្រតិបត្តិការ
- ការកែប្រែថ្មី/ច្នៃប្រឌិតថ្មី
- តម្លាភាព
- ជឿជាក់

# ក្រុមប្រឹក្សាភិបាល

| | |
|---|---|
| **លោក ហ៊ាង ភុយ** | ប្រធាន |
| **លោក ប៊ុន ឫទ្ធី** | អនុប្រធាន |
| **លោក ឃីត ព្រៃដិនប៊ែក** | ទីប្រឹក្សា-មិនបោះឆ្នោត |
| **លោក ធុច ថាត** | សមាជិក |
| **លោកស្រី ហែម មណី** | សមាជិក |
| **លោក ឆាយ ទីប៉ា** | សមាជិក |

# មាតិកា

**សារនាយកប្រតិបត្តិ** ........................................ 3
**សេចក្តីសង្ខេប** ........................................ 4
**ការឆ្លុះបញ្ចាំង និងការឆ្ពោះទៅមុខ** ........................................ 5

# កម្មវិធី

គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBEC)................ *6*
កម្មវិធីសាកល្បងទប់ស្កាត់ការបោះបង់ការសិក្សា (SDPP).......... *8*
គម្រោងសាលារៀនដៃគូ (BSI) ........................................ *10*
គម្រោងលើកកម្ពស់សេវាកម្មសុខភាពសាលារៀន *(ISHS)* ...... *12*
កម្មវិធីអាហារពេលព្រឹក *(SFP)* ........................................ *13*
គម្រោងសាលារៀនល្អប្រសើរ *(SfE)*........................................ *14*
កម្មវិធីអប់រំបញ្ចូលគ្នា *(IEP)*........................................ *16*
គម្រោងសាលារៀនមានបំណិនជីវិតពេញបរិបូរណ៍ *(SELLS)* ...*20*
គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ *(REACH)* ........................................ *21*
គម្រោងគាំទ្រការសិក្សារបស់សិស្ស *(PLP)* ........................... *23*
គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ *(TRAC)24*
គម្រោងខ្ញុំកំពុងរៀន *(QLE)*........................................ *26*

**ព្រឹត្តិការណ៍សំខាន់ៗ និងការអភិវឌ្ឍក្នុងឆ្នាំនេះ** .........27
**ការបង្ហាញហិរញ្ញវត្ថុ** ........................................29
**ក្រុមអ្នកគ្រប់គ្រងនៅក្នុងឆ្នាំ ២០១៣** ..........................30
**រចនាសម្ព័ន្ធអង្គការ ខេប** ........................................*31*

# សារនាយកប្រតិបត្តិ

ជូសមុខឱ្យសហគមន៍ខេប ខ្ញុំមានសេចក្តីរីករាយ សូមធ្វើការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំស្តីពីប្រតិបត្តិការរបស់យើងសម្រាប់ឆ្នាំ ២០១៣ នៃសារពើពន្ធនេះ ។



របាយការណ៍បានបង្ហាញពីការផ្តល់ជំនួយតាមរយៈអង្គការសម្រាប់អនុវត្តគម្រោងទាំង ១៤ នៅក្នុងឆ្នាំចាស់ ។ ថ្វីត្បិតតែការអភិវឌ្ឍគម្រោងថ្មីនៅក្នុងឆ្នាំនេះបាន និងកំពុងប្រឈមនិងជួបការលំបាកយ៉ាងណាក៏ដោយ ខេប នៅមានលទ្ធភាពទទួលបានជោគជ័យពីការស្វែងរកធនធានគាំទ្រកម្មវិធីថ្មីក្នុងឆ្នាំនេះមានគម្រោងចំនួន ៤ កំពុងចាប់ផ្តើមអនុវត្ត រួមមាន: **គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ** (គាំទ្រដោយអង្គការ All Children Reading/អង្គការអប់រំពិភពលោក) **គម្រោងសាលារៀនល្អប្រសើរ** (គាំទ្រដោយអង្គការ Classroom of Hope) **គម្រោងខ្ញុំកំពុងរៀន** (គាំទ្រដោយអង្គការ Save the Children) និង**គម្រោងលើកកម្ពស់សេវាសុខភាពសាលារៀន** (គាំទ្រដោយមូលនិធិ Breteau) ។

គម្រោងធំបំផុតរបស់អង្គការ ខេប គឺគម្រោងការសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (គាំទ្រដោយ USAID/Creative Associates) ត្រូវបានបន្តសុពលភាពរយៈពេល១៨ខែបន្ថែមទៀត ដែលជាព័ត៌មានដ៏ល្អសម្រាប់អង្គការ ខេប ។ អង្គការ ខេប បានបង្កើននូវគម្រោងស្រាវជ្រាវរយៈពេលខ្លីដែលគាំទ្រមូលនិធិដោយអង្គការសង្គ្រោះកុមារអន្តរជាតិ (Save the Children International) ដើម្បីសិក្សាអំពីផលប៉ះពាល់គុណភាពបរិស្ថានសិក្សាលើការអភិវឌ្ឍ និងលទ្ធផលនៃការសិក្សារបស់កុមារ ដែលជាផ្នែកមួយរបស់គម្រោងខ្ញុំកំពុងរៀន (I´m Learning) ការសិក្សាអំពីនិន្នាការចុះឈ្មោះចូលរៀននៅក្នុងទីក្រុងភ្នំពេញ និងការសិក្សាអំពីកម្មវិធីថែទាំ និងអភិវឌ្ឍកុមារតូច (ECCD) ។ ឱកាសទាំងនេះធ្វើឱ្យអង្គការ ខេប បានយល់ដឹងកាន់តែប្រសើរឡើងអំពីបរិស្ថាននៃការប្រតិបត្តិនៅក្នុងប្រទេសកម្ពុជា និងការលើកស្ទួយការអភិវឌ្ឍកម្មវិធីផ្អែកលើភស្តុតាងជាក់លាក់ ។

នៅក្នុងឆ្នាំនេះ អង្គការ ខេប ក៏បានសម្រេចសមិទ្ធផលជាចម្បងផងដែរ រួមមាន: ការបើកដំណើរការសហគ្រាសសង្គមជាផ្លូវការដំបូងនៅកម្ពុជា ដែលផ្តោតសំខាន់លើការផលិតសម្ភារៈឧបទេសជំនួយក្នុងការរៀន និងបង្រៀនប្រកបដោយនិរន្តរភាព ។ សហគ្រាសសង្គមនេះមានគោលបំណងធ្វើឱ្យសម្ភារៈឧបទេសបង្រៀនមានតម្លៃថោកសមរម្យសម្រាប់សាលារៀន ដែលមិនមានពាក់ព័ន្ធជាមួយនឹងគម្រោងណាមួយជាក់លាក់ឡើយ ។ សហគ្រាសសង្គមនេះមានឈ្មោះថា "ធនធានសិក្សា" ឬ "ធធស" បានបង្កើតសម្ភារៈឧបទេសបង្រៀនបែបច្នៃប្រឌិតដ៏ច្រើនជាភាសាខ្មែរមិនដែលធ្លាប់មានពីមុនសម្រាប់សាលារៀន (សូមចូលមើលគេហទំព័រ: www.tts-kape.org) ។

អង្គការ ខេប ក៏បានបញ្ចប់គម្រោងសាងសង់ថ្មី ដែលបង្ហាញអំពីរចនាបទស្ថាបត្យកម្មកសាងសាលារៀនថ្មីនៅក្នុងបរិបទនៃប្រទេស  កម្ពុជា ។ ខណៈអង្គការ ខេប មិនដែលបានដាក់ទុនវិនិយោគលើគម្រោងផ្នែកហេដ្ឋារចនាសម្ព័ន្ធនោះឡើយពីព្រោះតែគម្រោងការនេះបានបង្ខំឱ្យអង្គការយល់ព្រមជម្រុញការអភិវឌ្ឍឱ្យបានចប់សព្វគ្រប់ជាស្ថាពរនៅក្នុងឆ្នាំនេះ ដើម្បីបង្កើតវិធីសាស្ត្រថ្មីសម្រាប់ពង្រឹងបរិស្ថានសិក្សារបស់សាលារៀនដែលមានតម្លៃដូចទៅនឹងការរចនាសាលាស្តង់ដាមួយពេញលេញ ។ គម្រោងនេះត្រូវបានគាំទ្រដោយធនធានរួមពីរដ្ឋ និងឯកជន រួមមាន: ក្រុមហ៊ុន Flight Center ក្រុមហ៊ុន Apple Corporation ពីជំនួយឯកជន មូលនិធិ OakTree និងធនធានផ្ទាល់របស់អង្គការ ខេប ។ នៅទីបំផុត អង្គការ ខេប ទទួលបានជោគជ័យដ៏ត្រចះត្រចង់អំឡុងឆ្នាំក្នុងការស្វែងរកការគាំទ្រកម្មវិធីថ្មីជាមួយករណីសិក្សារបស់អង្គការ ដែលត្រូវបានធ្វើការផ្សព្វផ្សាយជាសាធារណៈដោយក្រុមប្រឹក្សាអូស្ត្រាលីដើម្បីអភិវឌ្ឍអន្តរជាតិ (ACFID) និងមណ្ឌលសិក្សាអប់រំតាមបែបថ្មី (CEI) ។

អង្គការ ខេប សូមថ្លែងអំណរគុណចំពោះក្រសួងអប់រំ យុវជន និងកីឡា ដៃគូអភិវឌ្ឍនានា និងសង្គមស៊ីវិលដែលបានគាំទ្រ និងធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ និងការតាំងចិត្តឆ្ពោះទៅរកជោគជ័យនៅឆ្នាំបន្តទៀត ដើម្បីលើកកម្ពស់គុណភាពការសិក្សានៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធនៃប្រទេសកម្ពុជា ។

KAMPUCHEAN ACTION FOR PRIMARY EDUCATION

**សៅ វណ្ណា**

នាយកប្រតិបត្តិ

# សេចក្តីសង្ខេប

កម្មវិធីរបស់អង្គការ ខេប បានបន្តបង្ហាញការអភិវឌ្ឍគម្រោងដែលមានអត្រាកើនខ្ពស់ជាប្រវត្តិសាស្ត្រ ព្រមទាំងការគាំទ្រគម្រោងទាំង ១៤ ដែលមានសាច់ប្រាក់ដល់ **៣.១១១.៥៣៣,៧៥ ដុល្លារអាមេរិក** ។ តួលេខនេះបង្ហាញអំពីកំណើនមូលនិធិឆ្នាំចាស់ ៣៩០.២០៩,៧០ ដុល្លារអាមេរិក ឬមានកំណើនចំនួន ១៤,៣% ។ កម្មវិធីអង្គការ ខេប ក៏បានបន្តអនុវត្តន៍គម្រោងតូចៗផ្សេងៗជាច្រើនទៀត ដូចជា គម្រោងបច្ចេកវិទ្យា និងគម្រោងលក្ខណៈតូចៗជាច្រើន ។ គម្រោងទាំងនេះមានលក្ខណៈប្លែកៗពីគ្នាបញ្ចូលគ្នា និងគម្រោងធំៗ (ឧ. គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBEC)) ដែលផ្តោតសំខាន់លើបញ្ហាអភិវឌ្ឍសំខាន់ៗ ដូចជា កម្មវិធីអំណានថ្នាក់បឋម (ឧ. គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRAC)) កម្មវិធីសិក្សាពីហិរញ្ញវត្ថុ (ឧ. កម្មវិធី Aflateen) ។ អត្រាប្រើប្រាស់មូលនិធិក៏នៅបន្តមានភាពរឹងមាំខ្លាំងផងដែរ ដែល ៨៤% នៃប្រាក់ចំណូលបានចំណាយក្នុងឆ្នាំនេះ និងមូលនិធិ (៧៨%) ត្រូវបានផ្តល់សម្រាប់កុមារ សាលារៀន ដៃគូក្នុងស្រុក និងកម្មវិធីស្រាវជ្រាវអប់រំ ។ ម៉្យាងវិញទៀត អង្គការ ខេប បានបង្ហាញកំណើនទទួលមូលនិធិពីប្រភពផ្សេងៗគ្នាមានទឹកប្រាក់ចំនួន ១១០.០០០ ដុល្លារអាមេរិក នៅក្នុងឆ្នាំនេះពីវិស័យឯកជន រួមមាន ធនាគារ *Barclay's Bank* ក្រុមហ៊ុន *Apple Corporation* និងក្រុមហ៊ុន *Flight Center* ។ អង្គការ ខេប ក៏សង្ឃឹមយ៉ាងមុតមាំផងដែរថា នាពេលឆាប់ៗនេះការប្រតិបត្តិការសហគ្រាសសង្គម (TTS) នឹងបន្ថែមលើលំហូរមូលនិធិឯកជននេះ ដែលជាសហគ្រាសសង្គមមួយបានប្រែខ្លួនធំរឹងមាំដោយសារប្រតិបត្តិការការងារខ្លួន ។




អ្វីដែលគួរឱ្យចាប់អារម្មណ៍មួយទៀតនៅក្នុងឆ្នាំនេះគឺការរៀបចំ"មណ្ឌលសិក្សាគំរូ" បានបញ្ចប់ដោយពេញលេញ ។ ក្នុងកំឡុងពេលដែលអង្គការ ខេប មិនបានវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ព្រោះគម្រោងនេះគឺជាធនធានផ្តួចផ្តើម ទើបនៅឆ្នាំនេះ អង្គការ ខេប អភិវឌ្ឍវិធីសាស្ត្រថ្មីពេញលេញ ដើម្បីពង្រឹងបរិស្ថានសិក្សាសាលារៀនដូចទៅនឹងរចនាសាលារៀនស្តង់ដា ដែលប្រើប្រាស់នូវរចនាបទស្ថាបត្យកម្មសាលាបង្កើតថ្មីនៅក្នុងបរិបទកម្ពុជា ។ ការវិនិយោគនេះត្រូវបានគាំទ្រពីមូលនិធិរួមពីរដ្ឋ និងឯកជនតាមរយៈការស្វែងរករបស់អង្គការ ខេប ជាមួយវិស័យឯកជន ។ អង្គការ ខេប ក៏បានជោគជ័យដ៏ល្អផងដែរនៅឆ្នាំនេះក្នុងការខិតខំប្រឹងប្រែងផ្សព្វផ្សាយអំពីបទពិសោធន៍ធ្វើកម្មវិធីបង្កើតថ្មីជាមួយកម្មវិធីអង្គការ ដែលបច្ចុប្បន្នកំពុងត្រូវបានផ្សព្វផ្សាយដោយក្រុមប្រឹក្សាអូស្ត្រាលីដើម្បីអភិវឌ្ឍអន្តរជាតិ និងមណ្ឌលសិក្សាបង្កើតថ្មី (www.educationinnovations.org) ។

អង្គការ ខេប បានកំពុងធ្វើការងារសហការដ៏ជិតស្និតជាមួយក្រសួងអប់រំ យុវជន និងកីឡានៅតាមតំបន់ជាច្រើន ប៉ុន្តែសំខាន់គឺខិតខំពង្រឹងអំណាននៅថ្នាក់បឋម ។ ជាមួយគ្នានេះដែរ អង្គការ ខេប បានធ្វើការយ៉ាងជិតស្និតជាមួយនាយដ្ឋានបឋមសិក្សា និងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីអភិវឌ្ឍស្តង់ដារអំណានសម្រាប់ថ្នាក់ទី ១ និងទី ២ ។ ឯកសារនេះនឹងត្រូវបានគណៈកម្មាធិការត្រួតពិនិត្យសៀវភៅបោះពុម្ពរបស់ក្រសួងធ្វើការត្រួតពិនិត្យក្នុងពេលឆាប់ៗនេះ ។ ការបោះពុម្ពស្តង់ដារអំណានទាំងនេះនឹងលើកកម្ពស់ការវាយតម្លៃបន្ត និងព្រមទាំងឯកសារយោងអំពីសម្ភារៈបង្រៀនថ្មីៗដែលបង្កើតឡើងដោយធនធានសិក្សា (TTS) ត្រូវបានក្រសួងឯកភាពផងដែរ ។

ចុងក្រោយនេះ អង្គការ ខេប ក៏បានបង្កើនវិនិយោគលើគម្រោងស្រាវជ្រាវរយៈពេលខ្លីគាំទ្រមូលនិធិដោយអង្គការ Save the Children ធ្វើការសិក្សាពីគុណភាពបរិស្ថានសិក្សា ការសិក្សាពីនិន្នាការចុះឈ្មោះចូលរៀននៅទីក្រុងភ្នំពេញ និងការសិក្សាអំពីការគាំពារ និងការអភិវឌ្ឍន៍កុមារតូច ។ ឯកសារនេះអាចរកបាននៅគេហទំព័រអង្គការ ខេប www.kapekh.org។ ឱកាសក្នុងការស្រាវជ្រាវទាំងនេះបានធ្វើឱ្យអង្គការ ខេប ដឹងប្រសើរជាងមុនអំពីបរិស្ថានអនុវត្តនៅក្នុងប្រទេសកម្ពុជា និងលើកស្ទួយការអភិវឌ្ឍន៍កម្មវិធីផ្អែកលើភស្តុតាង ។

**គម្រោងចំនួន១៤ បានអនុវត្តក្នុងឆ្នាំ ២០១៣**

| | |
|---|---|
| ឈ្មោះ IBEC | គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា |
| SDPP | កម្មវិធីសាកល្បងទប់ស្កាត់ការបោះបង់ការសិក្សា |
| BSI | គម្រោងសាលារៀនដៃគូ |
| ISHS | គម្រោងលើកកម្ពស់សេវាកម្មសុខភាពសាលារៀន |
| GEI | គម្រោងអប់រំកុមារី |
| CTSP | គម្រោងអាហារូបករណ៍សិស្សនៅសាកលវិទ្យាល័យ |
| PEI | គម្រោងអប់រំជនជាតិពូន |
| SELLS | គម្រោងសាលារៀនមានបំណិនជីវិតពេញបរិបូណ៌ (Aflateen & Aflatoun) |
| SfE | គម្រោងសាលារៀនល្អប្រសើរ |
| SFP | កម្មវិធីអាហារពេលព្រឹក |
| REACH | គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ |
| PLP | គម្រោងគាំទ្រការសិក្សារបស់សិស្ស |
| TRAC | គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ |
| QLE/ ILP | គម្រោងខ្ញុំកំពុងរៀន! |

# ការស្ទុះបញ្ឈាំង និង ការឆ្ពោះទៅមុខ!



សកម្មភាពធ្វើឡើងក្នុងគម្រោង TRAC រួមមានការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាសម្រាប់រៀនអក្សរ និងលេខនពន្ធជាមូលដ្ឋាន ។

ថ្វីបើការធ្វើទិសដៅគម្រោងមានលក្ខណៈវិជ្ជមានក៏ដោយក៏អង្គការ ខេប នៅតែមានការលំបាកក្នុងការទទួលជំនួយពីដៃគូអភិវឌ្ឍមួយចំនួន ដែលចំពេលគេប្តូរទិសដៅជំនួយពីវិស័យអប់រំទៅបម្រើវិស័យដទៃទៀត ។ នេះចង់និយាយផ្តោតសំខាន់លើការព្យួរជំនួយសម្រាប់វិស័យអប់រំរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) ដែលមានផលប៉ះពាល់នៅចុងឆ្នាំ ២០១៤ នេះ ។ អង្គការ ខេប បានកំពុងរៀបចំខ្លួនចំពោះការបង្អាក់ជំនួយពី USAID ដោយពន្លឿនការអភិវឌ្ឍកម្មវិធីរបស់ខ្លួននៅពេលគម្រោងធំចប់ ក៏បង្កើនចំនួនគម្រោងតូចៗ គម្រោងនៅថ្នាក់មូលដ្ឋានតាមតំបន់របស់គម្រោងគោល (ឧ.ខេត្តកំពង់ចាម) ។ គម្រោងដាក់ស្នើសរុបទាំង ៩ ទទួលបានជោគជ័យចំនួន ៦ ខណៈដែលគម្រោងមួយទៀតកំពុងរងចាំអនុម័ត ។ ទោះបីជាយ៉ាងណាក៏ដោយ គម្រោងដែលបានដាក់ស្នើមិនបានទទួលជោគជ័យ ឬត្រូវដកចេញដោយសារមិនស្របនឹងបេសកកម្ម និងចក្ខុវិស័យរបស់អង្គការ ខេប ។ សេចក្តីសង្ខេបកម្មវិធីអភិវឌ្ឍនៅឆ្នាំនេះមានបង្ហាញនៅក្នុងតារាងក្រោម ។

## ការអភិវឌ្ឍកម្មវិធី

| គម្រោង | ដៃគូ | ម្ចាស់ជំនួយ | លក្ខខណ្ឌ | រយៈពេល |
|---|---|---|---|---|
| I'm Learning Project | Save the Children Int'l<br>Royal Academy of Cambodia | Save the Children Int'l/<br>NORAD | បានយល់ព្រម | ២ ឆ្នាំកន្លះ |
| Empowering Youth through Education | Save the Children Int'l<br>Phnom Srey | Save the Children- Denmark/DANIDA | បានយល់ព្រម | ២ ឆ្នាំកន្លះ |
| School Dropout Prevention Pilot (Extension) | Creative Associates | USAID | បានយល់ព្រម | ២០ ខែ |
| Schools for Excellence (SfE) | Children's Action for Development (CAD) | Classroom of Hope | បានយល់ព្រម | ៣ ឆ្នាំ |
| | Aide et Action | Qatar Foundation | នៅរងចាំ | ៣ ឆ្នាំកន្លះ |
| Improved School Health Services Project (ISHS) | Dept. of Health, Kampong Cham | Breteau Foundation | បានយល់ព្រម | ៤ ឆ្នាំ |
| Books for Asia | The Asia Foundation | The Asia Foundation<br>USAID | បានយល់ព្រម | ២ ឆ្នាំ |
| Food for Education | Catholic Relief Service<br>World Education | US Department of Agriculture (USDA) | មិនជោគជ័យ | ៣ ឆ្នាំ |
| | World Food Program | | មិនពិចារណា | |
| SOLUTIONS | Int'l Labor Organization<br>World Education<br>Food & Agriculture Organization | US Department of Labor (USDOL) | មិនជោគជ័យ | ៤ ឆ្នាំ |
| Cymru-Khmer Program | Northwest Wales Advisory & Assistance Organization | UK Lottery | មិនពិចារណា | ៣ ឆ្នាំ |

# 6 គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBEC)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) តាមរយៈអង្គការអប់រំពិភពលោកអន្តរជាតិ (WE.IC) |
| អ្នកទទួលផលផ្ទាល់ | សិស្សកម្រិតបឋមសិក្សា ៨១.៦៤៧នាក់ (ស្រី ៣៩.២៧៧ នាក់)<br>សិស្សកម្រិតមធ្យមសិក្សា ៥៦.៤០៥នាក់ (ស្រី ២៨.៤៧០នាក់)<br>អ្នកទទួលផលសរុបៈ ១៣៨.០៥២ នាក់ (ស្រី ៦៧.៧៤៧នាក់) |
| ថវិកាប្រចាំឆ្នាំ ២០១៣ | ៦៧៩.៤៦៣,៥០ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | ៤,៩២ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | ៦ ខេត្ត (កំពង់ចាម ក្រចេះ សៀមរាប ស្វាយរៀង ព្រៃវែង និងកំពង់ធំ) |
| ស្រុកគ្របដណ្តប់ | ៥០ ស្រុក (១៦ ក្នុងខេត្តកំពង់ចាម ៦ ខេត្តក្រចេះ ១០ ខេត្តសៀមរាប ៥ ខេត្តស្វាយរៀង ៨ ខេត្តព្រៃវែង និង ៥ ក្នុងខេត្តកំពង់ធំ) |
| បឋមសិក្សាគោលដៅ | ១៩២ បឋមសិក្សា |
| មធ្យមសិក្សាគោលដៅ | ១៣០ អនុវិទ្យាល័យ |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | តុលា ២០០៩ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | កញ្ញា ២០១៤ |

### សមាសភាគបច្ចេកទេសទាំង ៤ របស់គម្រោង IBEC

១. កសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងការស្វែងរកការគាំទ្រដើម្បីនិរន្តរភាព
២. បង្កលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌
៣. កែលម្អការគ្រប់គ្រងសាលារៀន និងការចូលរួមពីសហគមន៍
៤. កែលម្អបរិបទទំនាក់ទំនងអប់រំ

មន្ត្រីបច្ចេកទេសរបស់អង្គការ ខេប បានធ្វើសកម្មភាពនៅក្នុងសមាសភាគទី ២, ៣ និង ៤ អំឡុងពេលដែលអង្គការអប់រំពិភព-លោកបានសហប្រតិបត្តិការនៅក្នុងសមាសភាគទី ១ ។ សមាសភាគទី ១ សង្កត់ធ្ងន់ទៅលើការកសាង និងពង្រឹងសមត្ថភាពអង្គការ ខេប ដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដើម្បីឈានទៅទទួលជំនួយដោយផ្ទាល់ពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ ។ គម្រោង IBEC គឺជាគម្រោងដ៏ធំរបស់អង្គការ ខេប ហើយផ្តល់នូវសេវាកម្មគាំទ្រដើម្បីអភិវឌ្ឍសាលារៀន ដូចជា កម្មវិធីអាហារូបករណ៍ដល់កុមារក្រីក្រ ជំនួយការបង្ការសម្រាប់កុមារជាមួយនឹងតម្រូវការសិក្សាពិសេស ការអភិវឌ្ឍបណ្ណាល័យ ការបណ្តុះបណ្តាលគ្រូ ការអប់រំបំណិនជីវិត បណ្តាញកុមារជួយកុមារ ក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាកុមារី និងការគាំទ្រលើហេដ្ឋារចនាសម្ព័ន្ធជាដើម ។

## បច្ចុប្បន្នភាពគម្រោង

គម្រោង IBEC ទទួលបានជោគជ័យដ៏សំខាន់ក្នុងអំឡុងឆ្នាំនេះ ។ គម្រោង និងក្រសួងអប់រំ យុវជន និងកីឡា បានយល់ព្រមចាប់ផ្តើមប្រើប្រាស់កម្មវិធីបំណិនជីវិត ដែលបានធ្វើការសាកល្បងជោគជ័យនៅក្នុងឆ្នាំ ២០១២ ។ ទោះបីគម្រោងមិនទាន់អាចទទួលបានលទ្ធផលឯកភាពនៃកម្មវិធីសិក្សាទាំងអស់នៅក្នុងឆ្នាំនេះក៏ដោយ ក៏គម្រោងអាចទទួលបានការឯកភាព ៧៣% នៃកម្មវិធីបំណិនជីវិតចំនួន ៣០ម៉ូឌុល ហើយជាង ៦ម៉ូឌុលទៀតកំពុងស្ថិតនៅក្នុងការពិចារណា ។

ព្រឹត្តិការណ៍សំខាន់មួយទៀតនៅឆ្នាំនេះ គឺការធ្វើសមាហរណកម្មកម្មវិធីគាំទ្រសាលារៀនជាមួយផែនការវិនិយោគថ្នាក់ឃុំ ដែលជាយុទ្ធសាស្ត្រគន្លឹះសម្រាប់បន្តឱ្យមាននិរន្តរភាពពេលគម្រោងចប់ ។ ក្នុងបរិបទនេះ ឃុំ១៦បានផ្តល់មូលនិធិវិនិយោគសម្រាប់គាំទ្រដល់សកម្មភាពអប់រំនៅសាលាគោលដៅរបស់គម្រោង IBEC ។

គម្រោងក៏បានទទួលជោគជ័យផងដែរក្នុងការជួយអង្គការដៃគូក្នុងស្រុកឈ្មោះ អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម (BSDA) ដើម្បីបានការទទួលស្គាល់ពីគណកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ដែលជាភ្នាក់ងារទទួលស្គាល់គុណភាពរបស់អង្គការនៅក្នុងប្រទេសកម្ពុជា ។ សមិទ្ធិផលនេះព្រមជាមួយការទទួលស្គាល់គុណភាពរបស់អង្គការ ខេប នឹងមានលក្ខណៈស្របច្បាប់យូរអង្វែងសម្រាប់គម្រោងដែលនឹងជួយកសាងសិទ្ធិអំណាចស្ថាប័ននៅក្នុងវិស័យអប់រំដើម្បីបន្តអន្តរាគមន៍ ត្រូវបានសាកល្បងដោយគម្រោង IBEC ដូចទៅនឹងទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិបានធ្វើកន្លងមកក្នុងវិស័យសុខាភិបាល ។ ម៉្យាងវិញទៀត គម្រោង IBEC បានរៀបចំពិធីប្រគល់វិញ្ញាបណបត្រចូលរួមជាអធិបតីភាពពីក្រសួងអប់រំ យុវជន និងកីឡា ដែលជាព្រឹត្តិការណ៍មួយដ៏សំខាន់ក្នុងឆ្នាំនេះ ។ អ្វីដែលសំខាន់របស់គម្រោងចុងក្រោយនេះ គឺសហគ្រាសសង្គមួយឈ្មោះ **ធនធានសិក្សា** ដែលធានាបន្តលំហូសម្ភារៈបង្រៀនដល់សាលារៀន មានភាពឯករាជ្យពីគម្រោងនៅកំឡុងឆ្នាំនេះ ។




**សៀវភៅកម្មវិធីបំណិនជីវិតៈ** *សៀវភៅកម្មវិធីបំណិនជីវិតកំពុងត្រូវបានពិនិត្យដោយក្រុមប្រឹក្សាត្រួតពិនិត្យសៀវភៅរបស់ក្រសួង ។ សៀវភៅពណ៌ខៀវផ្តោតលើបញ្ហាសង្គម ពណ៌បៃតងបង្ហាញពីបំណិនផ្ទាល់ខ្លួន និងពណ៌លឿងបង្ហាញអំពីកម្មវិធីបំណិនជីវិតផ្នែកសេដ្ឋកិច្ច ។*



**ការលើកកម្ពស់ផ្នែកវិទ្យាសាស្ត្រៈ** *សិស្សធ្វើពិសោធន៍នៅពេលគ្រូឈរពីក្រោយ*

# “ ការសាកល្បងកែលម្អការអប់រំសម្រាប់សតវត្សទី ២១ ”

## រូបភាពសកម្មភាពថ្មីៗ

***កន្លែងលាងដៃ:*** *បានកសាងសម្រាប់សិស្សលាងដៃចាប់ពី ១០ទៅ ១២នាក់បានក្នុងពេលតែមួយ ។*





***ការស្រាវជ្រាវគុណភាព និងជំនាញពាក់ព័ន្ធ:*** *គម្រោ IBEC បានកែលម្អជាច្រើននៅសាលារៀន រួមមាន: បណ្ណាល័យគំរូ (រូបខាងលើ) និងកម្មវិធីបំណិនជីវិត ដូចជាថ្នាក់រៀនជួសជុលកង់ (រូបខាងឆ្វេង) ។*



## រឿងជោគជ័យ:

*ការអប់រំបំណិនជីវិតរួមផ្សំនឹងការទូន្មានក្នុងគ្រួសារបានរក្សាកុមារឱ្យបន្តការសិក្សា និងអាចបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារនៅក្នុងពេលតែមួយ ។*

ចិត្រ ស្រីរ៉ា គឺជាសិស្សរៀននៅថ្នាក់ទី ៨ វិទ្យាល័យ សង្កើប ស្រុកបាធាយ ខេត្តកំពង់ចាម ដោយទទួលបានអាហារូបករណ៍ពីគម្រោង IBEC ។ នាងជាកូនទី២ចេញពីគ្រួសារមួយដែលមានសមាជិកគ្រួសារ ៥នាក់ រួមទាំងឪពុកម្តាយផ្ទុកមេរោគអេដស៍ និងកំពុងបានទទួលការព្យាបាលពីមន្ទីរពេទ្យជើងព្រៃ ។

កាលពីឆ្នាំទៅ គ្រួសាររបស់នាងទទួលបានចំណូលពីការចិញ្ចឹមជ្រូកដែលឧបត្ថម្ភដោយកម្មវិធីសាលាជួយគ្រួសារ ដែលជាផ្នែកមួយនៃកម្មវិធីបំណិនជីវិតរបស់គម្រោង IBEC ។ ជំនួយនេះគឺជាផ្នែកមួយនៃសកម្មភាពឧបត្ថម្ភអាហារូបករណ៍សម្រាប់សិស្សក្រីក្រ ។ ស្រីរ៉ា បានរៀនចិញ្ចឹមជ្រូកនៅសាលាដែលជាមុខវិជ្ជាកម្មវិធីបំណិនជីវិតរបស់នាង ហើយនាងបានប្រើប្រាស់ជំនាញនេះដើម្បីជួយគ្រួសារនាងចិញ្ចឹមកូនជ្រូក ដែលទទួលបានពីគម្រោង ។ ចាប់ពីឆ្នាំមុនមកដល់ឆ្នាំនេះ គ្រួសារនាងមានកូនជ្រូកចំនួន ១១ក្បាល ។

ទោះបីជា ស្រីរ៉ា មកពីគ្រួសារក្រីក្រមែន តែនាងបានចំណាយពេលច្រើនចូលរួមក្នុងសកម្មភាពសាលា ដូចជា ធ្វើជាសមាជិកក្រុមប្រឹក្សាកុមារ ចូលរួមវគ្គបំប៉នបន្ថែម និងសិក្សាភាសាអង់គ្លេសពេលល្ងាចជាមួយព្រះសង្ឃនៅវត្តក្នុងភូមិរបស់នាង ។ ជានិច្ចកាល ស្រីរ៉ា ទទួលបានការលើកទឹកចិត្តពីគ្រូបង្រៀនឱ្យនាងខិតខំព្យាយាមរៀនសូត្រ ។ បច្ចុប្បន្ននេះ នាងទទួលបានលិខិតសរសើរពីសាលាចំពោះការខំសង្វាតរៀនរបស់នាង ។ ស្រីរ៉ា បាននិយាយថា “*ខ្ញុំចង់រៀនឱ្យចប់ថ្នាក់ទី ១២ និងបន្តការសិក្សាទៅសាកលវិទ្យាល័យ ។ គ្រូបានប្រាប់ខ្ញុំថា ខ្ញុំនឹងអាចរកការងារធ្វើមួយដ៏ល្អនៅក្រុមហ៊ុន ឬធនាគារបាន ប្រសិនបើខ្ញុំបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ*” ។ ឪពុកម្តាយនាងបានប្តេជ្ញាចិត្តបញ្ជូននាងទៅសាលា រៀន ព្រោះនាងមានការតាំងចិត្តខិតខំរៀនខ្លាំងជាងបងប្អូនស្រីដទៃទៀត ។ ពួកគេជឿថា ស្រីរ៉ា អាចទទួលជោគជ័យ ។ ឪពុករបស់ស្រីរ៉ាក៏បានថ្លែងអំណរគុណដល់ទីភ្នាក់ងារសហរដ្ឋ អាមេរិកដែលបានជួយគ្រួសារគាត់ ព្រោះគាត់គ្មានដីសម្រាប់ធ្វើកសិកម្មទេ និងសង្ឃឹមថា ស្រីរ៉ា អាចរៀនបានចប់ ។ គ្រួសារនាងគឺទីពឹងលើនាងទៅថ្ងៃអនាគត ។

| សកម្មភាព | ចំនួនអ្នកទទួលផល | ភេទស្រី |
|---|---|---|
| សិស្សទទួលអាហារូបករណ៍នៅបឋមសិក្សា | ៣.៩៣៨ | ២.១៤៧ |
| សិស្សទទួលអាហារូបករណ៍នៅមធ្យមសិក្សា | ១.៦០៤ | ១.១០៤ |
| គ្រូបឋមសិក្សាទទួលការបណ្តុះបណ្តាលកម្មវិធីកុមារមេត្រី | ៦៤៥ | ៣៩៦ |
| ការអនុវត្តកម្មវិធីកុមារមេត្រីនៅមធ្យម និងស្តង់ដា/ការបណ្តុះបណ្តាលគ្រូ | ៦៨៤ | ៣០៨ |
| ការបញ្ជូនកុមារទៅទទួលសេវាព្យាបាលជម្ងឺ | ៧៥ | ២៥ |
| អ្នកដែលទទួលផលប្រយោជន៍ពីការផ្គត់ផ្គង់ទឹកស្អាត | ៣៦.៩៣៧ | ១៩.៤៤៥ |
| ការបង្កើតបន្ទប់កុំព្យូទ័រ | ២ បន្ទប់ក្នុងឆ្នាំ ២០១៣ និង ២៥ តាំងពីចាប់ផ្តើមគម្រោង | |
| ការជួសជុលបន្ទប់រៀនឡើងវិញ | ៨៣ បន្ទប់ | |

## ផលជះឥទ្ធិពលរបស់គម្រោង

កំឡុងពេលអនុវត្តគម្រោង៤ឆ្នាំនេះ គម្រោង IBEC បានបន្តនូវស្តង់ដាដ៏ខ្ពស់ក្នុងការអនុវត្តទទួលបានលទ្ធផល ៩១% ពីសមាសភាគបច្ចេកទេសទាំង៤ ។ ផែនការការងារត្រូវបានឯកភាពដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិនៅខែកញ្ញា ឆ្នាំ២០១២ រួមមាន គំរូស្តង់ដាប្រចាំឆ្នាំសំខាន់ចំនួន ៥៧ ឬស្តង់ដាអនុវត្តដើម្បីទទួលបានលទ្ធផលក្នុងពេល៤ឆ្នាំ ។ ស្តង់ទាំងអស់នេះ មានតែ ៩%ប៉ុណ្ណោះដែលមិនបានទទួលលទ្ធផលក្នុងឆ្នាំនេះ ដែលមានស្តង់ដាមួយបានពន្យាពេល ។ ចំពោះសុចនាករដែលមិនត្រូវបានរំពឹងទទួលពេញលេញ គម្រោងនៅតែបន្តដំណើរ ដើម្បីទទួលបានលទ្ធផលសុចនាករនៅចុងបញ្ចប់គម្រោងឱ្យបានច្រើនបំផុត ។ គម្រោងបានបង្ហាញអំពីការជះឥទ្ធិពលទៅលើលទ្ធផលដែលពាក់ព័ន្ធនឹងការត្រួតថ្នាក់ និងការផ្លាស់ប្តូរក្នុងបញ្ហាពាក់ព័ន្ធការអប់រំ ដែលការកាត់បន្ថយការបោះបង់គឺជាបញ្ហាដ៏លំបាកសម្រាប់គម្រោង ជាពិសេស កម្រិតមធ្យមសិក្សា ។

# កម្មវិធីសាកល្បងទប់ស្កាត់ការបោះបង់ការសិក្សាសិស្ស (SDPP)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការអន្តរជាតិគ្រីអេធីវ អាសូស៊ីអេត អ៊ិនធឺណេស៊ីនណល (CAI) /USAID |
| អ្នកទទួលផលផ្ទាល់ | -សិស្ស ៣៨.១៤១ (ស្រី១៨.២៩៩) បានចូលរៀនថ្នាក់កុំព្យូទ័រ<br>-សិស្សប្រឈម ៤៣.៨៣៩ (ស្រី១៧.៩១០) បានទទួលការតាមដាន និងគាំទ្រពីកម្មវិធី រួមមានសិស្ស ២២.០៥៥ (ស្រី ៩.១៣១) បានចូលរៀនថ្នាក់កុំព្យូទ័រ ។ |
| ថវិកាប្រចាំឆ្នាំ ២០១៣ | ១.៣១៤.៥៦៨,៤៣ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | មិនមាន កំឡុងឆ្នាំនេះ |
| ខេត្តគ្របដណ្តប់ | ៦ ខេត្តៈ (បន្ទាយមានជ័យ ពោធិ៍សាត់ បាត់ដំបង កំពង់ស្ពឺ ព្រៃវែង និងស្វាយរៀង) |
| ចំនួនស្រុកគ្របដណ្តប់ | ៤៥ ស្រុក |
| បឋមសិក្សាគោលដៅ | គ្មាន |
| មធ្យមសិក្សាគោលដៅ | អនុវិទ្យាល័យ ៣២២ សាលា (២១៥ សាលាទទួលបានអន្តរាគមន៍ និង ១០៧ សាលាប្រៀបធៀប) |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | កញ្ញា ២០១០ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | បន្តដល់ខែកញ្ញា ២០១៥ |

## បច្ចុប្បន្នភាពគម្រោង

កម្មវិធីអេសឌីភីភី ទទួលបានលទ្ធផលសំខាន់ៗនៅក្នុងឆ្នាំ ២០១៣ ដូចខាងក្រោមៈ



Computer Labs: Students practicing computer skills in labs provided by SDPP

**ការសាកល្បងអន្តរាគមន៍ទាំងពីរ** បុគ្គលិកសាលារៀនបានចាប់ផ្តើមអនុវត្តអន្តរាគមន៍ប្រព័ន្ធរំលឹកជាមុននៅក្នុងសាលាទទួលបានអន្តរាគមន៍ចំនួន២១៥ នៅទូទាំង៦ខេត្ត បានទៅដល់សិស្សថ្នាក់ទី ៧-៩ ជាង៧៦.០០០នាក់ ដោយទទួលបានការបណ្តុះបណ្តាលប្រព័ន្ធរំលឹកជាមុន មុនពេលចាប់ផ្តើមឆ្នាំសិក្សា។ ការកំណត់សិស្សប្រឈមត្រូវបានបញ្ចប់ដោយមានសិស្ស៤៣.៨៣៩នាក់ ត្រូវបានកំណត់ជាសិស្សប្រឈមដោយប្រើប្រាស់កត្តាបោះបង់ការសិក្សាដែលមានស្រាប់ ដូចជា ការអវត្តមានពីសាលារៀន ការរៀនខ្សោយ និងឥរិយាបថមិនល្អក្នុងចំណោមពួកគេ។ ។ ដើម្បីគាំទ្រសាលារៀនក្នុងការអនុវត្តអន្តរាគមន៍នេះ យើងបានរៀបចំការបណ្តុះបណ្តាលប្រព័ន្ធរំលឹកជាមុន នៅក្នុងខេត្តគោលដៅទាំងអស់នៅខែវិច្ឆិកា និងដើមខែធ្នូ ឆ្នាំ២០១២ សម្រាប់សមាជិកសមាគមមាតាបិតាសិស្ស/សហគមន៍ចំនួន៩២៥នាក់ ដែលក្រោយមកបានបើកកិច្ចប្រជុំសហគមន៍ ដើម្បីលើកទឹកចិត្តឱ្យមាតាបិតាសិស្ស គាំទ្រកូនៗរបស់ពួកគាត់ឱ្យនៅរៀនបន្ត ។

សិស្សថ្នាក់ទី៧ ដល់ទី៩ ប្រហែល៣៨.០០០នាក់ នៅក្នុងសាលារៀន១០៨ ទូទាំង៦ខេត្តគោលដៅ មានឱកាសរៀនជំនាញកុំព្យូទ័រតាមរយៈកម្មវិធីសិក្សា OpenOffice ដែលត្រូវបានអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា រយៈពេលពីរម៉ោង ក្នុងមួយសប្តាហ៍។ អង្គការខេប បានផ្តល់ជំនួយផ្នែក IT នៅក្នុងខេត្តនីមួយៗ ដើម្បីជួយក្នុងពេលមានបញ្ហាកុំព្យូទ័រ និងផ្តល់វគ្គបំប៉នដល់គ្រូបង្រៀន និងនាយកសាលា ។

**ពិធីផ្សព្វផ្សាយកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា** បានប្រព្រឹត្តទៅកាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៣ នៅអនុវិទ្យាល័យបន្ទាយខ្មែរ ខេត្តកំពង់ស្ពឺ ។ ពិធីនេះត្រូវបានចូលរួមដោយសិក្ខាកាមប្រហែល៦០០នាក់ រួមមាន ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លោកស្រី រ៉េបេកកា ប្លែក នាយកបេសកកម្មប្រចាំ USAID/កម្ពុជា លោកស្រី រ៉េបេកកា អាដាម មន្ត្រីជាន់ខ្ពស់ផ្នែកអភិវឌ្ឍអប់រំមកពី USAID/Washington បុគ្គលិក USAID ផ្សេងទៀត បុគ្គលិកមកពីអង្គការខេប និងអង្គការគ្រីអេធីវ អាសូស៊ីអេត និងអ្នកពាក់ព័ន្ធសំខាន់ៗ រួមមាន អាជ្ញាធរមូលដ្ឋាន សមាជិកសហគមន៍ មាតាបិតាសិស្ស គ្រូបង្រៀន និងសិស្ស។ ឯកឧត្តម រដ្ឋមន្ត្រីបានថ្លែងអំណរគុណដល់កម្មវិធីអេសឌីភីភី ដែលបានគាំទ្រ និងសហការជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីអនុវត្តគម្រោងនេះ និងបានបំពាក់មេដាយដល់អង្គការខេប អង្គការគ្រីអេធីវ អាសូស៊ីអេត និង USAID។ សម្ភារផ្សេងទៀតត្រូវបានបង្ហាញក្នុងអំឡុងកម្មវិធីផ្សព្វផ្សាយ រួមមាន សៀវភៅណែនាំប្រព័ន្ធរំលឹកជាមុន សៀវភៅណែនាំគ្រូបង្រៀន និងសិស្សផ្នែកកុំព្យូទ័រ សម្ភារផ្សព្វផ្សាយការយល់ដឹង (ផ្ទាំងរូបភាព បដា) និងសម្ភារកម្មវិធីអេសឌីភីភី ។

កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (អេសឌីភីភី) ជាកម្មវិធីពហុប្រទេសដែលមានរយៈពេលបីឆ្នាំ ហើយកម្មវិធីនេះទទួលបានការឧបត្ថម្ភពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ក្នុងគោលបំណងដើម្បីកាត់បន្ថយអត្រាសិស្សបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ។ គម្រោងនេះមានគោលបំណងណែនាំកម្មវិធីផ្អែកលើភស្តុតាងដល់បេសកកម្មរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ និងបណ្តាប្រទេសនានានៅអាស៊ី និងមជ្ឈិមបូព៌ាអំពីការទប់ស្កាត់សិស្សបោះបង់ការសិក្សាដោយសាកល្បងនូវប្រសិទ្ធភាពអន្តរាគមន៍ទប់ស្កាត់សិស្សបោះបង់ការសិក្សានៅក្នុងប្រទេសគោលដៅចំនួនបួន រួមមាន ប្រទេសកម្ពុជា ឥណ្ឌា តាជីគីស្ថាន និងទីម័រលែស ។

កម្មិវិធីអេសឌីភីភីត្រូវបានរៀបចំឡើងដើម្បីប្រតិបត្តិការងារក្នុងបីដំណាក់កាល គឺៈ

១. កំណត់ការអនុវត្តល្អក្នុងការទប់ស្កាត់សិស្សបោះបង់ការសិក្សានៅសហរដ្ឋអាមេរិក និងប្រទេសកំពុងអភិវឌ្ឍន៍ ។
២. កំណត់ក្រុម ថ្នាក់ និង/ឬតំបន់ភូមិសាស្ត្រដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយការបោះបង់ការសិក្សា និងវិភាគលក្ខខណ្ឌ ដែលមានឥទ្ធិពលលើការបោះបង់ការសិក្សា
៣. គ្រោងរៀបចំ អនុវត្ត និងវាយតម្លៃលើអន្តរាគមន៍ ដើម្បីឱ្យសិស្សប្រឈមនឹងការបោះបង់នៅបន្តការសិក្សានៅក្នុងតំបន់ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុត ។

កម្មវិធីអេសឌីភីភី ត្រូវបានអនុវត្តដោយ អង្គការអន្តរជាតិគ្រីអេធីវ អាសូស៊ីអេត អ៊ិនធឺណេសិនណល ហើយអង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា (ខេប) កំពុងអនុវត្តកម្មវិធីអេសឌីភីភីក្នុងប្រទេសកម្ពុជា ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា។ តាមរយៈកិច្ចព្រមព្រៀង និងវិធីសាស្ត្រដែលបានអនុវត្តជាមួយក្រសួងអប់រំ យុវជន និងកីឡា កម្មវិធីអេសឌីភីភី កំពុងធ្វើការជាមួយថ្នាក់ទី៧ ទី៨ និងទី៩ ក្នុងអនុវិទ្យាល័យ ៣២២ នៅក្នុងខេត្តចំនួន៦ មានជាអាទិ៍ ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ ព្រៃវែង ពោធិ៍សាត់ និងស្វាយរៀង។ អ្នកពាក់ព័ន្ធផ្នែកអប់រំសំខាន់ៗបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់មួយក្នុងឆ្នាំ២០១១ ដើម្បីប្រមូលគំនិតលើការទប់ស្កាត់ការបោះបង់ការសិក្សាតាមរយៈដំណើរការពិគ្រោះយោបល់ ។ អន្តរា គមន៍ជាអាទិភាពចំនួនពីរ គឺ**ប្រព័ន្ធរំលឹកជាមុន** និង**បន្ទប់រៀនកុំព្យូទ័រ**ត្រូវបានបង្កើតឡើងដោយស្របតាមផែនការយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡា និងភាពដែលអាចយកទៅអនុវត្តបាន ។

***ប្រព័ន្ធរំលឹកជាមុន*** i). ប្រើប្រាស់ទិន្នន័យសាលារៀនដែលមានស្រាប់ ដូចជា វត្តមាន លទ្ធផលសិក្សា ឥរិយាបថ និងសូចនាករផ្សេងៗទៀត ដើម្បីកំណត់សិស្សប្រឈមនឹងការបោះបង់ការសិក្សា ។ II). បង្កើនសមត្ថភាពបុគ្គលិកសាលារៀនដើម្បីដោះស្រាយតម្រូវការរបស់សិស្សប្រឈមនឹងការបោះបង់ ។ III). ពង្រឹងភាពជាដៃគូរវាងបុគ្គលិកសាលារៀន និងមាតាបិតា/អាណាព្យាបាលសិស្សប្រឈមនឹងការបោះបង់ ។

***បន្ទប់រៀនកុំព្យូទ័រ*** ដំឡើងបន្ទប់រៀនកុំព្យូទ័រម៉ូឌែលស៊ិនខ្លាយអិន "thin-client" ដែលមានតម្លៃថោក ប្រើថាមពលពន្លឺព្រះអាទិត្យនៅក្នុងសាលារៀន និងផ្តល់ការបណ្តុះបណ្តាលជំនាញកុំព្យូទ័រដល់សិស្ស ដើម្បីបង្កើនការយល់ដឹងអំពីតម្លៃ និងអត្ថប្រយោជន៍នៃការនៅរៀនបន្ត ។




*ពិធីផ្សព្វផ្សាយកម្មវិធី SDPP៖ ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា (ខាងឆ្វេង)បានបំពាក់មេដាយ ជូនលោកស្រី **រ៉េបេកកា អាដាម**តំណាង USAID/Washington (កណ្តាល)*

# “ កម្មវិធីអភិវឌ្ឍន៍ផ្នែកឈើតស៊ូតាំង ”

ក្រសួងអប់រំ យុវជន និងកីឡាបានគាំទ្រចំពោះអន្តរាគមន៍ ការវាយតម្លៃផលប៉ះពាល់ និង ការបន្តគម្រោងៈ

គណៈកម្មការសម្របសម្រួលថ្នាក់ជាតិរបស់ក្រសួងអប់រំ យុវជន និងកីឡាបានជួបពិភាក្សាជាមួយអង្គការខេប/កម្មវិធី SDPP ដើម្បីធ្វើបច្ចុប្បន្នភាពលើភាពរីកចម្រើននៃកម្មវិធី និងពង្រឹងការអនុវត្តកម្មវិធីនេះ ។

ដើម្បីគាំទ្រការវាយតម្លៃគម្រោងនេះ ទិន្នន័យមូលដ្ឋានដំណាក់កាលទី២ និងទិន្នន័យពាក់កណ្តាលអាណត្តិទី១ ត្រូវបានបញ្ចប់នៅសាលារៀនចំនួន៣២២ ដោយប្រមូលទិន្នន័យស្តីពីឯកសារសាលារៀន សម្រង់អវត្តមានសិស្ស លទ្ធផលសិក្សា និងឥរិយាបថសម្រាប់សិស្ស ជាង១០០.០០០នាក់ និងបទសម្ភាសន៍ជាមួយនាយកសាលា គ្រូបង្រៀន និងសិស្ស។ នៅដំណាច់ឆ្នាំសិក្សានេះ ក្រុមការងារបានជួបប្រជុំដើម្បីឆ្លុះបញ្ចាំងអំពីការអនុវត្តកម្មវិធីក្នុងឆ្នាំសិក្សានេះ និងបានណែនាំអំពីការកែលម្អទៅលើសម្ភារ និងវិធីសាស្ត្របណ្តុះបណ្តាល ដើម្បីឱ្យការបន្តអនុវត្តគម្រោងទៅដោយរលូន។



*ពិធីផ្សព្វផ្សាយកម្មវិធីអេសឌីភីភីៈ លោក* ***ជា គុសល*** *អ្នកសម្របសម្រួលប្រចាំប្រទេសនៃកម្មវិធីអេសឌីភីភីបង្ហាញផលិតផលរបស់កម្មវិធី SDPPដល់ ឯកឧត្តម* ***អ៊ឹម សិទ្ធី*** *រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា*

## ផលប៉ះពាល់នៃការបណ្តុះបណ្តាល

| សិក្ខាកាមចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលក្នុងឆ្នាំ ២០១២-២០១៣ | ខេត្តគោលដៅ | | | | | | សរុប |
|---|---|---|---|---|---|---|---|
| | ស្វាយរៀង | ព្រៃវែង | កំពង់ស្ពឺ | ពោធិ៍សាត់ | បន្ទាយមានជ័យ | បាត់ដំបង | |
| វគ្គបំប៉នស្តីពីអន្តរាគមន៍បន្ទប់រៀនកុំព្យូទ័រ និងប្រព័ន្ធរំលឹកជាមុន | | | | | | | |
| នាយកសាលា | ២១ | ២០ | ១៩ (ស្រី២) | ១៥ (ស្រី១) | ១៤ (ស្រី១) | ១៩ (ស្រី២) | ១០៨ (ស្រី៦) |
| គ្រូកុំព្យូទ័រ | ៨៤ (ស្រី១១) | ៧៧ (ស្រី១៥) | ៧៥ (ស្រី១៥) | ៦០ (ស្រី១៧) | ៥៤ (ស្រី១១) | ៧៦ (ស្រី២៤) | ៤២៦ (ស្រី៩៣) |
| គ្រូទទួលបន្ទុកថ្នាក់ | ៣៥ (ស្រី១១) | ២៤ (ស្រី៩) | ៤១ (ស្រី១០) | ២៨ (ស្រី៨) | ៣៩ (ស្រី១៥) | ៣១ (ស្រី១៦) | ១៩៨ (ស្រី៦៩) |
| មន្ត្រីមកពីមន្ទីរអប់រំខេត្ត | ២ | ២ | ១ | ២ | ២ | ២ | ១១ |
| សរុប | ១៤២ (ស្រី២២) | ១២៣ (ស្រី២៤) | ១៣៦ (ស្រី២៧) | ១០៥ (ស្រី២៦) | ១០៩ (ស្រី២៧) | ១២៨ (ស្រី៤២) | ៧៤៣ (ស្រី១៦៨) |
| កម្មវិធីបណ្តុះបណ្តាលដល់មាគមមាតាបិតាសិស្ស/សហគមន៍ (ប្រព័ន្ធរំលឹកជាមុន) | | | | | | | |
| សិក្ខាកាមសរុប | ១៧៨ (ស្រី២៣) | ១៨១ (ស្រី១៥) | ១៦២ (ស្រី១២) | ១២២ (ស្រី១៨) | ១២៦ (ស្រី១៨) | ១៥៥ (ស្រី១៩) | ៩២៤ (ស្រី១០៥) |
| សិក្ខាកាមសរុបក្នុងកម្មវិធីបណ្តុះបណ្តាលទាំងពីរ | ៣២០ (ស្រី៤៥) | ៣០៤ (ស្រី៣៩) | ២៩៨ (ស្រី៣៩) | ២២៩ (ស្រី៤៤) | ២៣៧ (ស្រី៤៥) | ២៨៥ (ស្រី៦១) | ១៦៩៧ (ស្រី២៧៣) |

## លទ្ធផលនៃអន្តរាគមន៍ប្រព័ន្ធរំលឹកជាមុន និងបន្ទប់រៀនកុំព្យូទ័រ

| សកម្មភាពអនុវត្តនៅសាលារៀន/សហគមន៍ក្នុងខេត្តគោលដៅទាំង៦ | Total (2012-2013) |
|---|---|
| ចំនួនការហៅទូរស័ព្ទដោយសាលាទៅមាតាបិតាសិស្ស | ៨.៨៣៨ |
| ចំនួនសំបុត្រអវត្តមាន ៣ថ្ងៃ ដែលសាលាបានផ្ញើទៅមាតាបិតាសិស្សពីថ្នាក់ទី៧ ដល់ទី៩ | ៨.៧០៩ |
| ចំនួនសំបុត្រអវត្តមាន ១០ថ្ងៃ ដែលសាលាបានផ្ញើទៅមាតាបិតាសិស្សពីថ្នាក់ទី៧ ដល់ទី៩ | ៤.០១៣ |
| ចំនួនកិច្ចសន្យាចូលរួមដែលចុះហត្ថលេខាដោយមាតាបិតា និងសិស្ស | ៦.៦៦៤ |
| ចំនួនការចុះសួរនាំដល់ផ្ទះដោយសាលា/សហគមន៍ (រួមទាំងការចុះសួរនាំលើកទី២) | ១៥.០៩៦ |
| ចំនួនកិច្ចប្រជុំសហគមន៍ (ជាមធ្យមសាលានីមួយៗមានកិច្ចប្រជុំចំនួន ៣ដង តាមការគ្រោងទុករបស់កម្មវិធី) | ៦៤៣ |
| ចំនួនសិក្ខាកាមសរុបចូលរួមក្នុងកិច្ចប្រជុំសហគមន៍ (ជាមធ្យមមានអ្នកចូលរួម២៧នាក់ក្នុងកិច្ចប្រជុំនីមួយៗ) | ១៧.២៥១ (ស្រី៩.៧៨២) |
| ចំនួនការហៅទូរស័ព្ទចេញដើម្បីដោះស្រាយបញ្ហាក្នុងដំណើរការបន្ទប់រៀនកុំព្យូទ័រ (រួមទាំងបញ្ហាលើទូរស័ព្ទដែលផ្តល់ដោយកម្មវិធីអេសឌីភីភី ដើម្បីទាក់ទងជាមួយមាតាបិតាសិស្សប្រឈមនឹងការបោះបង់ការសិក្សា) | ៧៧៥ |
| ចំនួនទស្សនកិច្ចសាលារៀនដោយការិយាល័យអប់រំស្រុក | ៨១៩ |
| ចំនួនទស្សនកិច្ចសាលារៀនដោយមន្ទីរអប់រំខេត្ត | ៨៥ |

## ករណីសិក្សា

### មុខវិជ្ជាកុំព្យូទ័រទាក់ទាញសិស្សកម្ពុជាឲ្យមករៀន

**វី ផានិត** ជាសិស្សដែលមានរូបរាងតូចជាងគេក្នុងថ្នាក់ទី ៩ របស់គេនៅអនុវិទ្យាល័យ បាយដំរាំ ស្ថិតនៅភាគពាយព្យនៃប្រទេសកម្ពុជា ។ ដោយមានកម្ពស់ទាប ផានិតមានការលំបាកក្នុងការជិះកង់រៀងរាល់ព្រឹកតាមផ្លូវជនបទទៅកាន់សាលារៀនរបស់គាត់ ។

ការធ្វើដំណើរទៅសាលាគ្រាន់តែជាបញ្ហាប្រឈមមួយសម្រាប់ការសិក្សារបស់ ផា និត ។ ជាកូនច្បងក្នុងគ្រួសារ គាត់តែងតែជួយគ្រួសារក្នុងការដាំ និងថែទាំដំណាំពោត សណ្តែក និងអំពៅនៅចំការ។ អវត្តមានញឹកញាប់ និងលទ្ធផលសិក្សាខ្សោយលើមុខវិជ្ជាសំខាន់ៗមួយចំនួនដូចជាភាសាខ្មែរ និងរូបវិទ្យា បានធ្វើឱ្យកុមារដែលមានអាយុ១៥ឆ្នាំរូបនេះក្លាយជាសិស្សប្រឈមនឹងការបោះបង់ការសិក្សា។

ក្នុងប្រទេសកម្ពុជា សិស្សអនុវិទ្យាល័យប្រហែលម្នាក់ ក្នុងចំណោមប្រាំនាក់មិនអាចបន្តការសិក្សាទៅថ្នាក់វិទ្យាល័យបាន ដោយហេតុនេះ បណ្តាលឱ្យពួកគេគ្មានជំនាញ និងបាត់បង់ឱកាសក្នុងការស្វែងរកការងារ ។

ដើម្បីរក្សាសិស្សឱ្យនៅបន្តការសិក្សា កម្មវិធីសាកល្បងទប់ស្កាត់ការបោះបង់ការសិក្សា (អេសឌីភីភី/SDPP) របស់ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ដែលអនុវត្តដោយអង្គការអន្តរជាតិគ្រីអេធីវ អាសូស៊ីអេត និងអង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា កំពុងធ្វើការជាមួយសាលាចំនួន២១៥ ក្នុងខេត្តគោលដៅប្រាំមួយ ក្នុងប្រទេសកម្ពុជាដើម្បីកាត់បន្ថយអត្រាបោះបង់ការសិក្សា ។ អន្តរាគមន៍ប្រព័ន្ធរំលឹកជាមុនបានកំណត់ ផានិត ជាសិស្សម្នាក់ដែលត្រូវការការគាំទ្រដើម្បីបន្តការសិក្សារបស់គាត់ ។

ដើម្បីទាក់ទាញចំណាប់អារម្មណ៍ពីសិស្ស និងមាតាបិតាសិស្ស កម្មវិធីអេសឌីភីភី បានបំពាក់បន្ទប់រៀនកុំព្យូទ័រដល់អនុវិទ្យាល័យ បាយដំរាំ ដែលសិស្សអាចសិក្សាកម្មវិធីកុំព្យូទ័រស្របតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និង កីឡា។

លោក **តាក់ ចាន់គយ** នាយកអនុវិទ្យាល័យ បាយដំរាំ មានប្រសាសន៍ថាៈ “អន្តរាគមន៍ទាំងពីរបានកាត់បន្ថយអត្រាបោះបង់ការសិក្សានៅសាលារបស់ខ្ញុំក្នុងឆ្នាំសិក្សានេះ ។ កម្មវិធីអេសឌីភីភី មិនត្រឹមតែផ្តល់បំណិនជីវិតដ៏ពិសេស (ជំនាញកុំព្យូទ័រ) ដល់សិស្សរបស់ខ្ញុំប៉ុណ្ណោះទេ កម្មវិធីថែមទាំងតាមដានសិស្សប្រឈមនឹងការបោះបង់ការសិក្សាទៅលើអវត្ត មាន ឥរិយាបថ និងលទ្ធផលសិក្សារបស់ពួគគេ ។ ” កត្តាកំណត់ទាំងនេះត្រូវបានចាត់ទុកជាសូចនាករដ៏ច្បាស់លាស់សម្រាប់ការបោះបង់ការសិក្សា។

ក្នុងឆ្នាំសិក្សា២០១១-២០១២ អនុវិទ្យាល័យបាយដំរាំមានអត្រាសិស្សបោះបង់ការសិក្សា២៧,៣ ភាគរយ។ បន្ទាប់ពីសាលាបានទទួលអន្តរាគមន៍ប្រព័ន្ធរំលឹកជាមុន និងបន្ទប់រៀនកុំព្យូទ័រ សាលារាយការណ៍ថាអត្រាសិស្សបោះបង់ការសិក្សាក្នុងឆ្នាំសិក្សា២០១២-២០១៣ បានថយចុះដល់១៦,៨%។ លទ្ធផលជាក់លាក់នឹងត្រូវបង្ហាញតាមរយៈការវាយតម្លៃដោយប្រៀបធៀបសាលាទទួលបានអន្តរាគមន៍ និងសាលាមិនទទួលបានអន្តរាគមន៍ ដែលកម្មវិធីកំពុងអនុវត្តនៅសាលាចំនួន៣២២ ។

ផានិត មានចិត្តចង់បន្តការសិក្សារបស់គាត់ ជាពិសេសខណៈពេលដែលគាត់កំពុងពេញចិត្តនឹងការរៀនកុំព្យូទ័រជាខ្លាំង។ ផានិត និយាយថាៈ “ខ្ញុំសប្បាយចិត្តក្នុងការរៀនកុំព្យូទ័រ ពីព្រោះចំណេះដឹងកុំព្យូទ័រមានសារៈសំខាន់ណាស់សម្រាប់ការសិក្សា និងការងាររបស់ខ្ញុំនាពេលអនាគត។ ” នៅពេលដែលឃើញតម្លៃនៃចំណេះដឹងកុំព្យូទ័រ ឪពុកម្តាយរបស់ ផានិត បានទិញកុំព្យូទ័រជុំនំមួយឱ្យគាត់អាចអនុវត្តនៅផ្ទះ។ ពួកគេតែងតែរំលឹក ផានិត ឱ្យប្រឹងប្រែងរៀនសូត្រ កុំឱ្យក្លាយជាកសិករដូចពួកគេនាពេលអនាគត។

ផានិត បានស្តាប់ដំបូន្មានឪពុកម្តាយរបស់គាត់។ គាត់កំរអវត្តមាននៅសាលាណាស់ចាប់តាំងពីពេលដែលបន្ទប់រៀនកុំព្យូទ័របានដំឡើងនៅសាលារបស់គាត់។ ឆ្នាំនេះ ផានិត នឹងចូលរួមប្រលងថ្នាក់ជាតិដើម្បីបញ្ចប់ការសិក្សាមូលដ្ឋានរយៈពេល៩ឆ្នាំ។ នេះជាជោគជ័យដ៏គួរឱ្យកត់សម្គាល់មួយសម្រាប់កុមារក្នុងតំបន់ដែល ផានិត រស់នៅ។ មាស ចាន់បុប្ផា គ្រូបង្រៀនកុំព្យូទ័រដល់ ផានិត មានប្រសាសន៍ថាៈ “ផានិត ជាសិស្សពូកែម្នាក់ក្នុងថ្នាក់រៀនកុំព្យូទ័រ។ ដោយសារថ្នាក់រៀនកុំព្យូទ័រ ខ្ញុំជឿជាក់ថាផានិត នឹងបន្តការសិក្សាដើម្បីសម្រេចគោលបំណងរបស់គាត់។ ” ។



*ផានិត កំពុងអនុវត្តកុំព្យូទ័រក្នុងថ្នាក់រៀន ។ គាត់ជាសិស្សម្នាក់ក្នុងចំណោមសិស្សផ្សេងទៀតដែលតែងតែបញ្ចប់លំហាត់កុំព្យូទ័រសម្រាប់គ្រូរបស់គាត់មុនគេ។*

# គម្រោងសាលារៀនដៃគូ (BSI)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការអូកទ្រី/ក្រុមហ៊ុនFlight Center, សមាគមន៍ចិន , មូលនិធិBreteau Foundation, ម្ចាស់ជំនួយឯកជន, ក្រុមហ៊ុន Apple Corporation |
| អ្នកទទួលផលផ្ទាល់ | សិស្សថ្នាក់ទី ៧-៩ ចំនួន១៨២៥នាក់ (ស្រី៨៨៩នាក់)<br>គ្រូបង្រៀនថ្នាក់ទី ៧-៩ ចំនួន៧៨នាក់ (ស្រី ៣៧នាក់)<br>គណៈគ្រប់គ្រងសាលារៀនចំនួន១៣នាក់ (ស្រី២នាក់) |
| ថវិកាប្រចាំឆ្នាំ ២០១៣ | ១៨៥.៥០៥ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | ៩៧ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | កំពង់ចាម |
| ចំនួនស្រុកគ្របដណ្តប់ | ៣ ស្រុក |
| មធ្យមសិក្សាគោលដៅ | ៣ វិទ្យាល័យ |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ខែមករា ឆ្នាំ ២០១១ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ខែកញ្ញា ឆ្នាំ ២០១៤ |

## សនិទានភាពនៃកម្មវិធី

គម្រោងសាលារៀនដៃគូគឺជាគម្រោងដែលមានការច្នៃប្រឌិតថ្មីៗស្វែងរកគន្លងអភិវឌ្ឍជាច្រើនសម្រាប់សាលារដ្ឋដោយផ្អែកលើលក្ខណៈអំណោយផលរបស់សាលាក្នុងការប្រើប្រាស់ជំនួយបច្ចេកទេស។ គម្រោងមិនមែនត្រឹមតែផ្តល់ជំនួយបច្ចេកទេសដ៏ល្អដល់សាលាដែលត្រូវបានជ្រើសរើសប្រកបដោយសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍប៉ុណ្ណោះទេ ប៉ុន្តែក៏បានសង្កត់ធ្ងន់លើរចនាសម្ព័ន្ធអភិបាលកិច្ចពិសេសដែលធានាឲ្យការប្រើប្រាស់ធនធានទាំងនេះព្រមទាំងការឧបត្ថម្ភគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវ ដោយផ្អែកលើភារកិច្ចបន្ថែម ដែលគ្រូបង្រៀនបានបំពេញ (ឧ. ការរៀបចំគម្រោងការពិសេសពាក់ព័ន្ធនឹងការសិក្សាបែបស្ថាបនា ការផ្តល់ប្រឹក្សាអាជីព និងក្លឹបសិក្សា... ។ល។ វិធីអភិវឌ្ឍទាំងពីរគន្លងនេះបង្ហាញពីគំរូនៃភាពជាដៃគូ រវាងរដ្ឋ និងឯកជនក្នុងការគ្រប់គ្រងសាលារៀនរដ្ឋទាំងបី ដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដែលសហការយ៉ាងជិតស្និទ្ធជាមួយតួអង្គមិនមែនរដ្ឋាភិបាល (ឧ.អង្គការ ខេប)។

## បច្ចុប្បន្នភាពគម្រោង

អង្គការ ខេប បានចចារប្រកបដោយជោគជ័យ ដើម្បីឲ្យមានភាពបត់បែនពិសេស សំដៅបង្កើតនូវគំរូការគ្រប់គ្រងពាក់កណ្តាលឯកជន និងពាក់កណ្តាលរដ្ឋនៅសាលារៀនរដ្ឋទាំងបី ដោយសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ អង្គការខេប ក្នុងឋានៈជាតួអង្គមិនមែនរដ្ឋាភិបាល មិនត្រឹមតែបានបង្ហាញអំពីវិធីសាស្ត្រអប់រំល្អគ្រប់ជ្រុងជ្រោយទាក់ទងនឹងការសិក្សាបែបស្ថាបនា និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងការអប់រំ និងបរិក្ខាបច្ចេកវិទ្យាព័ត៌មាន (ឧ. បន្ទប់កុំព្យូទ័រ) ប៉ុណ្ណោះទេ ប៉ុន្តែក៏បានធ្វើការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើម្បីបង្កើតប្រឹក្សាភិបាលពិសេសដែលធានាថា មានទំនួលខុសត្រូវខ្ពស់ទៅលើការប្រើប្រាស់ធនធាន ។ តាមលំនាំជាច្រើន គំរូថ្មីនេះដូចគ្នាទៅនឹងសាលារៀន Charter Schools ប៉ុន្តែតម្រូវនឹងបរិបទពិសេសដោយឡែករបស់កម្ពុជា។ ចំណុចនេះរាប់ទាំងការផ្តល់ជាពិសេសក្នុងការដាក់បញ្ចូលទាំងអាជ្ញាធរមូលដ្ឋាន និងតួអង្គមិនមែនរដ្ឋាភិបាលទៅក្នុងក្រុមប្រឹក្សាភិបាល ប៉ុន្តែដោយទុកលទ្ធភាពនៃការបត់បែន ដើម្បីពិសោធន៍ការចាត់ចែងរបស់សាលា ថវិកាឧបត្ថម្ភគ្រូបង្រៀនតាមភារកិច្ចបន្ថែម និងខ្លឹមសារកម្មវិធីសិក្សា។ ការផ្តល់ទាំងអស់នេះឆ្លុះឲ្យឃើញនូវរបត់ប្រវត្តិសាស្ត្រវប្បធម៌នៃប្រទេសកម្ពុជាឆ្ពោះទៅរកគំរូអប់រំបែបចម្រុះមួយ ដែលប្រទេសទៃទៀតក្នុងអាស៊ានដកំពុងអនុវត្តយ៉ាងទូលំទូលាយ និងជួយជំរុញឲ្យតួនាទីប្រព័ន្ធអប់រំកម្ពុជាកាន់ប្រសើរឡើងក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមចំពោះសមាហរណកម្មអាស៊ានឆ្នាំ ២០១៥ ខាងមុខនេះ ។ គំរូថ្មីនៃការអប់រំនេះផ្តោតការយកចិត្តទុកដាក់ទៅលើបច្ចេកទេសសិក្សាទំនើបតាមរយៈការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា (ICT)។ ក្នុងន័យនេះ សិស្សមិនត្រឹមតែបានរៀនអក្សរសាស្ត្របែបឌីជីថលប៉ុណ្ណោះទេ ប៉ុន្តពួកគេក៏រៀនវិធីកសាងចំណេះដឹងតាមរយៈឧបករណ៍ ICT ផងដែរ ។ ការផ្តល់សិទ្ធិអំណាចឲ្យសិស្សគឺជាគន្លឹះមួយ នៃប្រព័ន្ធអភិបាលកិច្ចរឹងមាំដោយមានការវិនិយោគសំខាន់ៗជាច្រើនធ្វើឡើងដើម្បីបង្កលក្ខណៈឲ្យក្រុមប្រឹក្សាកុមារបង្កើនភាពម្ចាស់ការក្នុងសាលារបស់ខ្លួនកាន់តែប្រសើរឡើង។





***ពិសោធន៍រចនាបទស្ថាបត្យកម្មសាលារៀនៈ*** *បរិវេណសាលារៀនគម្រោងត្រូវបានរចនាឡើងវិញដោយមានកន្លែងសិស្សលេង និងរៀន ។ មានផ្លូវចូលទៅបរិវេណខាងក្រោយអាគារដើម្បីកុំឲ្យបរិវេណនេះទុកសម្រាប់បោះចោលសម្រាមទៀត ។ អគារមានកញ្ចក់បង្ហាញអំពីសម្ភារៈសំខាន់នៅក្នុងរចនាបទសាលារៀនដែលជាគំរូតាមអន្តរជាតិ ។ ដោយមានការណែនាំត្រឹមត្រូវល្អ ឥរិយាបទសិស្សត្រូវបានកែប្រែ និងគេចផុតពីគ្រោះថ្នាក់នានា ។*

# “ សាលារៀនរដ្ឋដែលមានស្តង់ដាឯកជន ”

## ការបង្កើតថ្មីនៅក្នុងឆ្នាំនេះ

កាលពីឆ្នាំទៅ គម្រោងបានកំណត់ដំណាក់កាលនៃការច្នៃប្រឌិតថ្មីដ៏ទូលំទូលាយមួយ ដោយដំបូងរចនាឡើងវិញទីកន្លែងរូបវន្តក្នុងសាលាគោលដៅដោយប្រើប្រាស់គោលការណ៍ស្ថាបត្យកម្មសាលារៀនសម័យទំនើប ដែលខុសប្លែកពីរចនាបទអាគារស្តង់ដាសាលារដ្ឋទូទៅ ។ រចនាបទនេះរួមមាន បន្ទប់រៀនមានពន្លឺគ្រប់គ្រាន់ អាចចល័តពីបន្ទប់មួយទៅបន្ទប់មួយទៀត បន្ថែមលំហសិក្សាខាងក្រៅ ដូចជា សួនច្បារ និងបរិវេណក្នុងអាគារសិក្សា និងការប្រើប្រាស់បរិវេណកាន់តែប្រសើរ ។ ឧទាហរណ៍ កន្លែងនៅក្រោយអាគារបន្ទប់រៀនដែលជាទម្លាប់ត្រូវបានប្រាស់ជាកន្លែងសិស្សចោលសម្រាម ។ ផ្ទុយមកវិញ សាលាគម្រោងបានព្យាយាមរចនាឲ្យបរិវេណទាំងខាងមុខ និងខាងក្រោយសម្រាប់ឱ្យសិស្សសម្រាកកំសាន្ត។ មណ្ឌលសិក្សាបង្កើតថ្មីមួយត្រូវបានកសាងឡើងដោយមានការឧបត្ថម្ភពីវិស័យឯកជន ដូចជា ក្រុមហ៊ុន *Apple Corporation* និងក្រុមហ៊ុន *Flight Center* ដោយបញ្ចូលទាំងមណ្ឌលព័ត៌មាន និងភាពងាយស្រួលសម្រាប់សិស្សរៀនតាមរយៈការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាចល័ត ។

## ផលជះរបស់គម្រោង

ខណៈដែលគម្រោងឈានដល់ឆ្នាំទី៤ នៃការអនុវត្តកម្មវិធី សូចនាករសរុប ៧០% ទទួលបានលទ្ធផល ចំណែក ១៤% កំពុងដំណើរការបច្ចុប្បន្ននេះ ។ សូចនាករ ១៤% ទៀត ដូចជា ការកាត់បន្ថយការបោះបង់ការសិក្សាបាន ៥% ឫតិចជាងមិនអាចសម្រេចបានទេ តែទោះយ៉ាងនេះក្តី ការកាត់បន្ថយអត្រាបោះបង់សម្រេចបានជាង៥០%ហើយ។  គម្រោងក៏បានវាយតម្លៃយ៉ាងល្អិតល្អន់ ទាំងក្របខ័ណ្ឌផ្ទៃក្នុង និងខាងក្រៅ ។ ការវាយតម្លៃផ្ទៃក្នុង បានរកឃើញថា សិស្សមានការផ្លាស់ប្តូរឥរិយាបទសំខាន់ៗជាច្រើនចំពោះការសិក្សា ដូចជាមានសិស្សជាច្រើនបានគិតគូដល់អនាគតរបស់ខ្លួន គេបានចូលរួមក្នុងសកម្មភាពសិក្សាបន្ថែម និងមិនចង់បោះបង់ការសិក្សា ។ល ។ ការវាយតម្លៃពីមូលនិធិ Oaktree ថ្មីៗនេះធ្វើសេចក្តីសន្និដ្ឋានប្រហាក់ប្រហែលគ្នានេះដែរ។



*ការបញ្ចូលមណ្ឌលព័ត៌មានក្នុងបរិស្ថានសិក្សា ក្លឹបប្រាស់ទូរទស្សន៍ក្នុងមណ្ឌលព័ត៌មាន ដើម្បីមើលភាពយន្តឯកសារទាក់ទងនឹងប្រធានបទសិក្សា ។*





*បន្ទប់រៀនរបស់សាលារដ្ឋដដែល មុនពេល និងក្រោយពេលចាប់ផ្តើមគម្រោង ។*

12

# គម្រោងលើកកម្ពស់សេវាកម្មសុខភាពសាលារៀន (ISHS)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | មូលនិធិ Breteau |
| អ្នកទទួលផលផ្ទាល់ | ១.០១៧ (ស្រី ៤៩៣ នាក់) |
| ថវិកាប្រចាំឆ្នាំ ២០១៣ | ១៦.៤៥០ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | ១៦,១៨ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | ១ (កំពង់ចាម) |
| ចំនួនស្រុកគ្របដណ្តប់ | ១ (ស្រុកជើងព្រៃ) |
| មធ្យមសិក្សាគោលដៅ | ១ (វិទ្យាល័យ ហ៊ុន សែន ស្គន់) |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ២០១៣ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ២០១៦ |

## បច្ចុប្បន្នភាពគម្រោង

គ្លីនិកសុខភាពសិស្សថ្មីនេះបានចាប់ផ្តើមដំណើរការក្នុងខែកញ្ញា ឆ្នាំ ២០១៣ នៅវិទ្យាល័យ ហ៊ុន សែន ស្គន់ ។ នេះគឺជាសមិទ្ធិផលមួយដ៏សំខាន់ដែលឆ្លុះឲ្យឃើញនូវកម្រិតថ្មីមួយទៀតនៃកម្មវិធីកុមារមេត្រី ព្រោះសកម្មភាពនេះផ្តួចផ្តើមដោយក្រុមប្រឹក្សាកុមារទាំងស្រុង។ ដូច្នេះ កម្មវិធីនេះបង្ហាញអំពីឥរិយាបទគំរូមួយនៃភាពម្ចាស់ការរបស់សាលា និងការលើកទឹកចិត្តឱ្យមានផ្តួចផ្តើមគំនិតថ្មីៗ ។ ក្នុងអំឡុងប្រតិបត្តិការពីរខែដំបូង មានសិស្ស លោកគ្រូអ្នកគ្រូ និងបុគ្គលិកសាលា សរុប២៧០នាក់ បានទទួលសេវាកម្មសុខភាពពីគ្លីនិកនេះ ។ ដោយមានគ្លីនិកនេះ សាលាទទួលបានកេរ្តិ៍ឈ្មោះល្បីល្បាញយ៉ាងឆាប់រហ័សនៅក្នុងសហគមន៍ ហើយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានជ្រើសរើសវិទ្យាល័យ ហ៊ុន សែន ស្គន់ ឲ្យបង្ហាញស្តីពីបទពិសោធន៍នៃការអនុវត្តការថ្នៃប្រឌិតផ្នែកអប់រំក្នុងភាពជាដៃគូជាមួយគម្រោងសាលារៀនដៃគូ (BSI) នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំស្តីពីការអភិវឌ្ឍការងារអប់រំនៅក្នុងឆ្នាំ ២០១៤ ។



***សេវាកម្មសុភាពថ្មី:*** *គិលានុបដ្ឋាយិកាថ្មីប្រចាំនៅវិទ្យាល័យ ស្គន់ ថែទាំសិស្សរងគ្រោះថ្នាក់ក្នុងថ្នាក់រៀន ។*

## សន្និទានភាពនៃកម្មវិធី

ដោយប្រកាន់ខ្ជាប់នូវវិធីសាស្ត្រអនុវត្ត ដែលលើកកម្ពស់ការអភិវឌ្ឍអ្នកពាក់ព័ន្ធ ក្រុមប្រឹក្សាកុមារនៅវិទ្យាល័យ ហ៊ុន សែន ស្គន់ បានចាប់ធ្វើសកម្មភាពរងមួយនៃការផ្តួចផ្តើមគំនិតដោយខ្លួនឯង ដើម្បីបង្កើតកន្លែងដែលគេអាចជួបប្រជុំគ្នា (សហព័ន្ធសិស្ស) និងគាំពារសិស្សឈឺនៅក្នុងសាលារៀន និងមានសិស្សជាច្រើននាក់មកពីទីឆ្ងាយ ធ្វើដំណើរដោយជិះកង់ពីផ្ទះមកកាន់សាលារៀន ។ សិស្សជាច្រើនគឺជាកូនចៅគ្រួសារក្រីក្រមានអាហារហូបចុកមិនគ្រប់គ្រាន់ ។ បន្ទាប់ពីពួកគេខំប្រឹងដោយប្រើកម្លាំង មួយចំនួនមានសុខភាពមិនល្អ ជួនកាលចុះខ្សោយកម្លាំង និងត្រូវការឈប់សម្រាក ។ ដោយសារគ្មានការផ្គត់ផ្គង់ពីសាលារៀនចំពោះតម្រូវការទាំងនេះ ដែលជា រឿយៗ គេត្រូវដេកក្នុងថ្នាក់រៀន ឬអង្គុយនៅបរិវេណក្រៅថ្នាក់ ។ ក្រុមប្រឹក្សាកុមារបានជួបម្ចាស់ជំនួយម្នាក់ ដែលបានសម្រេចចិត្តជួយគេដោះ- ស្រាយតម្រូវការនេះ ។ ការទំនាក់ទំនងទាំងនេះហើយបានឈានដល់ការសាងសង់ គ្លីនិកសុខភាពដែលមានការផ្គត់ផ្គង់គ្រប់គ្រាន់នៅវិទ្យាល័យ ស្គន់ ដោយមានគិលានុបដ្ឋាយិកាពេញម៉ោងផ្តល់ដោយការិយាល័យសុខាភិបាល ស្រុកជើងព្រៃ (ការជ្រើសរើសដោយមានការប្រកួតប្រជែង) ។ សកម្មភាពនេះគឺជាឧទាហរណ៍មួយនៃការផ្តល់អំណាចឲ្យអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍ ដោយមានសិស្សជាអ្នកផ្តួចផ្តើមគំនិតទាំងស្រុង ។





*ការជាវសម្ភារៈ និងការផ្គត់ផ្គង់គិលានដ្ឋានគ្រប់គ្រាន់ ។*

# កម្មវិធីអាហារពេលព្រឹក (SFP)
# កម្មវិធីអារូបករណ៍ជាស្បៀងសម្រាប់យកទៅផ្ទះ (THR)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | កម្មវិធីស្បៀងអាហារពិភពលោក (WFP) |
| អ្នកទទួលផលផ្ទាល់ | *SFP*: សិស្ស ៣៤.១៨២នាក់ (ស្រី ១៦.៥៨នាក់)<br>*THR*: សិស្ស ១៧.៤២០នាក់ (ស្រី ៩.២២៤នាក់)<br>អាហារូបករណ៍: សិស្ស ៣២៥នាក់ (ស្រី ១៨៨ នាក់) |
| បដិភាគទទួលក្នុងឆ្នាំ ២០១៣* | SFP: ៦២៧.៧៤៩,៤៥ ដុល្លាអាមេរិក<br>THR: ៨៧១.000,00 ដុល្លាអាមេរិក<br>អាហារូបករណ៍: ១៥.៦២៥,00 ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | SFP: ១៨ ដុល្លាអាមេរិកក្នុង១នាក់<br>THR: ៥0 ដុល្លាអាមេរិកក្នុង១នាក់<br>អាហារូបករណ៍: ៥0 ដុល្លាអាមេរិកក្នុង១នាក់ |
| ខេត្តគ្របដណ្តប់ | ១ ខេត្ត (កំពង់ចាម) |
| ចំនួនស្រុកគ្របដណ្តប់ | ១៧ |
| បឋមសិក្សាគោលដៅ | SFP: ៩៤ និង THR: ៥២២ |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | តុលា ២00២ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | មិថុនា ២០១៦ |

* *ទិន្នន័យតំណាងតម្លៃសាច់ប្រាក់ស្បៀងអាហារ និងផលិតផលដទៃទៀតគិតជាតោន ។*

**ចំនួនសិស្សរបស់កម្មវិធី SFP និង THR**
**ពីឆ្នាំ ២00៦ ដល់ ២០១៣**




អង្គការ ខេប ធ្វើការងារជាមួយកម្មវិធីស្បៀងអាហារពិភពលោក និងមន្ទីរអប់រំខេត្ត ដើម្បីគាំទ្រការតាមដាន និងការកសាងសមត្ថភាពចំពោះសាលារៀននៅក្នុងតំបន់អសន្តិសុខស្បៀងក្នុងខេត្តកំពង់ចាម ។ គម្រោងនេះមានសមាសភាព ២ គឺ: កម្មវិធីអាហារពេលព្រឹក (SFP) ដែលផ្តល់អាហារក្តៅពេលព្រឹកដល់បឋមសិក្សាចំនួន ៩៤ និងកម្មវិធីអាហារូបករណ៍ជាស្បៀងសម្រាប់យកទៅផ្ទះ (THR) ដែលបានដំណើរការដំសកម្មនៅសាលារៀនចំនួន ៦១៦ ។ កុមារនៃកម្មវិធី THR ជាកុមារនៅក្នុងគ្រួសារ រងគ្រោះបំផុតដែលមានកាន់ប័ណ្ណក្រីក្រចេញជូនដោយអាជ្ញាធរមូលដ្ឋាន ។ កម្មវិធី SFP និងកម្មវិធី THR ស្វែងរករបស់លើកទឹកចិត្តសម្រាប់ឱ្យកុមារ ទៅសាលា ក៏ដូចជា ការបង្កើននូវប្រសិទ្ធភាពចូលរៀនដោយកាត់បន្ថយ ភាពស្រេកឃ្លានពេលព្រឹក និងបង្កើនការយកចិត្តទុកដាក់របស់សិស្ស ។

កម្មវិធីបច្ចុប្បន្នបានបន្តវិវឌ្ឍឆ្ពោះទៅរកការផ្តោតអារម្មណ៍កាន់តែច្រើនថែមទៀតលើរបបរយកផ្ទះនិងការកាត់បន្ថយបន្តិចម្តងនៃការផ្តល់សេវាអាហារពេលព្រឹក ។ យើងអាចមើលឃើញតួរលេខពីការពង្រីកទំហំនៃកម្មវិធី THR មានរហូតជាង ៦00 សាលារៀនចាប់ពីឆ្នាំ ២0១១-២0១២មក និងមានការពង្រីកបន្ថែមទៀតនៅក្នុងឆ្នាំ ២0១៣ ។ ការផ្តល់រង្វាន់លើកទឹកចិត្តជាសាច់ប្រាក់ក្នុងឆ្នាំនេះ ត្រូវបង្ហាញបន្ថែមក្នុងកម្មវិធីអាហារូបករណ៍ស្បៀងសម្រាប់យកទៅផ្ទះ ។ អង្គការ ខេប បានបន្តបង្កើតបណ្តាញរវាងកម្មវិធីអាហារពេលព្រឹក និងកម្មវិធីអាហារូបករណ៍ជាស្បៀងសម្រាប់យកទៅផ្ទះជាមួយកម្មវិធីដទៃទៀតជាពិសេស ករណីគម្រោង IBEC ដែលបានសម្របសម្រួលឱ្យសិស្សទាំងនោះទទួលកម្មវិធីអាហារូបករណ៍ជាស្បៀងសម្រាប់យកទៅផ្ទះរួម និងអាហារូបករណ៍ដែលផ្តល់ជូនដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ។

## រូបភាពសកម្មភាពខ្លីៗ



*បុគ្គលិកកម្មវិធីស្បៀងអាហារពិភពលោកផ្ទៀងផ្ទាត់ឈ្មោះសិស្ស*





(ខាងឆ្វេង) និង (ខាងស្តាំ) សិស្សមានឱកាសសម្រាក់នៅសាលា នាំគ្នាសិក្សា និងបរិភោគអាហារពេលព្រឹកដ៏ឆ្ងាញ់រៀងរាល់ថ្ងៃសិក្សានៅសាលា ។

14

# គម្រោងសាលារៀនល្អប្រសើរ (SfE)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | Classroom of Hope (CoH) |
| អ្នកទទួលផលផ្ទាល់ | កុមារ ៥.០១៩ នាក់ (ស្រី ២.៣៤០នាក់) |
| ចំនួនអ្នកទទួលផលប្រយោលពីគម្រោង | ១០.១១៦ នាក់ (មាតាបិតា ១០.០៣៨ នាក់ គ្រូ ៦៣ នាក់ នាយកសាលា ១៥ នាក់) |
| ថវិកាប្រចាំឆ្នាំ ២០១៣ | ៥៨.៤៩៤,៤៥ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | ១១,៥ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | ១ ខេត្ត (កំពង់ចាម) |
| ចំនួនស្រុកគ្របដណ្តប់ | ១ ស្រុក (ក្រូចឆ្មារ) |
| បឋមសិក្សាគោលដៅ | ១៥ សាលាបឋម |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | តុលា ២០១២ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ កញ្ញា ២០១៥ |

គម្រោងសាលារៀនល្អប្រសើរ (SfE) ផ្តោតលើការបង្កើនការចូលរួម និងគុណភាពអប់រំកម្រិតបឋមសិក្សា ព្រមទាំងកសាងសមត្ថភាពអ្នកពាក់ព័ន្ធ ដើម្បីពង្រឹងការគ្រប់គ្រងសាលារៀន ។ គោលដៅទាំងនេះស្របទៅតាមគម្រោងផែនការអភិវឌ្ឍរបស់ក្រសួងអប់រំ យុវជន និងកីឡា (អយក) និងគោលនយោបាយកម្មវិធីសាលាកុមារមេត្រី ។

### ធាតុសំខាន់ៗនៃបច្ចេកទេសក្នុងការអនុវត្ត

ការអនុវត្តន៍ដោយផ្អែកលើសិទ្ធិជាមូលដ្ឋាន
ការផ្ទេរអំណាច
ភាពជាម្ចាស់ការក្នុងតំបន់
គម្រោងផែនការដែលអនុវត្តប្រកបដោយនិរន្តរភាព ។

គម្រោងសាលារៀនល្អប្រសើរ (SfE) ចាប់ផ្តើមនៅខែតុលា ឆ្នាំ ២០១២ និងបញ្ចប់នៅចុងខែកញ្ញា ឆ្នាំ ២០១៥ ។ គម្រោងនេះមានគោលបំណងដើម្បីបង្កើតសាលាកុមារមេត្រីដែលមានការដំណើរការយ៉ាងល្អប្រសើរនូវសមាសភាគមួយចំនួន ដូចជា បង្កើនគុណភាពអប់រំ ការគ្រប់គ្រង និងបង្កលក្ខណៈងាយស្រួលដល់កុមារជួបការលំបាក ជាពិសេស កុមារី កុមារក្រីក្រឱ្យអាចបញ្ចប់ការសិក្សាកម្រិតមូលដ្ឋាន និងលើកទឹកចិត្តឱ្យមានការចូលរួមពីមាតាបិតា សហគមន៍ និងអាជ្ញាធរមូលដ្ឋានផងដែរ ។



សិស្សមានជំនឿជាក់ខ្លួនឯង និងមានសេរីភាព និងពេលវេលាពង្រឹងគុណភាពអប់រំ និងបញ្ហាពាក់ព័ន្ធផ្សេងៗ ។

សកម្មភាពរបស់គម្រោង SfE មានដូចតទៅ៖ (១) សកម្មភាពកសាងសមត្ថភាពដល់ភាគីសាលារៀន (២) សកម្មភាពកែលម្អសាលារៀនតាមរយៈបញ្ជីសេវាកម្មសាលាកុមាមេត្រី ដោយប្រើប្រាស់កញ្ចប់ថវិកាអំណោយដល់សាលារៀន (៣) សម្របសម្រួលដល់សហគមន៍ អាជ្ញាធរមូលដ្ឋាន ដើម្បីបង្កើនការចូលរួមរបស់ពួកគេក្នុងការអប់រំ និងទី (៤) គឺការកសាងសមត្ថភាពអង្គការថ្មីមួយនៅខេត្តបាត់ដំបងគឺអង្គការអភិវឌ្ឍន៍សកម្មភាពកុមារ (CAD) នូវប្រព័ន្ធហិរញ្ញវត្ថុ ការគ្រប់គ្រងរដ្ឋបាល និងប្រព័ន្ធផ្តល់សេវាផ្សេងៗ ។

## សកម្មភាពសំខាន់ៗ

ការសាងផែនការអភិវឌ្ឍប្រចាំឆ្នាំ

ផែនទីសិក្សា និងអាហារូបករណ៍សម្រាប់កុមារក្រីក្រ ។

កុមារជួយកុមារៈផ្តោតលើសកម្មភាពកុមារធំជួយបង្រៀនកុមារតូច ។

បំប៉នបន្ថែមសម្រាប់សិស្សដែលមានតម្រូវការពិសេស ។

គាំទ្រកម្មវិធីសាលាកុមារមេត្រីសម្រាប់គ្រូក្នុងមូលដ្ឋាន និងក្រុមប្រឹក្សាកុមារ ដើម្បីបង្កើនការចូលរួម ។

មូលដ្ឋាននៃការបណ្តុះបណ្តាលគ្រូះដើម្បីប្រាកដថា គ្រូទទួលបានតម្រូវការផ្នែកបច្ចេកទេស ដើម្បីផ្លាស់ប្តូរ ការអនុវត្តនៅក្នុងថ្នាក់រៀនរបស់ពួកគេ ។

កម្មវិធីបំណិនជីវិតដែលផ្សារភ្ជាប់នឹងស្ថានភាពជាក់ស្តែងក្នុងមូលដ្ឋាន ។

បណ្តុះបណ្តាលភាពជាអ្នកដឹកនាំសម្រាប់នាយកសាលា និងសហ-គមន៍ ដើម្បីប្រាកដថាអ្នកពាក់ព័ន្ធមានជំនាញក្នុងការគ្រប់គ្រង និងត្រួតពិនិត្យថវិកាប្រកបដោយប្រសិទ្ធភាព។

អប់រំសុខភាព និងការថែទាំ ដើម្បីប្រាកដថាកុមារស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរផ្នែកសុខភាព ឬពិការទទួលបានការឧបត្ថម្ភ និងការព្យាបាល ។



<u>*មេរៀនកម្មវិធីបំណិនជីវិតៈ*</u> *សិស្សបឋមសិក្សាធ្វើការរួមគ្នា ក្នុងការថែទាំដំណាំនៅសួនច្បារក្នុងសាលារៀនរបស់ពួកគេ។*

# “ការអប់រំផ្តល់នូវក្តីសង្ឃឹមសម្រាប់អនាគត ”

## បច្ចុប្បន្នភាពគម្រោង

- ការវាយតម្លៃខាងក្រៅនៅចុងបញ្ចប់នៃគម្រោងតាមរយៈការជ្រាវស្រាវ ឯកសារ និងការធ្វើបទសម្ភាសន៍ ជាមួយអ្នកពាក់ព័ន្ធរបស់គម្រោងបានសន្និដ្ឋានថា គម្រោងនេះជាគម្រោងមួយដែលអនុវត្តប្រកបដោយប្រសិទ្ធភាព និងជោគជ័យ "ទឹកប្រាក់ដែលបានចំណាយលើគម្រោងជាទឹកប្រាក់ដែលមានតម្លៃ ” ។
- សមាជិកក្រុមប្រឹក្សាកុមារអាចធ្វើការឆ្លុះបញ្ចាំងអំពីដំណើរការសកម្មភាពរបស់ពួកគេនៅសាលានិងផ្តល់នូវអនុសាសន៍ដ៏មានប្រយោជន៍ដល់គ្រូ សាលារៀន និងអ្នកពាក់ព័ន្ធនៅក្នុងតំបន់ពួកគេ តាមរយៈការធ្វើបទបង្ហាញ។
- ក្រុមគាំទ្រផ្នែកបច្ចេកទេស (TSG) គណៈកម្មការទ្រទ្រង់ សាលា ប្រធានកម្រង នាយកសាលា និង ការិយាល័យអប់រំស្រុក (DOE) មានសមត្ថភាពខ្ពស់ ដើម្បីជួយលោកគ្រូ-អ្នកគ្រូ ព្រមទាំងវាយតម្លៃសាលារៀន និងគ្រូដោយប្រើឧបករណ៍វាយតម្លៃរបស់ក្រសួងអប់រំ យុវជន និងកីឡា ។
- នៅបំណាច់ឆ្នាំសិក្សា ២០១៣-២០១២៤អត្រាសិស្សគង់វង្សមាន ៩៧% និងសិស្សបោះបង់ការសិក្សាមាន ៤% ធៀបនឹងទិន្នន័យមូលដ្ឋានមាន ៩% (កាត់បន្ថយពី៩% មក ៤%)។

## រូបភាពសកម្មភាពខ្លីៗ



*កុមាររីករាយនឹងការលេងល្បែងសិក្សាក្នុងបណ្ណាល័យសាលារៀន*



*ក្រុមសិស្សអនុវត្តបំណិនជីវិតដាំស្លដោយក្រុមរបស់ពួកគេផ្ទាល់*

## Student Focus



*ចាន់ថេនរៀបចំខ្លួនស្រេចទៅសាលារៀន*

កុមារីចាន់ថេន គឺជាសិស្សដែលបានទទួលអាហារូបករណ៍នៅសាលារៀនដែលមានការគាំទ្រពីគម្រោងសាលារៀនល្អប្រសើរ (SfE) ជំនួយដោយអង្គការថ្នាក់រៀនមានសង្ឃឹម (CoH) ។ នាងរស់នៅក្នុងផ្ទះតូចមួយជាមួយនឹងឪពុកម្តាយរបស់នាង ដែលមានមុខរបរមិនទៀងទាត់ ដែលតែងតែពនេចររកការងារធ្វើតាមរដូវកាល ដើម្បីទទួលបានកម្រៃមកផ្គត់ផ្គង់គ្រួសារ ។ ចាន់ថេន រៀននៅថ្នាក់ទី៣ នៃសាលាបឋមសិក្សាភូមិពរកាខ្នុរ ។ នាងគឺជាសិស្សពូកែ មានការលើកទឹកចិត្ត ប៉ុន្តែ ពេលខ្លះនាងខកខានមិនបានទៅសាលាទេ ព្រោះនាងគឺជាកូនច្បងមានភារកិច្ចទទួលខុសត្រូវខ្ពស់ក្នុងការជួយធុរៈគ្រួសារ ដូចជាជួយចម្អិន និងរៀបចំអាហារ ព្រមទាំងមើលប្អូនតូចៗពេលម្តាយរបស់នាងមិននៅផ្ទះ ដោយទៅស៊ីឈ្នួលគេក្នុងការរកប្រាក់សម្រាប់ផ្គត់ផ្គង់គ្រួសារ ។

ក្រោយពីចាន់ថេនត្រូវបានទទួលអាហារូបករណ៍ដែលផ្តល់ឱ្យដោយគម្រោងមក នាងមកសាលារៀនយ៉ាងទៀងទាត់ជាមួយនឹងទឹកមុខញញឹម ។ នាងបាននិយាយថា: "*ឥឡូវនេះខ្ញុំលែងបារម្ភជាមួយសម្ភារៈសិក្សារបស់ខ្ញុំទៀតហើយ ព្រោះខ្ញុំត្រូវទទួលបានកញ្ចប់សម្ភារៈមួយចំនួនពីគម្រោងសាលារៀនល្អប្រសើរ*" ។ ខណៈពេលដែលកំពុងបំបៅកូននៅនឹងដៃ ម្តាយនាងតបថា: "*ខ្ញុំពិតជាសោកស្តាយក្នុងការឱ្យកូនស្រីរបស់ខ្ញុំខកខានទៅសាលារៀននៅពេលខ្លះ ដើម្បីជួយធ្វើការងារផ្ទះខណៈពេលដែលនាងខ្ញុំរវល់ ប៉ុន្តែខ្ញុំមិនមានជម្រើសនោះទេព្រោះខ្ញុំគ្មាននរណាក្រៅពីនាងដែលអាចជំនួសដៃជើងខ្ញុំបាន*" ។ គាត់បានបន្តទៀតថា "*ឥឡូវនេះមានសកម្មភាពគួរឱ្យចាប់អារម្មណ៍ជាច្រើននៅសាលារៀនដែលធ្វើឱ្យកម្មវិធីកាន់តែប្រសើរឡើង*" ។

ក្រោយពីកូនត្រូវបានទទួលអាហារូបករណ៍ ឪពុកម្តាយរបស់ ចាន់ថេន មានការផ្លាស់ប្តូរគំនិតរបស់ពួកគេអំពីការធ្វើចំណាកស្រុកពីកន្លែងមួយទៅកន្លែងមួយក្នុងការស្វែងរកការងាររកកម្រៃ ។ លើសពីនេះទៅទៀត គាត់ទាំងពីរសប្បាយរីករាយជាមួយនឹងលទ្ធផលល្អកូនស្រីរបស់ពួកគេនៅក្នុងការសិក្សា ។ ពីមុន ចាន់ថេន ខកខានទៅសាលារៀនជាញឹកញាប់ដោយសារឪពុកម្តាយរបស់នាងត្រូវការនាងជួយកិច្ចការមួយចំនួននៅផ្ទះ ប៉ុន្តែក្រោយមកពួកគាត់មានការយល់ពីការសិក្សាកូន ដោយកូនគាត់ទទួលបានការគាំទ្រពីគម្រោង ដូច្នេះ ពួកគេមិនចាំបាច់ត្រូវចំណាយពេលច្រើននៅលើកូនរបស់ខ្លួនទៀតទេ។

ចំពោះចាន់ថេនវិញមានការផ្លាស់ប្តូរច្រើនក្នុងជីវិតសិក្សារបស់នាង គ្រូបន្ទុកថ្នាក់របស់នាង និងនាយកសាលារាយការណ៍ថា នាងទៅរៀនទៀងទាត់ទោះបីជាឪពុកម្តាយរបស់នាងរវល់ក៏ដោយ លើសពីនេះទៀត នាងលែងមានសម្ពាធពីឪពុកម្តាយរបស់នាងឱ្យស្នាក់នៅផ្ទះទៀតហើយ។ នាងនឹងត្រូវបានចូលរួមជាសមាជិកក្រុមប្រឹក្សាកុមារប្រចាំសាលា ។



*កុមារីចាន់ថេនទទួលកញ្ចប់អាហារូបករណ៍*

# កម្មវិធីអប់រំបញ្ចូលគ្នា (IEP)

កម្មវិធីអប់រំបញ្ចូលគ្នា (IEP) គឺជាការបញ្ចូលកម្មវិធីតូចៗមួយចំនួនដែលមានម្ចាស់ជំនួយចំនួន ៤ និងមាន ៣គម្រោង ។ គោលបំណងកម្មវិធីនេះ គឺដើម្បីបង្កើនភាពងាយស្រួលក្នុងការអប់រំ ជាពិសេសគឺស្ត្រី ជនជាតិភាគតិច និងកុមារ/យុវជនដែលងាយរងគ្រោះ និងរងផលប៉ះពាល់ដទៃទៀត ។ កម្មវិធី IEP ជួយកុមារ និងយុវជននៅកម្រិតបឋមសិក្សាតាមរយៈកម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញដទៃទៀត ។ IEP ត្រូវបង្កើតឡើងជាកម្មវិធីអប់រំបញ្ចូលគ្នា ដើម្បីកាត់បន្ថយចំណាយផ្សេងៗ និងចំណេញពេលវេលា ដោយមានអ្នកសម្របសម្រួលតែម្នាក់គ្រប់គ្រងគម្រោងទាំងអស់នោះ។

**IEP**

- គម្រោងអប់រំកុមារី (GEI)
- គម្រោងអប់រំជនជាតិពួង (PEI)
- គម្រោងអាហារូបករណ៍សិស្សនៅសាកលវិទ្យាល័យ (CTSP)

| | GEI | PEI | CTSP |
|---|---|---|---|
| ម្ចាស់ជំនួយ | អង្គការ *Terre des Hommes* & មូលនិធិ *Oaktree* | អង្គការ *Lotus Outreach* | អង្គការមូលនិធិអាស៊ី |
| ថវិកាប្រចាំឆ្នាំ ២០១៣ | **១៣៨.៨៦០ ដុល្លាអាមេរិក** | **២២.៦០៥ ដុល្លាអាមេរិក** | **១០២.៨០៧ ដុល្លាអាមេរិក** |
| អ្នកទទួលផលផ្ទាល់ | សិស្សអាហារូបករណ៍ ៧០៦ នាក់ (ស្រី ៥១០នាក់)<br>សិស្សអាហារូបករណ៍វិជ្ជាជីវៈ ៥នាក់ (ស្រី)<br>សិស្សរៀនជំនាញអាជីព ៩០នាក់ (ស្រី ៦៦នាក់)<br>មាតាបិតាសិស្ស ៤០នាក់ ទទួលផលពីកម្មវិធី បំណិនផ្ទាល់ខ្លួន (គ្រួសារសិស្សស្រី ២៩ នាក់)<br>សិស្សកម្មវិធីបំណិនជីវិត ១៥០នាក់ (ស្រី ៩៥នាក់)<br>សមាជិកក្រុមប្រឹក្សាកុមារ ៨៨នាក់(ស្រី ៦៥នាក់)<br>សិស្ស ៨៥ នាក់ (ស្រី ៦៨នាក់) បានចូលរួមសកម្មភាពវិស្សមកាល<br>**សរុបៈ ១.១៦៤ នាក់ (ស្រី ៨៣៨នាក់)** | សិស្សអាហារូបករណ៍ពួង ៣១ នាក់ (ស្រីទាំងអស់)<br>អាហារូបករណ៍គរុសិស្សពួង ២០ នាក់ (ស្រីទាំងអស់)<br>សិស្សកម្មវិធីបំណិនជីវិតផ្នែកវប្បធម៌ ៣០នាក់ - (ស្រី ១៩នាក់)<br>សិស្សស្រាវជ្រាវជនជាតិពួង ២២ នាក់ (ស្រី ១៤នាក់)<br>មណ្ឌលវប្បធម៌ ១<br>**សរុបៈ ១០២ នាក់ (ស្រី ៨៤នាក់)** | និស្សិតសាកលវិទ្យាល័យ ១១៤ នាក់ (ស្រីទាំងអស់)<br>ការអភិវឌ្ឍអាជីពៈ<br>ថ្នាក់ភាសាអង់គ្លេស<br>វគ្គសិក្សាកុំព្យូទ័រ<br>វគ្គបណ្តុះបណ្តាលខ្លីៗ<br>**សរុបៈ ១១៤ នាក់ (ស្រី ទាំងអស់)** |
| ចំនួនសាលា | ១៤ អនុវិទ្យាល័យ<br>៥ វិទ្យាស្ថានដទៃទៀត (សាលាគរុកោសល្យ និងវិក្រឹតការខេត្ត សាលាគរុកោសល្យ ភូមិភាគ, គិលានុបដ្ឋាយិកា បច្ចេកវិទ្យា និងសាលាកសិកម្ម) | ២ អនុវិទ្យាល័យ<br>១ សាលាគរុកោសល្យ និងវិក្រឹតការ | ១ សាកលវិទ្យាល័យ (សាកលវិទ្យាល័យ វេស្ទើន) |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | ១១៨ ដុល្លាអាមេរិក | ២២២ ដុល្លាអាមេរិក | ៩០២ ដុល្លាអាមេរិក |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | សីហា ២០០០ | មករា ២០១០ | វិច្ឆិកា ២០១០ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | កំពុងបន្ត | កំពុងបន្ត | កញ្ញា ២០១៥ |

*កម្មវិធីអប់រំបញ្ចូលគ្នា គឺជាកម្មវិធីមួយមានលក្ខណៈប្លែកដែលឱ្យតម្លៃខ្ពស់ទៅលើការបន្តអនុវត្តកម្មវិធី ។ អង្គការ ខេប មានមោទនភាពខ្លាំងចំពោះកម្មវិធីនេះ ដែលមិនត្រឹមតែផ្តល់នូវការគាំទ្ររយៈពេលខ្លីសម្រាប់សិស្សដែលងាយរងគ្រោះក្នុងការអប់រំប៉ុណ្ណោះទេ ប៉ុន្តែ កម្មវិធីនេះបានធ្វើការជាមួយកុមារតាមរយៈការពង្រីកវដ្តអប់រំ ។ វាក៏ជាមូលហេតុដែលធ្វើឱ្យគម្រោងអាហារូបករណ៍សិស្សនៅសាកលវិទ្យាល័យកើតឡើងដែរ ដោយរាប់បញ្ចូលយុវជនដែលងាយរងគ្រោះជាច្រើន ដែលបានចាប់ផ្តើមទទួលការគាំទ្រពីអង្គការ ខេប កំឡុងពេលពួកគេរៀននៅបឋមសិក្សា និងមធ្យមសិក្សា កាលពី១០ឆ្នាំកន្លងទៅ ។ អង្គការ ខេប បានជួយកុមារទាំងអស់នេះជោគជ័យតាមរយៈការផ្តល់អាហារូបករណ៍ ដោយធានាថា កម្មវិធីពិតជាត្រូវបង្កើតឡើងនូវ "ការផ្លាស់ប្តូរជីវិត" បុគ្គលម្នាក់ៗ ដែលបច្ចុប្បន្ននេះគឺជាបុរស និងស្ត្រីវ័យក្មេង ។*



*The students display their paintings at school.*

## គម្រោងអប់រំកុមារី (GEI)

គម្រោងអប់រំកុមារី (GEI) បានចាប់ផ្ដើមនៅឆ្នាំ ២000 ហើយដែលជាគម្រោងមានរយៈពេលយូរជាងគេបំផុតក្នុងសកម្មភាពផ្ដល់អាហារូបករណ៍របស់អង្គការខេប (ប្រហែលជាមានតែនៅកម្ពុជា) ដែលមានគោលបំណងបង្កើន ចំនួនកុមារ ជាពិសេសក្មេងស្រី ឱ្យបានចូលរួមក្នុងការអប់រំនៅតាមសាលារបស់ពួកគេ ។ ដូច្នេះ ពួកគេអាចចែករំលែកក្នុងសង្គមតាមសមត្ថភាពរបស់ពួកគេ ។

## បច្ចុប្បន្នភាពគម្រោង

នៅក្នុងឆ្នាំ ២០១២-១៣ មានសិស្សទទួលអាហារូបករណ៍សរុបចំនួន ៧០៦នាក់ ដោយមានអត្រាបោះបង់ការសិក្សា ៦% បើប្រៀបធៀបទៅនឹងអត្រាបោះបង់ការសិក្សា ៧% នៅក្នុងឆ្នាំ ២០១១-២០១២ ។

ការបណ្ដុះបណ្ដាលជំនាញចិញ្ចឹមជីវិតដល់គ្រួសារចំនួន ៤០ ឱ្យឈានទៅបង្កើនប្រាក់ចំណូលគ្រួសារបាន ៨៥% និង ១០០%នៃគ្រួសារទាំងអស់បច្ចុប្បន្ននេះ បានផ្ដល់ជាប្រាក់សុទ្ធ និងជំនួយសម្រាប់ការសិក្សារបស់កូនចៅពួកគេ ។

ចំនួន ៣២% នៃសិស្សអាហារូបករណ៍រៀនជំនាញចំនួន ៩០នាក់បានបញ្ចប់វគ្គសិក្សា និងបានប្រឡូកក្នុងការងារពិតប្រាកដ ។ សិស្សដែលមិនបានបញ្ចប់កំពុងបានបន្តការសិក្សាក្នុងឆ្នាំទី ២របស់ពួកគេ ។

ចំនួន ១០០%នៃសិស្សវិជ្ជាជីវៈទាំង៥នាក់ (រៀនដេរ) បានបញ្ចប់ការសិក្សា ហើយបច្ចុប្បន្ននេះកំពុងធ្វើការនៅក្នុងវិស័យកាត់ដេរ ។



*សិស្សគម្រោងអប់រំកុមារីសិក្សាកម្មវិធីបំណិននៅសួនជីវៈសាលារបស់ពួកគេ*



*គ្រួសារដែលដាក់ចំណីជ្រូកនេះបានទទួលការគាំទ្រសកម្មភាពលើកស្ទួយគ្រួសារ*

## សកម្មភាពគម្រោង



*សិស្សបានថ្លែងអំណរគុណម្ចាស់ជំនួយ និងអង្គការ ខេប ដែលបានផ្ដល់អាហារូបករណ៍ដល់ពួកគេ ដូចជា កង់ សំលៀកបំពាក់ និងសម្ភារៈសិក្សា ដើម្បីមានឱកាសបន្តការសិក្សាដោយគ្មានបញ្ហាលំបាក ។*

## ក្ដីសុបិន្តកុមារី

សៅ រី មានអាយុ ២១ឆ្នាំ ជាគរុសិស្សបឋមឆ្នាំទី២ កំពុងរៀននៅសាលាគរុកោសល្យ និងវិក្រឹតការក្នុងក្រុងកំពង់ចាម ។ នាងមកពីគ្រួសារកសិករមួយ និងមានដីតូចល្មមសម្រាប់មុខរបរកសិកម្ម និងជួយកិច្ចការផ្ទះ ។ បងប្រុស និងបងស្រីរបស់នាង ៣នាក់ទៀតបានឈប់រៀនតាំងពីបឋមសិក្សា ។ នាងស្រលាញ់ការអប់រំណាស់ និងប្រាថ្នាចង់បានការងារធ្វើល្អមួយ ។

រី បានចាប់ផ្ដើមចូលសាលារៀននៅពេលនាងមានអាយុ ៨ឆ្នាំ ហើយឪពុកនាងមិនបានខ្វាយខ្វល់បញ្ជូនកូនទៅសាលារៀនទេ សូម្បីតែខ្លួនគាត់ក៏មិនដែលរៀនអាន ឬសរសេរដោយខ្លួនឯងឡើយ ។ ដោយមានតម្រូវការច្រើននៅក្នុងគ្រួសាររបស់នាង ធ្វើឱ្យការអប់រំមិនមែនជាអាទិភាពទេ ។ ទោះបីជាយ៉ាងណាក៏ដោយ សៅ រី បានសម្រេចប្ដេជ្ញាចិត្តខ្ពស់ថា នាងត្រូវការទទួលការអប់រំ ។

សៅ រី បាននិយាយដោយប្ដេជ្ញាចិត្តខ្លាំងថា *“ខ្ញុំនឹងបញ្ចប់ការសិក្សានៅខែកក្កដា ឆ្នាំ២០១៤ ។ ខ្ញុំពិតជាចង់ទៅសហគមន៍របស់ខ្ញុំវិញដើម្បីបង្រៀនកុមារជាច្រើនដែលព្យាយាមចង់បានការអប់រំដូចខ្ញុំដែរ និងជួយពួកគេឱ្យចេះធើបឈរ និងសម្រេចក្ដីសុបិន្ត និងគោលដៅពួកគេ ដូចខ្ញុំកំពុងធ្វើ ។ ខ្ញុំសង្ឃឹមថា ការអប់រំដ៏ល្អនេះបានបង្រៀនខ្ញុំឱ្យក្លាយទៅជាមនុស្សល្អ និងចេះវិភាគបញ្ហា ។ ខ្ញុំនឹងព្យាយាមឱ្យអស់ពីសមត្ថភាពដើម្បីធ្វើជាគ្រូដ៏ល្អម្នាក់តាមដែលខ្ញុំអាចធ្វើបាន និងដើរតួគំរូក្នុងសហគមន៍របស់ខ្ញុំ”*។



*សៅ រី នៅសាលាគរុកោសល្យ*

# “ការរួចផុតពីគុណវិបត្តិតាមរយៈការអប់រំ ”

## គម្រោងអប់រំជនជាតិព្នង (PEI)

គម្រោងអប់រំជនជាតិព្នង (PEI) ឧបត្ថម្ភដោយអង្គការ Lotus Outreach អន្តរជាតិ បានអនុវត្តការងាររបស់ខ្លួន ក្នុងខេត្តមណ្ឌលគិរីតាំងពីខែមករា ឆ្នាំ២០១០។ គម្រោងនេះមានអាយុកាល៣ឆ្នាំហើយ ។ ការបង្កើតគម្រោងនេះឡើងមានបំណង (១) កាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្សព្នងកម្រិតអនុវិទ្យាល័យ (២) បង្កើនអត្រាចូលរៀនរបស់កុមារីកម្រិតថ្នាក់ទី ៧ ដល់ទី ៩ និង (៣) អន្តរាគមន៍សិស្សព្នងកំពុងសិក្សានៅសាលាគរុកោសល្យ និងវិក្រិតការខេត្តស្ទឹងត្រែង រយៈពេល ២ឆ្នាំ ។


ក្រុមប្រឹក្សាកុមារធ្វើធុងសម្រាមនៅសាលាអូរាំង ។


សិស្សអាហារូបករណ៍ហ្វឹកហ្វឺនសម្តែងល្បាំវប្បធម៌ ។


សិស្សអាហារូបករណ៍បង្ហាញអំពីសម្ភារក្នុងមណ្ឌលវប្បធម៌ ។

## បច្ចុប្បន្នភាពគម្រោង

សិស្សអាហារូបករណ៍ស្រីជនជាតិព្នងចំនួន៣១នាក់ ទទួលកញ្ចប់អាហារូបករណ៍ ដូចជា  សម្លៀកបំពាក់ សៀវភៅ ប៊ិច សម្ភារគណិតវិទ្យា ស្បែកជើង១គូ ប្រាក់ឧបត្ថម្ភប្រចាំខែ ប្រាក់ព្យាបាលសង្គ្រោះបន្ទាន់ និង វគ្គបណ្តុះបណ្តាលខ្លី ។

៩៧% នៃសិស្សសរុបចំនួន៣១នាក់បានប្រលងជាប់ ។ ក្នុងនោះសិស្សស្រី៨នាក់ បានប្រលងជាប់ចូលរៀននៅសាលាគរុកោសល្យ និងវិក្រឹតការ ខេត្តស្ទឹងត្រែង រយៈពេល២ឆ្នាំ ពីខែធ្នូ ២០១៣ ដល់ខែមិថុនា ឆ្នាំ២០១៥ ។ ក្រោយពេលបញ្ចប់ការសិក្សា ពួកគេនឹងក្លាយជាគ្រូបឋម និងមត្តេយ្យ ។

៩៤% នៃគរុសិស្សស្រីសរុបចំនួន១៦នាក់បានបញ្ចប់វគ្គបណ្តុះបណ្តាលគ្រូ នៅសាលាគរុកោសល្យ និងវិក្រឹតការខេត្ត។ បច្ចុប្បន្ននេះពួកគាត់ជាគ្រូបឋមសិក្សាក្នុងខេត្តមណ្ឌលគិរី ។ ទាំងនេះជាសមិទ្ធិផលដ៏សំខាន់ ក្នុងការបង្កើនចំនួនគ្រូបង្រៀនជនជាតិព្នងក្នុងវិស័យអប់រំ ។

កម្មវិធីបំណិនជីវិតផ្នែកវប្បធម៌បង្កើនយល់ដឹងសិស្សនូវអត្ថប្រយោជន៍វប្បធម៌ជនជាតិព្នង ដូចជា ត្បាញក្រម៉ា ធ្វើជៀល ផលិតស្រាពាង ។ ៩២% នៃសិស្សក្នុងកម្មវិធីយល់ដឹងពីវប្បធម៌ជនជាតិព្នងបានយ៉ាងល្អ។


សិស្សអាហារូបករណ៍រៀនកុំព្យូទ័រនៅពេលទំនេរ ។


សិស្សធ្វើយុទ្ធនាការស្តីពីការអប់រំ

# “ការរួចផុតពីគុណវិបត្តិតាមរយៈការអប់រំ ”

## គម្រោងអាហារូបករណ៍សិស្សនៅសាកលវិទ្យាល័យ (CTSP)

គម្រោងអាហារូបករណ៍សិស្សនៅសាកលវិទ្យាល័យ (CTSP) គឺជាគំនិតផ្តួចផ្តើមថ្មីតាមរយៈអង្គការ ខេប និងអង្គការមូលនិធិអាស៊ី ក្នុងឆ្នាំសិក្សា ២០១០-២០១១ ។ គម្រោងនេះជួយស្ត្រីវ័យក្មេងដែលបានបញ្ចប់ការសិក្សាពីវិទ្យាល័យឱ្យមានឱកាសបន្តការសិក្សាកម្រិតបរិញ្ញាប័ត្រនៅសាកលវិទ្យាល័យក្នុងតំបន់ ។ គម្រោង CTSP ចាប់ផ្តើមគាំទ្រដល់និស្សិតអាហារូបករណ៍ចំនួនពីរជំនាន់ សរុប ១១៤នាក់ (ជំនាន់ទី១ ៦៥នាក់ និងជំនាន់ទី២ ៤៩នាក់) ឱ្យបានចូលរៀននៅសាកលវិទ្យាល័យ វេស្ទើន ក្នុងខេត្តកំពង់ចាម ។ ភាគច្រើននៃនិស្សិតទាំងអស់នេះគឺអតីតសិស្សអាហារូបករណ៍របស់អង្គការ ខេប នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាពីមុន ។ អង្គការ ខេប មិនគ្រាន់តែគាំទ្រការសិក្សាប៉ុណ្ណោះទេ ប៉ុន្តែ ក៏មានទំនាក់ទំនងដ៏សកម្មជាមួយវិស័យឯកជនដើម្បីជ្រើសរើសនិស្សិតទាំងនេះឱ្យចូលធ្វើការផងដែរ ។ មិនតែប៉ុណ្ណោះ ក៏នៅមានការផ្តល់ការងារស្ម័គ្រចិត្តពីគម្រោងផ្សេងៗរបស់អង្គការ ខេប ផងដែរ ដើម្បីផ្តល់ឱ្យពួកគេមានបទពិសោធន៍បន្ទាប់ពីបញ្ចប់ការសិក្សា ។

### សកម្មភាពសំខាន់ៗ

សិក្សារយៈពេល៤ឆ្នាំនៅសាកលវិទ្យាល័យ
ការរៀបចំប្រជុំប្រចាំខែ
ការសិក្សាតាមក្រុមមុខវិជ្ជា
សិក្ខាសាលាស្តីពីការអភិវឌ្ឍអាជីពគឺផ្តោតទៅលើ:
- ភាពជាអ្នកដឹកនាំ ការលើកទឹកចិត្ត
- ជំនាញទំនាក់ទំនង
- ការស្វែងយល់ការងារស្ម័គ្រចិត្ត
- ទស្សនកិច្ចសិក្សា
- ការបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មាន
- ជំនាញភាសាអង់គ្លេស

### ការផ្តោតលើនិស្សិត CTSP



**ឈុន សុផា** ជានិស្សិតឆ្នាំទី៤ជំនាញគណនេយ្យ និងសេដ្ឋកិច្ច នៅសាកលវិទ្យាល័យ វេស្ទើន បានជាប់ការងារជាគណនេយ្យករនៅ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និរន្ត ក្នុងក្រុងកំពង់ចាម ដែលនៅក្បែរអន្ទេវា  សិកដ្ឋានសាកលវិទ្យាល័យដោយគ្រាន់តែចំណាយជិះកង់រយៈពេល១០នាទីប៉ុណ្ណោះ ។ នាង បានធ្វើការចាប់តាំងពីខែកក្កដា ឆ្នាំ២០១៣មក ។ នាងធ្វើការពីថ្ងៃច័ន្ទដល់សុក្រ បន្ទាប់មកនាងទៅរៀននៅសាកលវិទ្យាល័យ នាចុងសប្តាហ៍ ។ នាងទទួលបាន ប្រាក់ខែ១៧០ដុល្លាសហរដ្ឋអាមេរិកក្នុង។ អ្នកធ្វើការជាមួយនាងបាននិយាយថា *“សុផាគឺជាសមាជិកបុគ្គលិកឧស្សាហ៍ធ្វើការងារដ៏សកម្ម”* ។ សុផាមកពីគ្រួសារក្រមួយ ដូច្នេះ លទ្ធផលនាងទទួលបាននេះគឺមានតម្លៃណាស់ ចំពោះគ្រួសាររបស់នាង ។

### សញ្ញាប័ត្រទទួលបាន

និស្សិតអាហារូបករណ៍គម្រោង CTSP បានជ្រើសមុខជំនាញខាងក្រោម ដែលមានបង្រៀននៅសាកល វិទ្យាល័យ វេស្ទើន ដូចជា៖
- ហិរញ្ញវត្ថុ និងធនាគារ
- គណនេយ្យ
- ការគ្រប់គ្រង
- ទីផ្សារ និង
- អក្សរសាស្ត្រអង់គ្លេស ។




**ឡាក់ សាមឌី** រស់នៅជាមួយឪពុកម្តាយក្នុងផ្ទះចាស់នៅលើកោះតូចមួយ និងមានប្អូនប្រុសពីរនាក់ ។ គ្រួសារ នាងមានបញ្ហាប្រឈមសុខភាពដោយសារឪពុកនាងងងឹតភ្នែកមួយចំហៀង ម្តាយនាងពកក ហើយប្អូនប្រុស ម្នាក់គថ្លង់ ។ សាមឌីជានិស្សិតអាហារូបករណ៍កំពុងសិក្សាបរិញ្ញាប័ត្រផ្នែកគណនេយ្យរយៈពេល៤ឆ្នាំនៅសាកលវិទ្យាល័យ វេស្ទើន។ វាមិនជារឿងចម្លែកទេ ដែលនាងអាចដឹកនាំក្លិបគណនេយ្យបានពីព្រោះនាងមានទេពកោសល្យពីកំណើត ពូកែខាងគិតលេខ ។ សាមឌីសង្ឃឹមថា នាងនឹងក្លាយទៅគណនេយ្យករម្នាក់ក្នុង ធនាគារនៅថ្ងៃណាមួយជាក់ជាមិនខាន ។





ការផលិតព្រឹត្តិប័ត្ររបស់ក្រុមស្ត្រីដើម្បីបច្ចេកវិទ្យា




និស្សិតអាហារូបករណ៍ CTSP បានទៅទស្សនកិច្ចសិក្សានៅធនាគារ



និស្សិតអាហារូបករណ៍បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រើកាំមេរា និងការកំណត់គោលដៅ

# 20 គម្រោងសាលារៀនមានបំណិនជីវិតពេញបរិបូណ៌ (SELLS)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | Aflatoun/ ធនាគារ Barclay |
| អ្នកទទួលផលផ្ទាល់ | ៣.៣៣៨ (ស្រី ៣.០៤១ នាក់) |
| ថវិកាទទួលបានពីឆ្នាំ ២០១២ | ៦០.០០០ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | ១៨ ដុល្លារអាមេរិក |
| ចំនួនខេត្តគ្របដណ្តប់ | ២ ខេត្ត (ក្រចេះ និងកំពង់ចាម) |
| សិក្សាគោលដៅ | ១៨ សាលា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | តុលា ២០១០ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ធ្នូ ២០១៣ |

**គម្រោងSELLSមានគោលបំណងលើកកម្ពស់សិទ្ធិអំណាចកុមារដើម្បីក្លាយជាអ្នកផ្លាស់ប្តូរ និងជួយពង្រឹងគុណភាពជីវិតពួកគេផ្ទាល់ការរស់នៅផ្ទាល់ខ្លួន និងការរស់របស់អ្នកដទៃ ។**

គម្រោង SELLS ផ្តល់កម្មវិធីការសិក្សាផ្នែកហិរញ្ញវត្ថុនៅសាលាចំនួន ១០ ក្នុងខេត្តក្រចេះ ។ គម្រោងនេះចាប់ផ្តើមនៅក្នុងឆ្នាំ ២០០៩ ។ នៅក្នុងឆ្នាំ ២០១២-១៣ អង្គការ ខេប បានទទួលមូលនិធិបន្ថែមពីធនាគារ Barclay ដើម្បីអនុវត្តកម្មវិធីអាហ្វឡាទីនថ្មីដែលផ្តោតលើកម្មវិធីអប់រំផ្នែកសង្គម និងហិរញ្ញវត្ថុរបស់កុមារ ដែលចុះឈ្មោះចូលរៀនកម្រិតអនុវិទ្យាល័យ មកពីស្រុកចំនួន៥ ក្នុងខេត្តកំពង់ចាម ។ កម្មវិធីអាហ្វឡាទីនថ្មីបង្កើនការយល់ដឹងអំពីសិទ្ធិរបស់ពួកគេដែលមាន ចែងនៅក្នុង*សន្ធិសញ្ញាស្តីពីសិទ្ធិកុមាររបស់ អង្គការសហប្រជាជាតិ* និងផ្តល់អំណាចដល់ពួកគេក្នុងការទាមទារសិទ្ធិរបស់ខ្លួន។ បន្ថែមពីនេះទៀត កុមារទទួលបានឱកាសសិក្សាក្នុងការធ្វើផែនការថវិកា សន្សំ និងការចំណាយធនធាន ។ គម្រោងនេះមានបង្កើតជាក្លឹបអាហ្វឡាទូន ដែលកុមារអាចប្រើចំណេះដឹងដើម្បីរៀបចំយុទ្ធនាការសង្គម និងរៀបចំហិរញ្ញវត្ថុដើម្បីបង្កើតសហគ្រាសខ្នាតតូច ។

## សកម្មភាពសំខាន់ៗ

- បណ្តុះបណ្តាលសមត្ថភាពគ្រូបង្រៀនផ្នែកហិរញ្ញវត្ថុ
- បញ្ជ្រាបកម្មអាហ្វឡាទីនក្នុងកម្មវិធីសិក្សាដើម្បីលើកកម្ពស់ការអប់រំផ្នែកហិរញ្ញវត្ថុ
- ក្លឹបសិស្សអាហ្វឡាទីន
  - ® សហគ្រាសខ្នាតតូច
  - ® គំនូរ/សិល្បៈ
  - ® បំណិនជីវិត
- ការសន្សំផ្លូវការ និងក្រៅផ្លូវការ
- ការបើកគណនីសន្សំនៅធនាគារ
- តស៊ូមតិឱ្យមានការអប់រំផ្នែកហិរញ្ញវត្ថុក្នុងកម្មវិធីថ្នាក់ជាតិ (សៀវភៅ ៣ ក្បាលត្រូវបានអនុម័ត)។




## ករណីសិក្សា



វ៉ាន់ សុខណេង រៀនថ្នាក់ទី ១០ នៅវិទ្យាល័យ ស្រេង គីម បានចូលរួមកម្មវិធីអាហ្វឡាទីន ។ នាងរៀនអំពីការសន្សំ និងការចំណាយ និងមានផែនការរៀននៅសាកលវិទ្យាល័យ ។ ឥឡូវនាងបានបើកគណនេយ្យធនាគារមួយនៅក្នុងតំបន់ ។ មកដល់ឥឡូវនាងសន្សំបាន ២២០.០០០រៀល ស្មើនឹង ៥៥ ដុល្លាអាមេរិក ។ នាងបាននិយាយថា "*នាងខ្ញុំពិតជាសប្បាយណាស់ដែលមានគណនីផ្ទាល់ខ្លួនជាលើកដំបូងក្នុងជីវិតរបស់ខ្ញុំ*" ។



*សិស្សដាំត្រកួននៅសាលារៀន និងអាចលក់លើទីផ្សារ ឬក្នុងសហគមន៍បាន ។*



*ឪពុកឧបត្ថម្ភកូនស្រីគាត់ឱ្យបើកគណនេយ្យធនាគារក្រោមកម្មវិធីអាហ្វឡាទីន ។*



*ក្រុមសិស្សជួយខ្លួនឯងនៅវិទ្យាល័យ គ័រ*



*សិស្សចូលរួមកម្មវិធីបោះជំរុំ (ស្ត្រីដឹកនាំពិភពលោក)*

# គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀន តាមរយៈការគាំទ្រពីសហគមន៍ (REACH)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | Intervita |
| ដៃគូ (បានធ្វើកិច្ចព្រមព្រៀង) | អង្គការវឌ្ឍនភាព (WP); Ciai |
| អ្នកទទួលផលផ្ទាល់ | សិស្សបឋម: ៩.៧៥២ នាក់ (ស្រី ៤.៦០១ នាក់)<br>សិស្សមធ្យម: ៣៩៦ នាក់ (ស្រី ២១៦ នាក់)<br>គ្រូបឋមសហគមន៍: ១០ នាក់<br>គ្រូមធ្យមសហគមន៍: ២២ នាក់<br>ក្រុមគាំទ្របច្ចេកទេស: ២៨ នាក់<br>គ្រូ នាយក និងនាយករង: ១៧៤ នាក់ (ស្រី ៤១នាក់)<br>សិស្សអាហារូបករណ៍: ៣៦០ នាក់ (ស្រី ១៨០ នាក់)<br>គ្រួសារសិស្សអាហារូបករណ៍: ១០០ គ្រួសារ<br>បណ្តាញសហគមន៍គាំពារកុមារ: ៣៤ នាក់<br>ក្លឹបកុមារ: ១៨ នាក់ |
| ថវិកាទទួលបានពីឆ្នាំ ២០១២ | ១៦៩.០៧៩,៤៩ យូរ៉ូ (២០១.១៣៩,៧៤ដុល្លាអា.) |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | ២១,១៩ ដុល្លាអាមេរិក |
| ចំនួនខេត្តគ្របដណ្តប់ | ២ ខេត្ត (ព្រៃវែង និងស្វាយរៀង) |
| ចំនួនស្រុកគ្របដណ្តប់ | ៤ ស្រុក (៣ នៅស្វាយរៀង និង ១ នៅព្រៃវែង) |
| សិក្សាគោលដៅ | បឋមសិក្សា: ២៥ សាលា និង មធ្យម: ១២ សាលា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | កក្កដា ២០១២ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | មិថុនា ២០១៥ |

គោលបំណងគម្រោងរីកចម្បង គឺដើម្បីបង្កើនភាពងាយស្រួលចូលសាលារៀន និងកាត់បន្ថយការបោះបង់ការសិក្សាក្នុងចំណោមកុមារងាយរងគ្រោះ ដោយបង្ហាញអំពីឱនភាពគុណភាពអប់រំ និងការកែលម្អលក្ខខណ្ឌសេដ្ឋកិច្ចសង្គមគ្រួសារ ដូច្នេះ ពួកគេអាចផ្តល់បរិស្ថានសុវត្ថិភាព ដែលអាចធ្វើឱ្យកុមារចូលរៀនបានពេញលេញ ។

ដោយសារតែតម្រូវការចាំបាច់ក្នុងការចិញ្ចឹមជីវិត ដូច្នេះឪពុកម្តាយអាចបញ្ឈប់ការសិក្សារបស់កូនដើម្បីទៅរកប្រាក់ចំណូលបន្ថែមបន្តិចបន្តួច។ ដោយធ្វើចំណាកស្រុកទៅក្រៅប្រទេសដើម្បីរកការងារធ្វើ ដែលជាកត្តាធ្វើឱ្យមានសិស្សអវត្តមានច្រើន ហើយបណ្តាលឱ្យមានអត្រាឡើងថ្នាក់ទាប។ ទោះបីជាកុមារទាំងនោះបានវិលត្រឡប់មកសាលារៀនវិញក៏ដោយ ពួកគេជាញឹកញាប់មានការលំបាក និងមិនយល់ពីមេរៀនដែលពួកគេមិនបានរៀន ជាហេតុបណ្តាលឱ្យពួកគេបោះបង់ការសិក្សា ឬ ត្រួតថ្នាក់នៅឆ្នាំសិក្សានោះតែម្តង។

គម្រោងREACHកំពុងធ្វើកិច្ចសហការជាមួយអង្គការបីៈអង្គការ **ខេប** អង្គការ**ចាយ** និងអង្គការ**វឌ្ឍភាព** ។ អង្គការ**ខេប** និងអង្គការ**ចាយ** ធ្វើការជាមួយគ្នាក្នុងប្រពន្ធ័អប់រំរដ្ឋនៅកម្រិតបឋមសិក្សា ដើម្បីបង្កើនភាពងាយស្រួលចូលសាលារៀននិងគុណភាពអប់រំ ឯអង្គការ**វឌ្ឍនភាព** ផ្តោតលើសាលាមធ្យមនិងអភិវឌ្ឍសហគមន៍ ។

## សកម្មភាពសំខាន់ៗ

**បង្កើនភាពងាយស្រួលចូលសាលារៀន:** ការប្រមូលកុមារឱ្យចូលរៀន និងវត្តមានសិស្សនៅសាលាមានកម្រិតខ្ពស់ រួមទាំង ការអប់រំនៅមធ្យមសិក្សា តាមរយៈការលើកស្ទួយសិទ្ធិកុមារ យុទ្ធនាការប្រមូលកុមារចូលរៀន កម្មវិធីអាហារូបករណ៍ និងអន្តរាគមន៍ដទៃទៀត ដែលមានការចូលរួមពីសាលារៀន និងសហគមន៍ ។

**សកម្មភាពបង្កើតប្រាក់ចំណូល និងការអប់រំក្នុងសហគមន៍:** អង្គការវឌ្ឍនភាពគឺជាដៃគូអនុវត្តគម្រោងរបស់អង្គការ ខេប ដែលបានធ្វើការគាំទ្រដល់ ៣០០គ្រួសារ ដើម្បីបង្កើនសមត្ថភាពរកប្រាក់ចំណូលរបស់ពួកគេ តាមរយៈការណែនាំ និងការបណ្តុះបណ្តាលស្តីពីសកម្មភាពឥណទានខ្នាតតូច។ ហើយសកម្មភាពនេះក៏បានបង្កើតជាគណៈកម្មការសន្សំប្រាក់ ដែលមានការចូលរួមពីសមាជិកសហគមន៍ ។ អង្គការវឌ្ឍនភាពក៏បានផ្តល់ការគាំទ្រដល់សាលាមធ្យមសហគមន៍ចំនួន ១០ផងដែរ ។

**ការកសាងសមត្ថភាពនៅមូលដ្ឋាន:** គម្រោងបានពង្រឹងសមត្ថភាពអ្នកពាក់ព័ន្ធផ្សេងៗដើម្បីពង្រឹងសមត្ថភាពពួកគាត់ក្នុងការចូលរួមពិនិត្យតាមដាន ការធ្វើផែនការ និងការវាយតម្លៃដំណើរការអប់រំនៅមូលដ្ឋានពួកគាត់រស់នៅតាមរយៈយុទ្ធនាការលើកកម្ពស់ការយល់ដឹង ការបណ្តុះបណ្តាល និងសកម្មភាពហ្វឹកហ្វឺន ។ ការយកចិត្តទុកដាក់ជាពិសេសអំពីចំណាកស្រុក ការគាំពារកុមារ និងបញ្ហាអប់រំកុមារ ដែលនៅជិតព្រំប្រទល់ប្រទេសវៀតណាម ។

**ការបង្កើតបរិស្ថានសាលាកុមារមេត្រី:** គម្រោងលើកតម្កើនបរិស្ថានសិក្សាប្រកបដោយភាពទាក់ទាញ ដែលមានសម្ភារៈបង្រៀន និងវិធីសាស្ត្របង្រៀនសិស្សបែបមជ្ឈមណ្ឌល ។ គ្រូបង្រៀននឹងអភិវឌ្ឍទម្លាប់ឱ្យកុមារទទួលប្រយោជន៍អតិបរមារពីបរិស្ថានសាលាកុមារមេត្រី ។ គម្រោងលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងសកម្មតាមរយៈសកម្មភាពក្រុមប្រឹក្សាកុមារ និងការចូលរួមពិនិត្យតាមដាន និងវាយតម្លៃ ។

## រូបភាពសកម្មភាពខ្លីៗ



***ការអភិវឌ្ឍដោយអ្នកពាក់ព័ន្ធ:*** *ក្រុមប្រឹក្សាឃុំ នាយកសាលា និងនាយកកម្រងធ្វើការរួមគ្នាក្នុងអង្គប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ដើម្បីធ្វើការឆ្លុះបញ្ចាំងអំពីអ្វីដែលធ្វើបានល្អ និងអ្វីដែលត្រូវធ្វើការកែលម្អនៅឆ្នាំក្រោយទៀត ។*

***ការប្រមូលសិស្សចូលរៀន:*** *បុគ្គលិករីក គ្រូ និងសិស្សបានចុះទៅសហគមន៍មូលដ្ឋានផ្ទាល់ ដែលជាយុទ្ធនាការប្រមូលសិស្សចូលរៀន ។*





***បង្កើតការអប់រំដែលពាក់ព័ន្ធនឹងការសិក្សា:*** *សិស្សរៀនបំណិនជីវិតបុរេវិជ្ជាជីវៈដូចជា ការរៀបចំធ្វើម្ហូប និងចម្អិនអាហារ ដោយប្រើប្រាស់ឯកសារកម្មវិធីសិក្សាដែលបង្កើតដោយអង្គការ ខេប និងអង្គការអប់រំពិភពលោក ដែលទទួលស្គាល់ពីក្រសួងអប់រំ។ សកម្មភាពរៀនបែបនេះបង្កើត ភាពរីករាយនិងមានប្រយោជន៍ និងធ្វើឱ្យកុមារចូលសាលា។*

# “សហគមន៍រឹងមាំកសាងបាននូវសាលារៀនរឹងមាំ !”

## បច្ចុប្បន្នភាពគម្រោង

សាលាទាំងអស់បានអនុវត្តតាមផែនការអភិវឌ្ឍសាលាប្រចាំឆ្នាំ ។
ការធ្វើផែនទីសាលា និងការឧបត្ថម្ភអាហារូបករណ៍ដល់កុមារក្រីក្រ ត្រូវបានអនុវត្តជោគជ័យ ។
ការអនុវត្តជោគជ័យកម្មវិធីកុមារជួយកុមារ ដោយផ្តោតទៅលើសកម្មភាពកុមារធំជួយបង្រៀនកុមារតូច ។
គាំទ្រថ្នាក់បំប៉នបន្ថែមសម្រាប់អ្នកសិក្សាដែលមានតម្រូវការពិសេស
ការគាំទ្រកម្មវិធីសាលាកុមារមេត្រីសម្រាប់គ្រូនៅមូលដ្ឋាន និងក្រុមប្រឹក្សាកុមារ ដើម្បីបង្កើនការចូលរួមក្នុងការសិក្សា ។
ការបណ្តុះបណ្តាលវិធីសាស្ត្រមូលដ្ឋានដល់គ្រូដើម្បីធានាថា គ្រូបានបញ្ចូលបច្ចេកទេស ដែលតម្រូវឱ្យមានការផ្លាស់ប្តូរអនុវត្តការបង្រៀននៅតាមថ្នាក់រៀន។
កម្មវិធីបំណិនជីវិតធ្វើឱ្យមានការអប់រំចំណេះដឹងពាក់ព័ន្ធនៅក្នុងមូលដ្ឋាន។
ការបណ្តុះបណ្តាលភាពជាមេដឹកនាំសម្រាប់នាយកសាលា និងសហគមន៍ដើម្បីធានាថា អ្នកពាក់ព័ន្ធមានជំនាញគ្រប់គ្រងចាំបាច់ក្នុងការទទួលមូលនិធិពីក្រៅប្រទេសដោយប្រសិទ្ធភាព ។
ការអប់រំសុខភាព ។
ទស្សនកិច្ចសិក្សាសម្រាប់គ្រូបង្រៀន និងគណៈកម្មាការទ្រទ្រង់សាលាដើម្បីទទួលចំណេះដឹងថ្មីពីសាលារៀនដែលបានអនុវត្តបានល្អ ។
ក្រុមប្រឹក្សាកុមារធ្វើសកម្មភាពនិងគ្រប់គ្រងសកម្មភាពនៅសាលារៀន
ក្រុមគាំទ្របច្ចេកទេស (TSG) គាំទ្រដល់គ្រូផ្នែកបង្រៀន និងរៀន ។
គាំទ្របណ្ណាល័យដើម្បីបង្កើនការអាន និងសរសេររបស់សិស្ស ។

## ការជះឥទ្ធិពលគម្រោង

ការវាយតម្លៃគម្រោងនៅចុងឆ្នាំសិក្សាបង្ហាញថា: "ដោយផ្អែកលើការត្រួតពិនិត្យឯកសារដែលបានមកពីអ្នកពាក់ព័ន្ធផ្សេងគ្នាចូលរួមក្នុងគម្រោងបានផ្តល់ចម្លើយព្រមគ្នាថា គឺសាលារៀនសម្រេចបានសុចនាករក្នុងលំដាប់ទូលំទូលាយដែលស្ថិតក្រោម បរិស្ថានសាលាកុមារមេត្រី ដូចជា មានបង្គន់ដែលមានអនាម័យ ការគាំទ្រដល់ភាពងាយស្រួលចូលរៀន និងជំនួយដល់កុមារដែលត្រូវការរៀនពិសេស។
ការវាយតម្លៃរបស់ក្រុមប្រឹក្សាកុមារក៏បានរកឃើញផងដែរថា ពិន្ទុក្នុងការអនុវត្តមានការកើនឡើងបើប្រៀបធៀបទៅនឹងការវាយតម្លៃដើមឆ្នាំ ។ ក្រុមប្រឹក្សាកុមារ រៀបចំការប្រជុំក្រុមប្រចាំខែ ពួកគេគ្រប់គ្រងសកម្មភាពនៅសាលារៀន និងការពិនិត្យតាមដានផែនការរបស់ពួកគេ ។
ក្រុមគាំទ្របច្ចេកទេស (TSG) ប្រធានកម្រង និងប្រធានការិយាល័យអប់រំស្រុកបានជួយគ្រូផ្នែកបច្ចេកទេសបង្រៀន និងរៀន ការងាររដ្ឋបាល និងការវាយតម្លៃសិស្សជាប្រចាំ ។
នៅចុងឆ្នាំសិក្សា ២០១២-២០១៣ សាលាចំនួន ១៥ ឬ ៦០%នៃចំនួនសាលាសរុបបានរាយការណ៍ថាកាត់បន្ថយអត្រាបោះបង់ការសិក្សាបើប្រៀបធៀបនឹងការវាយតម្លៃដើមឆ្នាំ ។


ទស្សនកិច្ចបុគ្គលិក និងគ្រូរបស់គម្រោងនៅតាមផ្ទះសិស្ស ដើម្បីជ្រើសរើសសិស្ស អាហារូបករណ៍ ។

## រឿងជោគជ័យ


លោកមេភូមិ និងបុគ្គលិក អង្គការ ខេប ផ្តល់កង់ឱ្យសិស្សនៅនឹងផ្ទះគ្រួសាររបស់គេ ។

សំ ខុនមានអាយុ ៦ ឆ្នាំ និង សំ អា មានអាយុ ៩ ឆ្នាំ គឺជាបងប្អូនបង្កើតនឹងគ្នារស់នៅក្នុងស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ។ ពួកគេទាំងពីរនាក់គឺជាកូនរបស់ គ្រួសារក្រីក្រមួយ ។ ឪពុកម្តាយរបស់ពួកគេគ្មានដីសម្រាប់ធ្វើកសិកម្មទេ ។ ឪពុកពួកគេគឺជាកម្មករតាមរដូវកាល ។ ជួនកាលគាត់ចំណាកស្រុកទៅខេត្តព្រៃវែង ដើម្បីធ្វើការរកប្រាក់ចំណូល ប៉ុន្តែគាត់មិនអាចផ្គត់ផ្គង់គ្រួសារគាត់បានគ្រប់គ្រាន់ឡើយ ។ ម្តាយពួកគេនៅផ្ទះ ហើយគ្រួសារពួកគេមិនបានបញ្ជូនកូនទៅសាលារៀនទេពីព្រោះពួកគេមានអាទិភាពដទៃទៀត ។ បន្ទាប់ពីធ្វើផែនទីសាលារៀននៅក្នុងឆ្នាំសិក្សានេះ សាលានៅតំបន់នេះបានសុំឱ្យឪពុកម្តាយរបស់ខុន និងអានឱ្យចុះឈ្មោះចូលរៀនរៀងៗខ្លួននៅថ្នាក់ទី ១ និងទី ២ ។ ពួកគេធ្លាប់ចុះឈ្មោះចូលរៀនពីមុន ប៉ុន្តែក៏បានបោះបង់វិញពីព្រោះពួកគេរស់នៅឆ្ងាយពីសាលារៀន និងគ្មានសៀវភៅ ប៊ិច ឬឯកសណ្ឋានសម្រាប់ស្លៀកពាក់គ្រប់គ្រាន់ ។ ខុន និងអាន បានទទួលអាហារូបករណ៍តាមរយៈគម្រោងរីកនៅក្នុងឆ្នាំនេះ ។ កញ្ចប់អាហារូបករណ៍របស់អង្គការ ខេប រួមមាន៖ ខ្មៅដៃ សៀវភៅ ស្បែកជើងមួយគូ និងសម្លៀកបំពាក់ពីរកំប្លេ ។ ពួកគេក៏បានទទួលសម្ភារៈជាអង្ករពី អង្គការវឌ្ឍភាពផងដែរ ។ ជំនួយបន្ថែមដទៃទៀត រួមមាន កង់ផងដែរដើម្បីជួយសម្រួលដល់បញ្ហាផ្លូវឆ្ងាយ ។ បន្ទាប់ពីទទួលអាហារូបករណ៍រួច បច្ចុប្បន្ននេះ ខុន និង អាន បានមករៀនទៀងទាត់ និងបានឡើងថ្នាក់នៅចុងឆ្នាំសិក្សា ។ បច្ចុប្បន្ន ឪពុកម្តាយពួកគេបានយល់ថា អទិភាពដ៏សំខាន់គឺត្រូវបញ្ជូនកូនឱ្យទៅរៀន ទោះបីពួកគេមាន ការលំបាកផ្នែកហិរញ្ញវត្ថុក៏ដោយ ។ ប៉ុន្តែយ៉ាងហោចណាស់ ក៏ការគាំទ្រអាហារូបករណ៍អាចដោះស្រាយការធ្វើដំណើរផ្ទាល់ទៅសាលាផងដែរ ។

## ពិន្ទុមធ្យមភាគវាយតម្លៃកម្មវិធីកុមារមេត្រី



# គម្រោងគាំទ្រការសិក្សារបស់សិស្ស (PLP)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | CIAI |
| អ្នកទទួលផលផ្ទាល់ | សិស្ស ៣២៦ នាក់ (ស្រី ១៤៦ នាក់)<br>គ្រូ ៧៥ នាក់ (ស្រី ៤៧ នាក់) |
| ថវិកាប្រចាំឆ្នាំ ២០១៣ | ១១.៥១៧,១២ ដុល្លាអាមេរិក និងគាំទ្រ បដិភាគចំនួន ៨.២៤២,៧៥ ដុល្លាអាមេរិកពី ខេប សម្រាប់យាន្តជំនិះ (ម៉ូតូ ២គ្រឿង) |
| ខេត្តគ្របដណ្តប់ | ១ ខេត្ត (ប៉ៃលិន) |
| ចំនួនស្រុកគ្របដណ្តប់ | ១ ស្រុក (ប៉ៃលិន) |
| បឋមសិក្សាគោលដៅ | ១០ បឋមសិក្សា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | កញ្ញា ២០១២ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | កុម្ភៈ ២០១៤ |

## បច្ចុប្បន្នភាពគម្រោង

គណៈគ្រប់គ្រងសាលាបានទទួលវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អ ដែលយើងចាត់ទុកថា ជាការអនុវត្តប្រកបដោយប្រសិទ្ធភាពនិងមាននិរន្តរភាព ។

ក្រុមប្រឹក្សាកុមាររបស់សាលាគោលដៅត្រូវបានបង្កើតឡើងយោងទៅតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា និងមានតួនាទីដ៏សំខាន់ក្នុងការធ្វើផែនការសាលារៀន និងអនុវត្តសកម្មភាពដែលបានជ្រើសរើស ។

គម្រោងគាំទ្រការសិក្សារបស់សិស្សរៀបចំកិច្ចប្រជុំជាមួយមាតាបិតាសិស្សដើម្បីជួយពួកគាត់ឱ្យយល់អំពីតួនាទីពួកគាត់ក្នុងការអប់រំ និងទទួលខុសត្រូវចំពោះការអភិវឌ្ឍសាលាបន្ទាប់ពីគម្រោងបញ្ចប់ ។

គម្រោងគាំទ្រការសិក្សាបានបង្ហាញអំពីការអប់រំបំណិនជីវិតដល់គ្រប់សាលាទាំងអស់ដោយប្រើកម្មវិធីសិក្សាដែលអភិវឌ្ឍដោយអង្គការ ខេប ក្រោមគម្រោង IBEC និងទទួលស្គាល់ជាផ្លូវការដោយក្រសួងអប់រំ ។

គម្រោងនេះក៏បានគាំទ្របច្ចេកទេស និងសម្ភារៈដល់បណ្តាញសិស្សជួយសិស្ស ដោយប្រើប្រាស់វិធីសាស្ត្រកុមារជួយកុមារ ។

| សកម្មភាព | អ្នកទទួលផល | ស្រី |
|---|---|---|
| សិស្សទទួលកង់ សំលៀកបំពាក់ សម្ភារសិក្សា សម្ភារអនាម័យ និងការគាំទ្រសុខភាពជាមូលដ្ឋាន | ៣២៦ | ១៤៦ |
| សិស្សរៀនយឺតទទួលបានការប៉ំប៉នបន្ថែមរយៈពេល៣ខែត្រូវនឹងចំនួន ១០០៨ម៉ោង (ចំនួន២១ថ្នាក់នៃកម្រិតថ្នាក់ទី១ និង២ ដោយមួយខែត្រូវប៉ំប៉នចំនួន១៦ម៉ោង | ១៩២ | ១០១ |
| គ្រូទទួលការបណ្តុះបណ្តាលពង្រឹងសមត្ថភាពពីកម្មវិធីសាលាកុមារមេត្រី និង ទទួលបានសម្ភារបង្រៀន | ៧៥ | ៤៧ |
| គ្រូទទួលការបណ្តុះបណ្តាលពីកម្មវិធីបំណិនជីវិត | ២៤ | ១០ |
| សិស្សចូលរួមក្នុងសកម្មភាពសិស្សជួយសិស្ស | ១៩៧ | ១១៧ |
| សិស្សចូលរួមក្នុងសកម្មភាពសរសេរសំបុត្រកមិត្តភក្តិនៅសាលាផ្សេង | ២០៥ | ១២៦ |
| សិស្សជាគណៈកម្មការប្រតិបត្តិនៃក្រុមប្រឹក្សាកុមារ | ៧២ | ៣៦ |
| មាតាបិតាចូលរួមប្រជុំ និងចូលរួមសកម្មភាពសាលារៀន | ៤៥១ | ២៦១ |
| ការផ្តល់សម្ភារបង្រៀនសិស្សរៀនយឺត | ៨ សាលា | |
| ការជួសជុលសាលា និងសាងសង់ជម្រាលសម្រាប់សិស្សពិការ | ៨ សាលា | |

គោលបំណងរបស់គម្រោងគឺបង្កើនការចូលរួមរបស់កុមារធ្វើយ៉ាងណាឱ្យពួកគេទទួលបាននូវសេវាអប់រំប្រកបដោយសមធម៌ និងគុណភាពតាមរយៈការអនុវត្តសកម្មភាពមួយចំនួនពីកម្មវិធីសាលាកុមារមេត្រី ។

គម្រោងគាំទ្រការសិក្សារបស់សិស្សបានលើកស្ទួយគោលនយោបាយសាលាកុមារមេត្រី ប្រកបដោយប្រសិទ្ធភាព ក្នុងនេះមានសមាសភាគជាច្រើនត្រូវបានអនុវត្តតាមសាលារៀនគោលដៅ ។ គម្រោងបានចាប់ផ្តើមនៅខែកញ្ញា ២០១២ ដែលមានគោលបំណងលើកកម្ពស់កម្មវិធីសាលាកុមារមេត្រីក្នុងខេត្តប៉ៃលិន ។

### សមាសភាពទាំង ៦ នៃគោលនយោបាយសិស្សកុមារមេត្រី

១. កុមារទាំងអស់បានចូលរៀន
២. ការសិក្សាប្រកបដោយប្រសិទ្ធភាព
៣. សុខភាព សុវត្ថិភាព និងការការពារកុមារ
៤. ការឆ្លើយតបទៅនឹងយេនឌ័រ
៥. ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍
៦. ការគាំទ្រពីប្រព័ន្ធអប់រំ



*លោក សុខា បង្រៀនក្រុមប្រឹក្សាកុមារអំពីការធ្វើផែនការសកម្មភាព ដើម្បីកែលម្អសកម្មភាពសិក្សាប្រចាំថ្ងៃនៅសាលារៀនរបស់គេ ។*





# 24
# គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRAC)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | USAID/ World Vision US និង Australian Aid/ អង្គការអប់រំពិភពលោក (ទទួលមូលនិធិបឋម) |
| អ្នកទទួលផលផ្ទាល់ | សិស្ស ១.១៦១ នាក់ (ស្រី ៥៤៧ នាក់)<br>គ្រូ ៥១ នាក់ (ស្រី ៣៧ នាក់) |
| ថវិកាប្រចាំឆ្នាំ ២០១៣ | ៦៩.៥៣១,៤៨ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | ៤៩ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | ២ ខេត្ត (កំពង់ចាម និងសៀមរាប) |
| ចំនួនស្រុកគ្របដណ្តប់ | ៥ ស្រុក (ត្បូងឃ្មុំ អូររាំងឪ ព្រៃឈរ កំពង់ចាម និង ជីក្រែង) |
| បឋមសិក្សាគោលដៅ | ៨ សាលាបឋមសិក្សា (៦ ក្នុងខេត្តកំពង់ចាម និង ២ ក្នុងខេត្តសៀមរាប) |
| មធ្យមសិក្សាគោលដៅ | គ្មាន |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | តុលា ២០១២ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | កញ្ញា ២០១៤ |

គម្រោងត្រាកផ្តោតលើការលើកកម្ពស់បរិស្ថានរៀនសូត្រពីគ្រប់ផ្នែកពាក់ព័ន្ធ ដើម្បីពង្រឹងសមត្ថភាពរបស់កុមារឱ្យទទួលបាននូវជំនាញជាមូលដ្ឋានចាំបាច់ក្នុងការអាន ទន្ទឹមនឹងនោះជួយលើកស្ទួយវប្បធម៌នៃការអាននៅផ្ទះ និងសាលារៀន ព្រមទាំងលើកកម្ពស់កម្រិតនៃការអាន និងសរសេរសម្រាប់កុមារថ្នាក់ទី១ និងទី២ ដោយរៀបចំឱ្យមានការវាយតម្លៃទ្បេងទាត់ជាមួយប្រព័ន្ធឆ្លើយតបរហ័ស រួមបញ្ចូលទាំងការជួយបង្រៀនពីមាតាបិតា និងការរៀនតាមរយៈ M-Learning ។

### អន្តរាគមន៍សំខាន់ៗ

- ការបង្កើតស្តង់ដារអំណាន និងតេស្តវាយតម្លៃជាដំណាក់
- ការបង្កើតប្រព័ន្ធឆ្លើយតបរហ័សសម្រាប់កុមារ ដែលជួបបញ្ហាលំបាកក្នុងការអាន
- គ្រូបង្វឹកអំណាន
- ការសិក្សាចល័តតាមរយៈ ល្បែងសិក្សាក្នុងTablet
- ការចូលរួមពីមាតាបិតាសិស្ស
- ការបង្កើតល្បែងសិក្សាផ្សេងៗ

គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក) បានចាប់ផ្តើមនៅខែតុលា ឆ្នាំ២០១២ និងបន្តរហូតដល់ចុងខែកញ្ញា ឆ្នាំ២០១៤។ ត្រាកមានគោលបំណងពង្រឹងបំណិនអានរបស់កុមារនៅថ្នាក់ដំបូងដោយផ្តោតលើបរិស្ថានសិក្សារបស់កុមារទាំងនៅសាលា និងតាមផ្ទះ ។ គោលដៅបង្កើតថ្មីរួមមានស្តង់ដារអំណានដែលផ្សារភ្ជាប់ជាមួយកម្មវិធីសិក្សាអំណានថ្មីរបស់ក្រសួងអប់រំដើម្បីសម្រួលដល់ការវាយតម្លៃសិស្សទ្បេងទាត់ និងប្រព័ន្ធឆ្លើយតបរហ័សដើម្បីឆ្លើយតបទៅនឹងតម្រូវការសិស្សជួបបញ្ហាអាន និងការលេងល្បែងសិក្សាក្នុងឧបករណ៍ចល័ត(Tablet) ដែលសកម្មភាពទាំងនេះមានការសម្របសម្រួលដោយគ្រូបង្វឹកអំណាន ។ ត្រាកជួយគាំទ្រយុទ្ធសាស្ត្រអប់រំថ្មីរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ ដែលផ្តោតសំខាន់លើអំណានថ្នាក់ដំបូង ក៏ដូចជាជួយរដ្ឋាភិបាលដើម្បីកែលម្អអត្រាចេះអាននិងសរសេរដោយសហការដ៏ជិតស្និទ្ធជាមួយនាយកដ្ឋានបឋមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអភិវឌ្ឍនូវគោលដៅបង្កើតថ្មីនោះ។

## សកម្មភាពសំខាន់ៗ

1. ត្រាកធ្វើការជាមួយនាយកដ្ឋានបឋមសិក្សាដើម្បីបង្កើតស្តង់ដារអំណានជាដំណាក់រយៈពេលខ្លី ដោយផ្អែកលើសៀវភៅអំណានថ្មីរបស់ក្រសួង ។
2. ស្តង់ដារនេះជួយគ្រូចេះកំណត់រកសិស្សដែលជួបបញ្ហាក្នុងការអាន និងដឹងថាពួកគេកំពុងមានបញ្ហាអ្វី។
3. គ្រូបង្វឹកអំណាននឹងប្រើប្រាស់ប្រព័ន្ធឆ្លើយតបរហ័សដើម្បីដោះស្រាយតម្រូវការរបស់កុមារផ្អែកលើលទ្ធផលវាយតម្លៃ។
4. សម្ភារៈបង្រៀនបង្កើតថ្មីធ្វើឱ្យការសិក្សាមានភាពទាក់ទាញ និងចាប់អារម្មណ៍ ។
5. ការចូលរួមពីមាតាបិតាធ្វើឱ្យសិស្សហ្វឹកហ្វឺនជំនាញអាននៅសាលា និងនៅផ្ទះ ។



*ការចូលរួមពីមាតាសិស្សៈ មាតាសិស្សមកសាលាដើម្បីបង្រៀនកូននៅបណ្ណាល័យអំពី ការប្រើប្រាស់សម្ភារៈសិក្សា ។*

## បច្ចុប្បន្នភាពគម្រោង

- បន្ទាប់ពីអនុវត្តស្តង់ដារអំណាន និងការវាយតម្លៃជាដំណាក់នៅសាលាមួយឆ្នាំមក គម្រោងធ្វើការរៀបចំបញ្ចប់សៀវភៅស្តង់ដារអំណានសម្រាប់ឱ្យគ្រូងាយស្រួលប្រើប្រាស់ ។
- ពិធីការនៃប្រព័ន្ធឆ្លើយតបរហ័សត្រូវបានរៀបចំ និងដាក់បញ្ចូលក្នុងសៀវភៅ ។
- ការអភិវឌ្ឍ Application អំណាន Smart4Kids សម្រាប់ប្រើនៅលើ Tablets ឥឡូវនេះគឺឈានដល់ដំណាក់កាលធ្វើតេស្តបញ្ចប់ហើយ ។
- ត្រាកតាក់តែងករណីសិក្សាមួយនៅក្នុងការស្រាវជ្រាវរបស់អូស្ត្រាលីតាមរយៈ GSMA ។ បច្ចុប្បន្ននេះ ត្រាកត្រូវបានជ្រើសរើសចូលទៅក្នុងសៀវភៅ(កាតាឡុក)របស់ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍអន្តរជាតិអំពីវិទ្យាសាស្ត្រ និងការផ្តួចផ្តើមថ្មីៗនៃបច្ចេកវិទ្យា ហើយក៏ត្រូវបានបង្ហាញដល់ក្រុមអង្គការនានា និងទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍអន្តរជាតិនៅប្រទេសអូស្ត្រាលី ។

## រូបភាពសកម្មភាពខ្លីៗ



*សិស្សថ្នាក់ទី ១ ប្រើប្រាស់ Smart Phone នៅបណ្ណាល័យ ។*



*សិស្សថ្នាក់ទី ៥ បង្រៀនសិស្សថ្នាក់ទី ១ ដោយប្រើប្រាស់សម្ភារៈអាន នៅពេលទំនេររបស់គេ ។*

## ការផ្តោតលើគ្រូបង្វឹកអំណាន

លោក វ៉ាន់ ឈី (អាយុ៤៣ឆ្នាំ) គឺជាគ្រូបង្វឹកអំណាននៅសាលាគោលដៅរបស់គម្រោងត្រាកក្នុងខេត្តកំពង់ចាម ។ លោកមានការបារម្ភអំពីអនាគតកុមារនៅមូលដ្ឋានរបស់លោក ព្រោះកុមារទាំងនោះប្រឈមមុខនឹងឧបសគ្គច្រើនចំពោះការសិក្សារបស់ពួកគេ និងមិនបានទទួលសេវាអប់រំគ្រប់គ្រាន់ ។ មូលហេតុនេះធ្វើឱ្យលោកបានក្លាយទៅជាគ្រូបង្វឹកអំណានក្នុងគម្រោងត្រាក ដែលឧបត្ថម្ភដោយទីភ្នាក់ងារសហ រដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ អង្គការទស្សនពិភពលោក និងទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍអន្តរជាតិ តាមរយៈ គម្រោង All Children Reading ។ លោក វ៉ាន់ឈី បានរកឃើញថា សាលាបានប្រឈមមុខនឹងការលំបាកជាច្រើន។



*គ្រូអំណានផ្តល់កិច្ចសម្ភាសន៍នៅខេត្តកំពង់ចាម*

គ្រូបង្រៀនត្អូញត្អែអំពីសិស្សរៀនខ្សោយ ដែលពិបាកបង្រៀន ហើយគ្រូខ្វះការគាំទ្រខាងផ្នែកវិធីសាស្ត្របង្រៀនថ្មីៗ ។ លោក វ៉ាន់ឈី ពន្យល់ថា “*មុនពេលខ្ញុំធ្វើគ្រូបង្វឹកអំណាន ខ្ញុំគឺជាពលរដ្ឋ ធម្មតាម្នាក់ ដែលមិនបានយល់ច្បាស់អំពីប្រព័ន្ធអប់រំ និងតម្លៃនៃការចូលរួមពីសហគមន៍ និងគ្មានយុទ្ធសាស្ត្រដើម្បីជួយកុមារនៅក្នុងសហគមន៍*” ។ លោកវ៉ាន់ឈី ត្រូវបានក្លាយជាគ្រូបង្វឹកអំណានដែលទទួលការបណ្តុះបណ្តាលពីគម្រោងត្រាក ហើយលោកក៏បានផ្តល់បច្ចេកទេសបន្តដល់សាលា និងពង្រឹងគុណភាពអប់រំសម្រាប់កុមារដោយជួយសិស្សថ្នាក់ទី១ និងទី២ ដោយផ្តោតលើបំណិនអាន និងសរសេរ ។ តាំងពីពេលគាត់បានក្លាយជាគ្រូបង្វឹកអំណាន និងបានអនុវត្តអន្តរាគមន៍គម្រោងត្រាកមក គាត់សង្កេតឃើញថា សមត្ថភាពសិស្សមានភាពល្អប្រសើរ ហើយគ្រូងាយស្រួលក្នុងការបង្រៀនជាងមុន ព្រោះពួកគាត់ទទួលបានបច្ចេកទេសនិងសម្ភារៈបង្រៀនបន្ថែម ។ លោកត្រូវបានគេស្គាល់ថា គឺជាគ្រូដែលបានជួយដល់មាតាបិតាសិស្សក្នុងការជួយបង្រៀនកូននៅផ្ទះ ។ លោកក៏បានចុះទៅសួរសុខទុក្ខមាតាបិតាសិស្ស តាមផ្ទះផងដែរ ដើម្បីចែករំលែកព័ត៌មាន និងផ្តល់ព័ត៌មានត្រឡប់អំពីការសិក្សារបស់សិស្ស ។ លោកបានបរិច្ចាគពេលវេលាដើម្បីកែលម្អគុណភាពអប់រំនៅតំបន់គាត់ ។ ឥឡូវលោក វ៉ាន់ឈីមានភាពក្លាហានជាងមុន មានជំនាញបន្ថែម និងយល់ដឹងអំពីវិស័យអប់រំ និងមានការអភិវឌ្ឍខ្លួនបន្ថែម ។ បន្ថែមពីនេះទៅទៀត លោក វ៉ាន់ ឈី គឺជាមនុស្សថ្មីម្នាក់ដែលមានប្រជាប្រិយភាពទាំងនៅក្នុងសាលារៀន និងសហគមន៍របស់គាត់ ។



*មាតាបិតាចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការរៀនអាន រវាងមាតាបិតា និងសិស្សនៅសាលារៀន ។*

# គម្រោងខ្ញុំកំពុងរៀន ( I'm Learning! Project )

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | Save the Children/NORAD |
| អ្នកទទួលផលផ្ទាល់ | សិស្ស ១.៨៧២ នាក់ (ស្រី ៩៦៩ នាក់)<br>មាតាបិតា/សហគមន៍១២០នាក់ (ស្រី៦០នាក់)<br>នាយកសាលា ២០ នាក់ (ស្រី ៣នាក់)<br>គ្រូ ២៤០ នាក់ (ស្រី ១២០នាក់) |
| ថវិកាប្រចាំឆ្នាំ ២០១៣ | ៤០.០២៤,០០ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | គ្មាន |
| ខេត្តគ្របដណ្តប់ | ២ (កំពង់ចាម/ព្រៃវែង) |
| ចំនួនស្រុកគ្របដណ្តប់ | ១២ (៩ ស្រុកក្នុងខេត្តកំពង់ចាម ៣ ស្រុកក្នុងខេត្តព្រៃវែង) |
| បឋមសិក្សាគោលដៅ | ៥ សាលាអនុវត្ត<br>១៥ សាលាប្រៀបធៀប |
| មធ្យមសិក្សាគោលដៅ | គ្មាន |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | មីនា ២០១៣ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ២០១៥ |

## បច្ចុប្បន្នភាពគម្រោង

*គម្រោងខ្ញុំកំពុងរៀន!* បានចាប់ផ្តើមនៅខែឧសភា ឆ្នាំ២០១៣ ដោយបានធ្វើការសិក្សាលើសាលាបេក្ខភាពជាច្រើនមុនពេលឈានដល់ការសម្រេចជ្រើសរើសសាលាចំនួន ២០ (សាលាអនុវត្ត ៥ និងសាលាប្រៀបធៀប ១៥) ។ គម្រោងនេះបានប្រតិបត្តិរយៈពេល ៥ខែប៉ុណ្ណោះ ប៉ុន្តែក្នុងអំឡុងពេលនេះ អង្គការ ខេប បានបង្កើតលក្ខណៈវិនិច្ឆ័យ និងចុះជ្រើសរើសសាលាដែលមានចំនួន ៥ ប្រភេទ ។ បន្ទាប់មកគម្រោងបានចាប់ផ្តើមធ្វើការប្រមូលទិន្នន័យមូលដ្ឋានដោយប្រើឧបករណ៍ដោយមានការកែប្រែតិចតួចពី អង្គការ Save the Children ពីគោលការណ៍ QLE បឋម។ ក្រុមការងារអង្គការ ខេប ក៏បានចាប់ផ្តើមអភិវឌ្ឍគម្រោងស្រាវជ្រាវដើម្បីណែនាំអំពីការប្រមូលទិន្នន័យ និងការវិភាគលើការ ផ្លាស់ប្តូរបរិស្ថានសិក្សាសាលា និងលទ្ធផលទទួលបានជាក់ស្តែង ។ គម្រោងនេះនឹងធ្វើរបាយការណ៍ស្រាវជ្រាវជាផ្លូវការស្របទៅនឹងប្រទេសពីរទៀត ដែលនឹងផ្សព្វផ្សាយទូលំទូលាយតាមរយៈបណ្តាញការងារអង្គការ Save the Children ។



សកម្មភាពធ្វើតេស្តអាន និងសរសេររបស់សិស្ស

## សនិទានភាពនៃកម្មវិធី

*គម្រោងខ្ញុំកំពុងរៀន!* គឺជាគម្រោងថ្មីមួយដែលបានចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ ២០១៣ ។ គម្រោងនេះជាឧទាហរណ៍មួយនៃនិន្នាការថ្មីក្នុងការអភិវឌ្ឍដែលផ្តោតលើកម្មវិធីជាភស្តុតាង ។ គម្រោងនេះមានសមាសភាគផ្សេងៗគ្នា រួមមាន៖ ផ្នែកស្រាវជ្រាវ ផ្នែកតាមដាន និងវាយតម្លៃ និងផ្នែកប្រតិបត្តិ ។ អង្គការ Save the Children ទទួលខុសត្រូវផ្នែកសកម្មភាពអនុវត្តនៅក្នុងសាលាអនុវត្តទាំង ៥ នៅខេត្តកំពង់ចាម ហើយអង្គការ ខេប ទទួលខុសត្រូវផ្នែកតាមដាន និងវាយតម្លៃ ដែលជាការអភិវឌ្ឍគម្រោងស្រាវជ្រាវផ្លូវការបង្ហាញពីសុពលភាពបែបពិសោធន៍ អំពីលទ្ធផលនៃអន្តរាគមន៍ ដែលធ្វើឱ្យផ្លាស់ប្តូរនៅសាលាអនុវត្ត ធៀបទៅនឹងសាលាប្រៀបធៀប ។ គម្រោងផ្តល់ភស្តុតាងជាក់លាក់ដែលជាវិធីសាស្ត្រសរុបចំពោះការអភិវឌ្ឍសាលារៀនថាពិតជាអាចកែលម្អលទ្ធផលសិក្សារបស់កុមារ ។ ខណៈដែលអភិវឌ្ឍវិធីសាស្ត្រសរុប ដូចជា កម្មវិធីកុមារមេត្រីរបស់ អង្គការ ខេប មាន ៦ផ្នែក ដែលទទួលបានការផ្សព្វផ្សាយទូលំទូលាយទាំងក្នុង និងក្រៅប្រទេសនោះ ប៉ុន្តែកម្រនឹងឃើញមានឧទាហរណ៍ពិសោធន៍បែបនេះណាស់ ។ ដូច្នេះ *គម្រោងខ្ញុំកំពុងរៀន!* ត្រូវការផ្តល់ការគាំទ្របែបច្នៃប្រឌិតថ្មី និងសរុបដល់សាលានៅក្នុងខេត្តកំពង់ចាម ដែលគម្រោងអនុវត្តនឹងបង្កើតជាភស្តុតាងប្រកបដោយប្រសិទ្ធភាពពីការអន្តរាគមន៍ទាំងនេះ ។ សកម្មភាពត្រូវបានរៀបចំជា "គម្រោងគុណភាពបរិស្ថានសិក្សា (QLE)" ដែលចំនួន ៤ គោលការណ៍ធំៗដូចខាងក្រោម៖

- ការពារផ្លូវចិត្ត និងអារម្មណ៍
- ការពារផ្លូវកាយ
- វិធីរៀនបែបសកម្ម (កែលម្អលទ្ធផលសិក្សា)
- ការចូលរួមពីមាតាបិតា និងសហគមន៍ ។



គម្រោងបានបណ្តុះបណ្តាលបង្ហាញទិសដល់អ្នកប្រមូលទិន្នន័យ ។

# ព្រឹត្តិការណ៍សំខាន់ៗ និងការអភិវឌ្ឍនៅក្នុងឆ្នាំនេះ

" ការអភិវឌ្ឍតាមរយៈបណ្តាញ និងនៅថ្នាក់មូលដ្ឋាន "

## សន្និបាតកម្មវិធីអាហ្វឡាទូនប្រចាំតំបន់នៅខាតមែនឌុ

នៅខែតុលា ឆ្នាំ ២០១២ អង្គការ ខេប បានបញ្ជូនតំណាង២រូបទៅចូលរួមសន្និបាតកម្មវិធីអាហ្វឡាទូនប្រចាំតំបន់ នៅរដ្ឋធានីខាតមែនឌុ ប្រទេសនេប៉ាល់ ។ កម្មវិធីនេះបង្ហាញអំពីគម្រោងសាលារៀនមានបំណិនជីវិតពេញបរិបូរណ៍ និងដកបទពិសោធន៍ពីការបង្កើតថ្មីនៃការរៀនអំពីហិរញ្ញវត្ថុ ដែលកំពុងអនុវត្តនៅក្នុងប្រទេសជិតខាង ដូចជា ឡាវ ថៃ និងហ្វីលីពីន ។ អង្គការ ខេប បានបង្ហាញ វីដេអូស្តីពីការអនុវត្តកម្មវិធីនៅក្នុងប្រទេសកម្ពុជា និងចែករំលែកបទពិសោធន៍ អំពីការបើកដំណើរការសហគ្រាសសង្គម TTS ដើម្បីលើកកម្ពស់បរិបទយល់ដឹង ពីហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងកម្មវិធីសិក្សាអាហ្វឡាទូនតាមរយៈល្បែងសិក្សាជាភាសាខ្មែរ ។

## សិក្ខាសាលាស្តីពីអំណាចស្ត្រីនៅសហរដ្ឋអាមេរិក

នៅខែវិច្ឆិកា ឆ្នាំ២០១២ កញ្ញា ហ៊ុម ម៉ារី ជាអ្នកសម្របសម្រួលកម្មវិធីអប់រំបញ្ចូលគ្នាត្រូវបានស្ថានទូតអាមេរិកអញ្ជើញចូលរួមសិក្ខាសាលាមួយ ដែលរៀបចំឡើងដើម្បីលើកកម្ពស់អំណាចស្ត្រីនៅក្នុងពហុវិស័យ រួមមាន វិស័យអប់រំ ។ សិក្ខាសាលានេះឧបត្ថម្ភដោយរដ្ឋាភិបាលអាមេរិក និងទៅទស្សនកិច្ចនៅសាកលវិទ្យាល័យ Montana និង Washington D.C ដែលជាកន្លែងរៀបចំវិញ្ញាបនបត្របញ្ជាក់ការចូលរួមកម្មវិធីអំណាចស្ត្រី ។ អង្គការ ខេប ក៏បានទទួលថវិកា ៦00 ដុល្លាអាមេរិកផងដែរពីបឋមសិក្សានៅអាមេរិកដើម្បីកសាងកន្លែងក្មេងលេងនៅសាលាបឋមសិក្សាភូមិ ៦ ខេត្តកំពង់ចាម ។

## ការចូលរួមសន្និសិទអន្តរជាតិអាហ្វឡាទូនស្តីពីហិរញ្ញវត្ថុ

តំណាងមកពីអង្គការ ខេប និងក្រសួងអប់រំ យុវជន និងកីឡា បានចូលរួមសន្និសិទអន្តរជាតិប្រចាំឆ្នាំស្តីពីការយល់ដឹងហិរញ្ញវត្ថុ ដែលរៀបចំឡើងដោយ អាហ្វឡាទូននៅក្រុង Nairobi ប្រទេសកេនយ៉ា ។ សន្និសិទនេះគឺជាឱកាសដ៏សំខាន់មួយសម្រាប់អង្គការ ខេប យល់ដឹងពីនិន្នាការពិភពលោកផ្នែកហិរញ្ញវត្ថុ និងរបៀបដែលអង្គការ ខេប អាចបន្តធ្វើគម្រោងអភិវឌ្ឍឱ្យទាន់សភាពការណ៍ចុងក្រោយក្នុងវិស័យនេះ ។



*សន្និសិទស្តីពីហិរញ្ញវត្ថុនៅកេនយ៉ាៈ កញ្ញា ហ៊ុម ម៉ារី ហំក្រម៉ាក្បាលចូលរួមពិភាក្សាក្រុមតូចៗអំពីហិរញ្ញវត្ថុ ។*

## សិក្ខាសាលាស្តីពីការអនុវត្តល្អរបស់អង្គការ ខេប & NEP

នៅថ្ងៃទី ២៨ ខែសីហា អង្គការ ខេប និងអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រចាំឆ្នាំលើកទី ៤ ស្តីពីការអនុវត្តល្អ និងមេរៀនបទពិសោធន៍ពីការអនុវត្តគម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា(IBEC) គាំទ្រមូលនិធិដោយ USAID និងអង្គការអប់រំពិភពលោក ។ សិក្ខាសាលានេះបានធ្វើឡើងនៅសណ្ឋាគារភ្នំពេញដែលមានអ្នកចូលរួមសរុប ៨២នាក់ រួមមានតំណាង ៤២អង្គការ សិស្ស គ្រូបង្រៀនមកពីសាលាគោលដៅគម្រោង IBEC និងម្ចាស់ជំនួយផងដែរ ដូចជា USAID ។




## គម្រោង BSI របស់អង្គការខេបត្រូវបានចុះផ្សាយនៅ ACFID និង មជ្ឈមណ្ឌលច្នៃប្រឌិតអប់រំ

គម្រោងសាលារៀនដៃគូមានភាពជោគជ័យយ៉ាងធំធេងកាលពីឆ្នាំកន្លងទៅក្នុងការជម្រុញឱ្យមានរបៀបវារៈតស៊ូមតិអំពីភាពជាដៃគូរវាងរដ្ឋ និងឯកជន ផ្អែកលើគំរូនៃគម្រោង BSI ។ ក្នុងន័យនេះ អង្គការ ខេប បានទំនាក់ទំនងជាមួយមជ្ឈមណ្ឌលច្នៃប្រឌិតអប់រំ(CEI) ដែលជាការិយាល័យ ដ៏ធំមួយនៅសហរដ្ឋអាមេរិក ដែលបានបង្ហាញករណីនានាស្តីអំពីភាពជោគជ័យនៃភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងវិស័យអប់រំ ។ CEI បានធ្វើសម្ភាសន៍ជាមួយបុគ្គលិកគម្រោង ដើម្បីចងក្រងប្រវត្តិគម្រោងដែលឥឡូវនេះត្រូវបានចុះផ្សាយនៅក្នុងគេហទំព័រCEI។ នេះគឺជាគេហទំព័រមួយដ៏មានប្រជាប្រិយភាព ហើយមានអ្នកអប់រំរាប់ពាន់អ្នកចូលទស្សនាជាប្រចាំ និងជួយលើកតំកើងកិត្យានុភាពរបស់គម្រោងលើឆាកអន្តរជាតិ។ គេអាចចូលទស្សនាព័ត៌មាននេះតាមរយៈគេហទំព័រ http://www.educationinnovations.org ។ BSI ក៏ត្រូវបានចងក្រងជាករណីសិក្សា ដោយមជ្ឈមណ្ឌលអូស្ត្រាលីដើម្បីអភិវឌ្ឍអន្តរជាតិ (ACFID) ដែលនឹងត្រូវចេញផ្សាយក្នុងពេលដ៏ខ្លីខាងមុខ សំដៅបញ្ចុះបញ្ចូលរដ្ឋាភិបាលប្រទេសអូស្ត្រាលីឱ្យជួយផ្តល់ជំនួយដោយផ្ទាល់ច្រើនឡើងថែមទៀតដល់អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលធ្វើកិច្ចការអភិវឌ្ឍ។ ករណីសិក្សាគម្រោង BSI នឹងត្រូវចេញផ្សាយនៅខែកុម្ភៈ ឆ្នាំ២០១៤ ខាងមុខនេះ និងបានចាប់ផ្តើមបង្ហាញដំបូងក្នុងសន្និបាតបណ្តាញសាកលវិទ្យាល័យ ACFID នៅសាកលវិទ្យាល័យ Sydney កាលពីខែវិច្ឆិកា ឆ្នាំ ២០១៣ កន្លងទៅ។

## មណ្ឌលសិក្សាគំរូដំណើរការពេញលេញ



*ទិដ្ឋភាពនៅខាងមុខមណ្ឌលសិក្សា*

គម្រោងសាងសង់មណ្ឌលសិក្សាគំរូដែលត្រូវបានឧបត្ថម្ភដោយ Apple Corporation, Flight Center អង្គការអប់រំពិភពលោក និងមូលនិធិ Oaktree បានចប់រួចរាល់នៅចុងឆ្នាំនេះ ។ អាគារនេះមានរចនាបទថ្មី និងមានលក្ខណៈពិសេសពាក់ព័ន្ធនឹងសាលាគំរូនៅខេត្តកំពង់ចាមបច្ចុប្បន្ន ។ មណ្ឌលថ្មីនេះនឹងជួយ សម្រួលបន្ថែមស្តង់ដាសិក្សាកម្រិតខ្ពស់ ធ្វើការជាមូលដ្ឋានដោយគម្រោង BSI ក្លឹបយុវជន កម្មវិធី ICT និងកម្មវិធីបំណិនជីវិត ដែលបានចាប់ផ្តើមកាលពីដើមឆ្នាំ ២០១១ មក ។ គ្រឿងបរិក្ខាពិសេសរួមមានមណ្ឌលព័ត៌មាន ដែលផ្តល់ឱ្យយើង អាចទទួលព័ត៌មានតាមរយៈបណ្តាញជាច្រើន ដូចជា Laptops ឧបករណ៍សិក្សា ជាទូរស័ព្ទដៃ ទូរទស្សន៍ LCD ខ្នាតធំ និងការសិក្សារឿងនិទាន ។ មណ្ឌលព័ត៌មាន ជាប់នឹងបន្ទប់កុំព្យូទ័រ (ប្រើប្រាស់បច្ចេកវិទ្យា thin client) និងបរិក្ខាបណ្ណាល័យ ដែលគម្រោង BSI បង្កើតដំបូងគេ ។ គ្រឿងបរិក្ខាក៏រាប់បញ្ចូលផងដែរនូវបន្ទប់ រៀនសម្រាប់សកម្មភាពកម្មវិធីបំណិនជីវិត បន្ទប់ប្រជុំ កន្លែងលក់អាហារ និង សួនច្បារដើម្បីពង្រីងសោភ័ណ្ឌភាពបរិស្ថានសិក្សា ។

# ព្រឹត្តិការណ៍សំខាន់ៗ និងការអភិវឌ្ឍនៅក្នុងឆ្នាំនេះ

" ការអភិវឌ្ឍតាមរយៈបណ្តាញ និងនៅថ្នាក់មូលដ្ឋាន "

## បច្ចុប្បន្នភាព TTS-KAPE



នៅថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១២ អង្គការ ខេប បានបើកសម្ពោធន៍ឱ្យដំណើរការសហគ្រាសសង្គមឯករាជ្យ ដែលមានឈ្មោះថា ធនធានសិក្សាខេប ឬហៅកាត់ថា ធធស គឺជាសហគ្រាសសង្គមដំបូងគេនៅកម្ពុជា ដែលលើកស្ទួយផលិតសម្ភារៈបង្រៀន និងរៀន (www.tts-kape.org)។ អង្គការ ខេប បានផ្តល់ទុនវិនិយោគដល់ធនធានសិក្សាខេបសម្រាប់ បោះពុម្ពផ្សាយ និងការចំណាយផ្សេងៗ ។ នៅឆ្នាំនេះ ធធស បានដំណើរការយ៉ាងជោគជ័យក្នុងការផ្តល់សេវាផ្គត់ផ្គង់សម្ភារៈបង្រៀន និងរៀនដល់សាលារដ្ឋ និងសាលាឯកជននៅក្នុងប្រទេស កម្ពុជា ហើយទទួលបានប្រាក់ចំណូលជាង ៣០.០០០ដុល្លាអាមេរិកក្នុងប្រតិបត្តិការដើមឆ្នាំដំបូង ។ ធធស បានបំពេញចន្លោះខ្វះខាតក្នុងវិស័យអប់រំដែលកំពុងតែធ្វើកំណែទម្រង់ដោយផ្តោតទៅលើសម្ភារៈបង្រៀន និងរៀន ។ បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា បានទទួលស្គាល់ជាផ្លូវការលើល្បែងសិក្សារបស់ ធធស ចំនួន ១១មុខ និង ១១មុខទៀតកំពុងពិនិត្យមើល ។ ប្រាក់ចំណេញដែល ធធស ទទួលបានពីអតិថិជនគឺត្រូវបញ្ចូលជាមូលនិធិសម្រាប់ចំណាយលើប្រាក់បៀវត្សន៍ ការប្រើប្រាស់សម្ភារៈ ការបោះពុម្ព និងមួយចំណែកទៀតបានផ្តល់ជាអំណោយដល់សាលារៀនជួបការលំបាក ។









**ការប្រើវិស័យឯកជនដើម្បីគាំទ្រការអភិវឌ្ឍការអប់រំឱ្យមាននិរន្តរភាព:**
កុមារចូលចិត្តលេងល្បែងសិក្សាដែលមានភាពទាក់ទាញដូចផលិតរបស់ ធធស (រូបខាងលើ) ។
ល្បែងសិក្សាថ្មីៗមួយចំនួនបានជួយការរៀនអក្សរ និងលេខថ្នាក់ដំបូង ដែលបច្ចុប្បន្ននេះត្រូវបានបង្កើតឡើងដោយ ធធស (រូបខាងស្តាំ) ។ សូមចុចពាក្យ "Like" លើទំព័រសង្គម **Facebook** របស់យើងតាមរយៈ **www.facebook.com/ttskape** ។

## គម្រោងស្រាវជ្រាវ

ឆ្នាំនេះ អង្គការ ខេប បានចូលរួមធ្វើការងារយ៉ាងសកម្មនៅក្នុងគម្រោងស្រាវជ្រាវ ដែលផ្តល់ការយល់ដឹងដ៏ប្រសើរអំពីបរិបទនៅមូលដ្ឋាន ដែលអង្គការបង្កើតនូវគម្រោងថ្មី ក៏ជាព័ត៌មានជួយអង្គការ ខេប លើកស្ទួយ ការអភិវឌ្ឍន៍ផ្អែកលើភស្តុតាង ដែលផ្តល់សុពលភាពពិសោធន៍នៃឥទ្ធិពលគម្រោង ។ ក្នុងឆ្នាំនេះ អង្គការ ខេប បានបន្តអនុវត្តកម្មវិធីសាកល្បងទប់ស្កាត់ សិស្សបោះបង់ការសិក្សាក្រោមការដឹកនាំរបស់អង្គការ *Creative Associates* ដែលជាគម្រោងស្រាវជ្រាវប្រើថវិកាច្រើនលានដុល្លាឧបត្ថម្ភដោយទីភ្នាក់ងារ សហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) នៅក្នុងប្រទេសចំនួន៤ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពអន្តរាគមន៍ទប់ស្កាត់ការបោះបង់ការសិក្សា ។

អង្គការ ខេប ក៏បានទទួលមូលនិធិពីអង្គការ Save the Children អន្តរជាតិផងដែរ ដើម្បីធ្វើការសិក្សាពីនិន្នាការចុះឈ្មោះសិស្សចូលរៀននៅក្រុងភ្នំពេញ ដែលមានការធ្លាក់ចុះគួរកត់សំគាល់ដោយសារមានការប្រកួតប្រជែងពីសាលាឯកជន និងការធ្វើសមាហរណកម្មឃុំជនបទនៅតំបន់ជាយក្រុង ។ របាយការណ៍នេះមានលក្ខណៈទៀងពេល និងបង្ហាញពីតម្រូវការពន្លឿនភាពជាដៃគូឯកជន និង រដ្ឋក្នុងវិស័យអប់រំដែលកំពុងត្រូវបានលើកស្ទួយពីគម្រោងដូចជា គម្រោងសាលារៀនដៃគូ (BSI) ។

អង្គការ ខេប ក៏បាន ចាប់ផ្តើមគម្រោងស្រាវជ្រាវជាមួយអង្គការ Save the Children ឈ្មោះថា "ខ្ញុំកំពុងរៀន" ដែលផ្តល់ឱកាសសម្រាប់សុពលភាពឥទ្ធិពលគម្រោងជាបទពិសោធន៍ ។ ម៉្យាងវិញទៀត អង្គការ ខេប បានធ្វើកិច្ចព្រមព្រៀងជាមួយអង្គការ Save the Children ដើម្បីសិក្សាគម្រោងធំស្តីពីការគាំពារ និងការអភិវឌ្ឍន៍កុមារដែលគាំទ្រមូលនិធិដោយ *Prudential Insurance* ។ ការសិក្សានេះបានពង្រីកការងារអង្គការ ខេប លើការគាំពារ និងការអភិវឌ្ឍន៍កុមារ និងតួនាទីពាក់ព័ន្ធវិស័យអប់រំនៅថ្ងៃអនាគត ។



# ការបង្ហាញផ្នែកហិរញ្ញវត្ថុ

## សាច់ប្រាក់ និងការចំណាយ

| Description | Amount (US$) |
|---|---|
| ចំណូលថវិកាសរុបក្នុងគម្រោងប្រចាំឆ្នាំ ២០១៣ | ៣.១១១.៩៣៣,៧៥ |
| សមតុល្យចុងគ្រាពីឆ្នាំ ២០១២ | ២០៥.៨០៣,៤១ |
| ចំណូលការប្រាក់ | ៧៤០,៦៣ |
| ទ្រព្យដែលអាចប្រើប្រាស់ក្នុងឆ្នាំ ២០១៣ | ៣.៣១៨.០៧៧,៧៩ |
| សរុបថវិកាចំណាយប្រចាំឆ្នាំ ២០១៣ | ២.៧៨៧.៩៥៦,៧១ |
| អត្រានៃការប្រើប្រាស់ថវិកា | ៨៤% |

## និន្នាការទទួលថវិការ




## តើថវិកាជំនួយត្រូវយកទៅប្រើប្រាស់ដូចម្តេច?




## សេចក្តីថ្លែងអំណរគុណ!

ជួសមុខឱ្យកុមារ គ្រូបង្រៀន ឪពុកម្តាយ និងក្រុមអ្នកទទួលផលទាំងនោះមកពីកម្មវិធីរបស់យើង អង្គការ ខេប សូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយទាំងអស់សម្រាប់ការផ្តត់ផ្គង់របស់ពួកគេក្នុងឆ្នាំនេះ និងឆ្នាំមុនៗកន្លងមក ។ ហិរញ្ញវត្ថុ និងការផ្គត់ផ្គង់បានធ្វើឱ្យអង្គការ ខេប មានសេវាកម្មមានន័យគ្រប់គ្រាន់ ។

**សូមអរគុណ!**

## លំហូរចំណូលឆ្នាំ ២០១៣

| ម្ចាស់ជំនួយ | ចំនួនទឹកប្រាក់ជាដុល្លា (US$) |
|---|---|
| Creative Associates International, Inc. (CAI)/ USAID | ១.៦០២.៤៣៥,០៩ |
| World Education, Inc./USAID | ៦២៩.៧៧៦,៩២ |
| The Oaktree Foundation | ២៣៤.៩៤៣,២៩ |
| Intervita | ២០១.១៣៥,៧៤ |
| The Asia Foundation | ១៩៣.៤៣៦,៨៣ |
| Save the Children | ៧២.២០៥.៣១ |
| Terre des Hommes | ៦៩.៤៣៨,៣០ |
| TRAC/All Children Reading | ៦៨.៦៣៤,៧៨ |
| Classroom of Hope (CoH) | ៥៨.៤៩៤,៤៥ |
| Aflateen/Barclay's Capital | ៤០.១៧៩.00 |
| Lotus Outreach | ៣៣.១២២,៤០ |
| CIAI | ២១.៩១០.00 |
| Aflatoun/Barclay's Capital | ១៩.១២១,៣១ |
| The Breteau Foundation/ ISHS | ១៦.៤៥០,00 |
| NEP/CEQE | ១០.000,00 |
| See Beyond Border | ៣.៧២០,00 |
| American Jewish World Service | ៣.០៩៤,១៤ |
| World Food Program*/VSO | In-kind Support |
| ការទទួលប្រាក់ចំណូលថ្មីឆ្នាំ ២០១៣ | ៣.១១១.៩៣៣,៧៥ |

* លំហូរសាច់ប្រាក់សរុបនៃបដិភាគសម្រាប់កម្មវិធីស្បៀង មិនត្រូវបានរាប់

# ថ្នាក់គ្រប់គ្រងអង្គការ ខេប ឆ្នាំ ២០១៣

## ក្រុមអ្នកគ្រប់គ្រងជាន់ខ្ពស់ (SMT)



**លោក សៅ វណ្ណា**
នាយកប្រតិបត្តិ



**លោក ហ៊ិន ស៊ីមហួន**
នាយករងប្រតិបត្តិរង និង
ប្រធានគម្រោង IBEC



**លោក ឃីត ច្រែដិនប៊ែក**
ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់



**លោកស្រី អាលី លែន**
ទីប្រឹក្សាទូទៅ



**លោកស្រី ប៉ោឡា ម៉ាសា**
ទីប្រឹក្សាផ្នែកកសាងសមត្ថភាព



**លោក ប្ញ សម្បត្តិ**
ប្រធានគ្រប់គ្រងហិរញ្ញវត្ថុ



**លោក ឈួន សារ៉ាន**
ប្រធានរដ្ឋបាល និង
ធនធានមនុស្ស

## អ្នកដឹកនាំសំខាន់ៗរបស់អង្គការ ខេប *(ឈ្មោះតាមលំដាប់អក្សរ)*



**លោកស្រី ខារូល វីលៀម**
មន្ត្រីជំនាញផ្នែកតាមដាន
វាយតំលៃ និងស្រាវជ្រាវរបស់
SDPP (គម្រោងស្វ័យយ័ត)



**លោក ជា កុសល**
អ្នកសម្របសម្រួលប្រចាំប្រទេស
របស់ SDPP (គម្រោងស្វ័យយ័ត)



**លោក ហាច្យ ពិសិដ្ឋ**
ប្រធានស្រាវជ្រាវ
(គម្រោងខ្ញុំកំពុងរៀន QLE)



**កញ្ញា ហ៊ឹម ម៉ារី**
ប្រធានសម្របសម្រួលកម្មវិធី
អប់រំបញ្ចូលគ្នា (IEP)



**កញ្ញា ភារីស្មា ស៊ុស្សីល គុមារ**
ទីប្រឹក្សាទំនាក់ទំនង



**លោកស្រី ម៉ា ច័ន្ទសុភាព**
ប្រធានផ្នែកកសាងសមត្ថភាព



**លោក ម៉ៃ សារិទ្ធិ**
ប្រធានគម្រោងបង្កើនភាពងាយ
ស្រួលចូលសាលារៀនតាមរយៈ
ការគាំទ្រពីសហគមន៍ (REACH)



**លោកស្រី ឱ តិរ៉ាណា**
ប្រធានកម្មវិធីអាហារូបករណ៍
នៅសាកលវិទ្យាល័យ CTSP



**លោកស្រី អ៊ុក សុធីរា**
អ្នកឯកទេសផ្នែកអប់រំរបស់
SDPP (គម្រោងស្វ័យយ័ត)



**លោក តួច សារ៉េត**
ប្រធានផ្នែករៀបចំ
ប្រព័ន្ធព័ត៌មាន



**លោក ពេជ្រ សុភឿន**
អ្នកសម្របសម្រួល កម្មវិធី
អាហារពេលព្រឹក (SFP) កម្មវិធី
អាហារូបករណ៍ស្បៀង (THR)



**កញ្ញា សែត សុលក្ខណា**
អ្នកសម្របសម្រួលគម្រោងត្រាក់
(វិធីសាស្ត្រសរុបដើម្បីពង្រឹង
អំណានសម្រាប់កុមារ TRAC)



**លោក ស្លេះ តហៀត**
ប្រធានគម្រោង
សាលារៀនល្អប្រសើរ (SfE)



**លោក សឿង វ៉ាន់**
ប្រធានកម្រោង
សាលារៀនដៃគូ (BSI)



**លោក ស៊ុំ វណ្ណៈ**
ប្រធានផ្នែកគ្រប់គ្រង
ការបោះពុម្ពផ្សាយ TTS

# រចនាសម្ព័ន្ធអង្គការ ខេប




| | | | | | |
|---|---|---|---|---|---|
| **BSI** | គម្រោងសាលារៀនដៃគូ | **IEP** | កម្មវិធីអប់រំបញ្ចូលគ្នា | **PLP** | គម្រោងគាំទ្រការសិក្សារបស់សិស្ស |
| **DPO** | មន្ត្រីបច្ចេកទេសថ្នាក់ស្រុក | **PC** | អ្នកសម្របសម្រួលថ្នាក់ខេត្ត | **SDPP** | កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា |
| **SELLS** | គម្រោងសាលារៀនមានបំណិនជីវិតពេញបរិបូរណ៍ | **PO** | មន្ត្រីកម្មវិធី | **SFP** | កម្មវិធីអាហារពេលព្រឹក |
| **IBEC** | គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា | **QLE/I'm learning!** | គម្រោងខ្ញុំកំពុងរៀន! | **TL** | ប្រធានក្រុម |

ផ្នែកដឹកនាំ

ព្រួញមុខពីរ = ទំនាក់ទំនងជាមួយទីប្រឹក្សា

ប្រអប់ដាច់ៗ = ស្វ័យយ័តភាព ។ SDPP គឺជាគម្រោងពាក់កណ្ដាលស្វ័យយ័ត ។ គណៈកម្មការគ្រប់គ្រងមូលនិធិសុខភាពមានស្វ័យយ័តភាពពេញលេញ ។

POs** មានគម្រោងអប់រំកុមារី (GEI), គម្រោងអាហារូបករណ៍សម្រាប់សិស្សនៅមហាវិទ្យាល័យ (CTSP) និងគម្រោងសេវាអប់រំជនជាតិដើម (PEI)។ "POs" បង្ហាញអំពីមន្ត្រីទាំងអស់នៅក្នុងកម្មវិធី IEP។

*សូមបញ្ជាក់ថា លំដាប់ថ្នាក់ក្នុងរចនាសម្ព័ន្ធខាងក្រោម ប្រធានផ្នែកនីមួយៗមិនត្រូវបានបញ្ចូលទៅក្នុងផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស/រដ្ឋបាល ដែលបានកំណត់ហើយនៅក្នុងបញ្ជីឈ្មោះ ៕




# បេសកកម្ម

បេសកកម្មរបស់អង្គការ ខេប គឺធ្វើការជាមួយរដ្ឋាភិបាល សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់អំណាចដល់កុមារ និងយុវជនរងគ្រោះ ក្នុងការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពតាមរយៈវិធីច្នៃប្រឌិតថ្មី ។


## ខេប

## អង្គការ សកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា

*“ការអភិវឌ្ឍមនុស្សប្រកបដោយសេចក្តីថ្លៃថ្នូរ ”*

ការិយាល័យ: សាលាគរុកោសល្យ និងវិក្រិតការខេត្ត ផ្លូវជាតិលេខ ៧ចាស់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម
ប្រអប់សំបុត្រ: P.O Box 1621 ភ្នំពេញ កម្ពុជា

ទូរស័ព្ទលើតុ: 042-941-481 / 042-941-918
អ៊ីមែល: kape@kapekh.org
គេហទំព័រ: www.kapekh.org
បណ្តាញសង្គម: Facebook: www.facebook.com/kapeaction
Google+: www.plus.google.com/+KAPECambodia
Linkedin: www.linkedin.com/company/kampuchean-action-for-primary-education
YouTube: www.youtube.com/TheKapeCambodia